# វប្បធម៌ ព្រហ្មចារី នៅកម្ពុជា

២០
២១

## ការសិក្សាអំពីទស្សនៈសង្គម

ក្លាហាន
klahaan
brave

rfsu

HEINRICH BÖLL STIFTUNG

ការសិក្សាស្រាវជ្រាវនេះអាចសម្រេចបានដោយជោគជ័យអាស្រ័យដោយមានការគាំទ្រមូលនិធិសប្បុរសពី
RFSU និង HBS.

# មាតិកា


១.០ សេចក្ដីផ្ដើម

២.០ វិធីសាស្ត្រ

២.១ វិធីសាស្ត្រ និងការបង្កើតកូដ
២.២ ក្រមសីលធម៌ និងដែនកំណត់

៣.០ ការត្រួតពិនិត្យ និងវិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធ

៤.០ ការរំពឹងទុក

៤.១ វប្បធម៌
៤.២ សង្គម
៤.៣ គ្រួសារ

៥.០ ផលវិបាក

៥.១ ផ្លូវចិត្ត
៥.២ ផ្លូវកាយ
៥.៣ អាពាហ៍ពិពាហ៍

៦.០ បទពិសោធន៍របស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា

៧.០ ការវិវត្តន៍នៃបរិបទសង្គម ?

៨.០ សេចក្ដីសន្និដ្ឋាន




**សមាជិកក្រុមស្រាវជ្រាវរបស់អង្គការក្លាហាន**
បុណ្យ រចនា
Kate Seewald
ពេជ្រ ភារ័ក្ស
ហេង អេឡៃន
សឿង សារិន
ហុង សុភ័ក្ត្រវឌ្ឍនៈ

**សមាជិកក្រុមស្រាវជ្រាវសកម្មស្នូល**
គង់ ស្រីនូ
ប៉ា សុខេង
ឆឹង ស៊ីអ៊ឹន
លាន ឆវ័ន្ត
មេត មន្ថារី
តាំង ស៊ីវហ្គេច
សុទ្ធ ពៅសំណាង
វិរៈ កញ្ញាពេជ្រ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកចូលរួមគ្រប់រូបនៅក្នុងគម្រោងសិក្សាស្រាវជ្រាវនេះដែលបានលះបង់នូវពេលវេលាដ៏មានតម្លៃដោយសប្បុរសដើម្បីជួយឱ្យការសិក្សាស្រាវជ្រាវនេះប្រព្រឹត្តិទៅ និងសម្រេចបានសមិទ្ធិផលដ៏ជោគជ័យ។ ក្នុងនេះរួមមាន អ្នកតបសម្ភាសគ្រប់ជំនាន់ដែលបានចូលរួមផ្តល់បទសម្ភាសន៍ និង អ្នកឯកទេសសិទ្ធិស្ត្រីនៅក្នុងរាជធានីភ្នំពេញផងដែរ។

អង្គការ ក្លាហាន សូមថ្លែងអំណរគុណ និងកោតសរសើរជាពិសេសដល់ក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋាន។ អ្នកស្រាវជ្រាវវ័យក្មេងទាំងនេះ  បានលះបង់នូវពេលវេលាផ្ទាល់ខ្លួន ព្រមទាំងការប្តេជ្ញាចិត្ត និងក្តីសោមនស្ស ដែល ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះកាន់តែមានភាពប្រសើរឡើង។

# ១.០ សេចក្តីផ្តើម

## បរិបទ &គោលបំណងស្រាវជ្រាវ ១/២

ស្ទើរតែគ្រប់ទិដ្ឋភាពនៃការសម្រេចចិត្ត អំពីការរួមភេទជាលើកដំបូងមិនថានៅពេលណា និងជាមួយអ្នកណាទេ នេះគឺជាការសម្រេចចិត្តផ្ទាល់ខ្លួនដ៏សំខាន់បំផុតរបស់បុគ្គលម្នាក់ៗ។ ទោះជាយ៉ាងនេះក្តី មានរបាយការណ៍ ស្រាវជ្រាវមួយចំនួនបានបង្ហាញថាមានកត្តាជម្រុញពីខាងក្រៅជាច្រើនដែលអាចជះឥទ្ធិពលដល់ការសម្រេចចិត្តនេះផងដែរ  ហើយកត្តាទាំងនេះ មានលក្ខណៈខុសៗគ្នា ផ្អែកលើអត្តសញ្ញាណយេនឌ័រ និងសម័យកាល ដែលបុគ្គលម្នាក់ៗធំធាត់ឡើង[១]។

ទោះបីជាសង្គមកម្ពុជាមានប្រជាជន ប្រមាណជា ២/៣ ដែលមានអាយុក្រោម៣០ឆ្នាំ [២] ហើយបាននឹងកំពុងប្រើប្រាស់បណ្តាញអ៊ីនធឺណិតចាប់តាំងពី វ័យជំទង់មកម្ល៉េះនោះ ក៏នៅមិនទាន់មានការសិក្សាស្រាវជ្រាវគ្រប់ជ្រុងជ្រោយទាក់ទងនឹងរបៀបដែលមនុស្សជំនាន់ថ្មីនេះ 'មនុស្សសម័យបច្ចេកវិទ្យា' ធ្វើការសម្រេចចិត្តជុំវិញរឿងរ៉ាវផ្លូវភេទ និងឥរិយាបថរបស់ពួកគេអំពីផ្នត់គំនិតសង្គមជុំវិញផ្នត់គំនិតព្រហ្មចារីនៅឡើយទេ។

ការស្រាវជ្រាវនេះមានគោលបំណងដោះស្រាយនូវចំណុចចន្លោះប្រហោង និងឆ្វេងយល់អំពី ទស្សនៈឥរិយាបថ និងផ្នត់គំនិតរបស់យុវជនកម្ពុជាអំពីព្រហ្មចារី និងដើម្បីកត់សម្គាល់ថា តើការយល់ឃើញទាំងនោះមានភាពខុសប្លែកពីមនុស្សជំនាន់មុនដែរឬទេ។ ការវិភាគទិន្នន័យដែលប្រមូលមកពីវាលតាមរយៈការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ និងការស្ទង់មតិប្រជាពលរដ្ឋដែលមាន អាយុ អត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទខុសៗគ្នានឹងចង្អុលបង្ហាញ ព្រមទាំងផ្តល់នូវការបកស្រាយជុំវិញទស្សនៈខុសគ្នាចម្បងៗ។



# បរិបទ &គោលបំណងស្រាវជ្រាវ (បន្ត) ២/២

ការយល់ដឹងច្រើនអំពីរបៀបដែលយុវជនកម្ពុជាប្រើប្រាស់នៅក្នុងការសម្រេចចិត្តជុំវិញរឿងរ៉ាវផ្លូវភេទផ្ទាល់ខ្លួន និងឥរិយាបថរបស់ពួកគេទៅលើជម្រើសរបស់មិត្តភ័ក្តិ និងមនុស្សជុំវិញខ្លួនគេមានសារៈសំខាន់សម្រាប់អ្នកតស៊ូមតិ ដែលប៉ុនប៉ងធ្វើការជាមួយក្រុមយុវជនជុំវិញបញ្ហាទាក់ទងនឹងទំនាក់ទំនងស្និទ្ធស្នាល និងសុខមាលភាពផ្លូវភេទ។

សញ្ញាណនៃការទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ការរួមភេទដោយមានការព្រមព្រៀងនិងពេញចិត្ត សិទ្ធិផ្នែកផ្លូវភេទ និងសុខភាពបន្តពូជ (SRHR) និង អំពើហិង្សាផ្អែកលើយេនឌ័រ (GBV) គឺជាឧទាហរណ៍នៃបញ្ហាសំខាន់ៗមួយចំនួនដែលយុវជនកម្ពុជាកំពុងតែជួបប្រទះ និងបង្កប់នូវស្លាកស្នាម ឬភាពអាម៉ាស់ដែលផ្សាភ្ជាប់ទៅនឹងការសម្រេចចិត្តជុំវិញរឿងរ៉ាវផ្លូវភេទដែលអាចជះឥទ្ធិពលទៅលើបទពិសោធន៍របស់យុវវ័យជុំវិញបញ្ហាទាំងនេះ ឬ បន្ថែមបន្ទុកទៅលើពួកគេកាន់តែខ្លាំងថែមទៀត។

យើងសង្ឃឹមថាការសិក្សាស្រាវជ្រាវនេះនឹងរួមចំណែកបង្កើតឱកាសសម្រាប់ការពិភាក្សាដោយបើកចំហ និងគ្មានបុរេវិនិច្ឆ័យអំពីការសម្រេចចិត្តផ្នែកផ្លូវភេទ រួមទាំង ស្វ័យភាពនិងបូរណភាពរាងកាយផងដែរ ដែលចំណុចទាំងអស់នេះគឺជាមូលដ្ឋាននៃបទពិសោធន៍ជីវិតរបស់យើងម្នាក់ៗក្នុងនាមជាមនុស្ស ប៉ុន្តែមិនសូវបានយកមកវិភាគ ឬពិភាក្សានៅក្នុងបរិបទកម្ពុជា។

តាមរយៈការប្រើប្រាស់វិធីសាស្ត្រសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) ការស្រាវជ្រាវនេះត្រូវបានសហការរៀបចំដោយយុវជនកម្ពុជាចំនួន ០៨ រូប និងផ្តល់នូវភស្តុតាងបឋមសម្រាប់អ្នកតស៊ូមតិយកទៅប្រើប្រាស់ ដើម្បីបង្កើត និង/ឬ សម្រួចសាររបស់ពួកគេជុំវិញសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជដើម្បីឲ្យការតស៊ូមតិរបស់ពួកគេកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ការស្រាវជ្រាវនេះក៏អាចជាចំណុចចាប់ផ្តើមដំបូងមួយសម្រាប់អ្នកស្រាវជ្រាវផ្សេងទៀតប្រើប្រាស់ជាមូលដ្ឋានសម្រាប់ធ្វើការសិក្សាឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនាពេលអនាគត។

## គោលបំណងនៃស្រាវជ្រាវ

ក្រុមអ្នកស្រាវជ្រាវបង្កើតគោលបំណងខាងក្រោមនេះ ដើម្បីកំណត់នូវអ្វីដែលពួកគេរំពឹងថានឹងអាចយល់ដឹងបន្ថែមតាមរយៈការសិក្សានេះ៖

- ស្វែងយល់ថាតើយុវជនកម្ពុជាមានការយល់ឃើញទូលំទូលាយជាងមនុស្សវ័យចំណាស់ដែរ ឬទេជុំវិញប្រធានបទទាក់ទងនឹងស្វ័យភាពផ្លូវភេទរបស់ស្ត្រីនិងវប្បធម៌ព្រហ្មចារី
- ស្វែងយល់អំពីទស្សនៈរបស់ប្រជាពលរដ្ឋកម្ពុជាជុំវិញការសម្រេចចិត្តរបស់ដៃគូស្និទ្ធស្នាលដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការចាប់ផ្តើមមានទំនាក់ទំនងផ្លូវភេទនៅក្នុង (ឬនៅក្រៅ)ទំនាក់ទំនងស្និទ្ធស្នាលរបស់ពួកគេ

# ២.០ វិធីសាស្ត្រស្រាវជ្រាវ

## វិធីសាស្ត្រស្រាវជ្រាវ ១/២

ការស្រាវជ្រាវនេះបានអនុវត្តតាមគោលការណ៍នៃការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) នៅគ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំ និងដំណើការនៃការស្រាវជ្រាវ។ APWLD ដែលជាអ្នកបង្កើត និងអនុវត្តវិធីសាស្ត្រ FPAR ដំបូងគេនៅក្នុងតំបន់បានផ្តល់ការពន្យល់ថា FPAR គឺជាវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីស៊ើបអង្កេតបញ្ហាសង្គមនានា តាមរយៈការចូលរួមដោយផ្ទាល់ ពីសំណាក់ភាគីដែលទទួលរងនូវការគាបសង្កត់ និងប្រជាពលរដ្ឋទូទៅនៅក្នុងការកំណត់ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមរបស់ពួកគេ។



FPAR គឺជា "មធ្យោបាយដែលអ្នកឯកទេសផ្នែកស្រាវជ្រាវ និងអ្នកចូលរួមអាចសហការរៀបចំសកម្មភាពរួមគ្នាដែលអាចជាសកម្មភាពរយៈពេលខ្លី និង/ឬ រយៈពេលវែងក្នុងគោលបំណងដើម្បីផ្លាស់ប្តូរសង្គមជាវិជ្ជមាន" [៣] ។ FPAR បានរួមបញ្ចូលយ៉ាងហ្មត់ចត់នូវគោលការណ៍ និងដំណើរការដែលផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយមដែលជាមធ្យោបាយប្រើប្រាស់ដើម្បីកសាងសមត្ថភាព និងចែករំលែកចំណេះដឹងក្នុងចំណោមអ្នកចូលរួមផងដែរ។




ក្នុងន័យនេះ  ក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋានត្រូវបានអញ្ជើញឲ្យចូលរួមសហការរៀបចំគម្រោងសិក្សាស្រាវជ្រាវទាំងមូល។ ក្រុមស្រាវជ្រាវសកម្មមានយុវជនកម្ពុជាចំនួន ០៨រូប ដែលស្នាក់នៅរាជធានីភ្នំពេញ និងខេត្តពោធិ៍សាត់។ ពួកគេបានទទួលការបណ្តុះបណ្តាលអំពីក្រមសីលធម៌នៃការស្រាវជ្រាវ  បច្ចេកទេសប្រមូលទិន្នន័យ ព្រមទាំងបានចូលរួមក្នុងដំណើរការទាំងស្រុងនៃគម្រោងសិក្សាស្រាវជ្រាវ។



វិធីសាស្ត្របែបគុណវិស័យដែលប្រើប្រាស់ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ បានផ្តល់ឱកាសដល់ក្រុមស្រាវជ្រាវអាចធ្វើការពិភាក្សាក្រៅផ្លូវការ និងស៊ីជម្រៅ។ ការសម្ភាសន៍ត្រូវបានធ្វើឡើង តាមប្រព័ន្ធអនឡាញ ឬជួបសម្ភាសផ្ទាល់ ដោយគិតគូរដល់ការអនុវត្តន៍នូវគោលការណ៍រក្សាគម្លាតសង្គមផងដែរ។

# វិធីសាស្ត្រស្រាវជ្រាវ (បន្ត) ២/២

## ការបង្កើតកូដ & ការវិភាគ

សមាជិកក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋានបានចូលរួមយ៉ាងសកម្មនៅគ្រប់ដំណាក់កាលនៃការសិក្សាស្រាវជ្រាវ មានន័យថាពួកគេមិនមែនចូលរួមត្រឹមតែជា "អ្នកប្រមូលទិន្នន័យ" ដែលទទួលបានកម្រងសំណួរយកទៅធ្វើការស្ទង់មតិ និងបញ្ជូនលទ្ធផលស្ទង់មតិទាំងនោះត្រឡប់មកវិញនោះទេ។

នៅក្នុងការបង្កើតកូដទិន្នន័យគុណវិស័យ ក្រុមស្រាវជ្រាវសកម្មបានចូលរួមវគ្គបណ្តុះបណ្តាលដែលភ្ជាប់ជាមួយនូវការអនុវត្តស្តីអំពីការវិភាគទិន្នន័យតាមផ្នែក នៅក្នុងរាជធានីភ្នំពេញ។ ទិន្នន័យសម្ភាសន៍នៅវាលត្រូវបានយកមកវិភាគនិងបែងចែកជាកូដដោយក្រុមស្រាវជ្រាវសកម្មដោយផ្ទាល់។

សេចក្តីថ្លែងដកស្រង់ពីអ្នកចូលរួមត្រូវបានកំណត់សម្គាល់ដោយអក្សរ 'Z' សម្រាប់អ្នកចូលរួមវ័យក្មេង 'O' សម្រាប់មនុស្សចាស់ និង 'C' សម្រាប់អ្នកចូលរួមមកពីសង្គមស៊ីវិល (CSO) ។ បច្ច័មបទ 'M' ឬ 'F' តំណាងឱ្យបុរស ឬស្ត្រី។ ឧទាហរណ៍ O11F ប្រើសម្រាប់សម្គាល់អ្នកចូលរួមជាស្ត្រីវ័យចំណាស់ ចំណែកឯ Z38M ប្រើដើម្បីសម្គាល់អ្នកចូលរួមដែលជាបុរសវ័យក្មេង។

## ការស្ទង់មតិអនឡាញ

បន្ថែមលើការសម្ភាសន៍នៅវាល ការស្ទង់មតិតាមអនឡាញត្រូវបានធ្វើឡើងដើម្បីផ្តល់នូវការយល់ដឹងឱ្យកាន់តែស៊ីជម្រៅបែបបរិមាណវិស័យបន្ថែមទៀត។ ការស្ទង់មតិបានបិទបញ្ចប់បន្ទាប់ពីទទួលបានការឆ្លើយតបចំនួន ៣,៧០០។ ទិន្នន័យបែបបរិមាណវិស័យត្រូវបាន វិភាគដោយប្រើប្រាស់កម្មវិធី Excel ហើយរបកគំហើញត្រូវបានបញ្ចូលនៅគ្រប់ផ្នែកនីមួយៗនៃរបាយការណ៍នេះ។






| អ្នកតបសម្ភាសន៍ | ចំនួន | កូដ | សរុប = ៧២ នាក់ |
|---|---|---|---|
| អង្គការសង្គមស៊ីវិល (អ្នកតស៊ូមតិយេនឌ័រ) | ៥ | 'C' | |
| អ្នកតបសម្ភាសន៍វ័យក្មេង (ជំនាន់ Z &M) | ៤៩ | 'Z' | |
| អ្នកតបសម្ភាសន៍ចំណាស់ (ជំ. X, ជំ. សង្គ្រាម) | ១៨ | 'O' | |

# ៣.០ ការពិនិត្យ និងវិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់

## 'កុំទុំ មុនស្រគាល'

## 'បុរស ជាមាសទឹកដប់ នារី ជាក្រណាត់ស'

ខណៈដែលមានអក្សរសិល្ប៍ជាច្រើនបានពិភាក្សាអំពីការរួមភេទមុនរៀបការនៅកម្ពុជា យើងកត់សម្គាល់នូវដែនកំណត់ និងចំណុចខ្វះចន្លោះពេលធ្វើការពិនិត្យអក្សរសិល្ប៍ទាំងនេះ សម្រាប់ការសិក្សាស្រាវជ្រាវ។ ចំណុចទីមួយ លើកលែងតែករណីសិក្សាមួយចំនួនរួមមាន Nishigaya [៤], Hoefinger [៥] និង Farvid & Saing [៦] ភាគច្រើននៃអត្ថបទដែលត្រូវបានគេប្រើជាប្រភពញឹកញាប់ទាក់ទងនឹងប្រធានបទការរួមភេទមុនពេលរៀបការនៅកម្ពុជានេះគឺមានអាយុកាលចាប់ពី ២០ ដល់ ២៥ឆ្នាំទៅហើយ។ ដោយផ្អែកលើការប្រែប្រួលយ៉ាងឆាប់រហ័សនៃបរិបទសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា អត្ថបទទាំងនោះអាចមិនឆ្លុះបញ្ចាំងទិដ្ឋភាពជាក់ស្តែង ឬបាត់បង់នូវខ្លឹមសារពេញលេញដែលធ្លាប់មានខណៈចេញផ្សាយដំបូង។

ចំណុចគួរឱ្យកត់សម្គាទីពីរ អក្សរសិល្ប៍ភាគច្រើនសរសេរផ្អែកលើទស្សនៈនៃសុខមាលភាពសាធារណៈដែលមិនសូវផ្តោតសំខាន់ក្នុងការធានានូវទស្សនៈ និង 'សម្លេង' របស់អ្នកចូលរួមដែលជាចំណុចអាទិភាព ហើយជំនួសដោយការសង្កត់ធ្ងន់ទៅលើសូចនាករបែបបរិមាណវិស័យ (សូមមើលគំនូសម្គាល់ទី ១)។ ការសិក្សានេះក៏អនុវត្ត ទស្សនៈ និងភាសានៃ "កត្តាហានិភ័យ" និង "សកម្មភាពហានិភ័យ" នៅពេលពិភាក្សាអំពីអត្រាប្រេវ៉ាឡង់នៃ P-MS ។

ភាសា និងការផ្តោតលើបរិមាណនេះ ឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់លើផលជះមកលើសុខភាពរាងកាយ ដូចជាការឆ្លងជំងឺតាមរយៈការផ្លូវភេទ (STIs) ជាដើម។

ទោះជាយ៉ាងណា ការផ្តោតទៅលើកត្តាទាំងអស់នេះមិនបានគិតគូរដល់ ឬ ផ្តល់ការយកចិត្តទុកដាក់លើបទពិសោធន៍វិជ្ជមាន ការទទួលស្គាល់នូវការរួមភេទមុនរៀបការដោយសុវត្ថិភាព និងមានការព្រមព្រៀងក្នុងចំណោមប្រជាជនកម្ពុជាដែលមិនទាន់រៀបការ និងស្ថិតក្នុងទំនាក់ទំនងរយៈពេលវែងនោះទេ។ ការសិក្សាភាគច្រើនមិនបានរាប់បញ្ចូល ឬ ទទួលស្គាល់នូវ បទពិសោធន៍ផ្លូវភេទរបស់សហគមន៍អ្នកស្រឡាញ់ភេទ ដូចគ្នានោះទេ។

> "ស្ត្រីនៅកម្ពុជាចាប់ផ្តើមរួមភេទរយៈពេល០,២ឆ្នាំ ក្រោយពេលរៀបការ នៅអាយុ ២០,៧ឆ្នាំ។
>
> ផ្ទុយទៅវិញ បុរសមានទំនោរចាប់ផ្តើមសកម្មភាពផ្លូវភេទ ១ឆ្នាំ មុនពេលរៀបការនៅអាយុ ២២,០ឆ្នាំ"

**គំនូសសម្គាល់ទី ១៖**
**ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ [៧]**

ទោះបីជាមានភាពចន្លោះក៏ដោយ ឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ទាំងអស់នេះបានផ្តល់នូវរបកគំហើញមួយចំនួនសម្រាប់ជាមូលដ្ឋានក្នុងការផ្ទៀតផ្ទាត់ និងវែកញែកនូវផ្នែកថ្មីៗមួយចំនួនទៀតដែលរកឃើញ នៅក្នុងគម្រោងស្រាវជ្រាវនេះ។ ចំណុចទីមួយគឺ សញ្ញាណនៃ 'លក្ខណៈប្រពៃ' របស់ស្ត្រីខ្មែរ ដែលត្រូវបានផ្សាភ្ជាប់ជាមួយភាពបរិសុទ្ធរបស់នាង។ ឧទាហរណ៍ដូចដែល Hoefinger [៨] បានលើកឡើង៖

"កូនស្រីដែលមានការទទួលខុសត្រូវបង្ហាញពីគុណធម៌របស់ពួកគេចំពោះញាតិជិតខាង និងមនុស្សម្នានៅជុំវិញខ្លួនពួកគេ តាមរយៈការរួមចំណែក រកប្រាក់ចំណូលសម្រាប់គ្រួសារ និងការរក្សាភាពបរិសុទ្ធរបស់ពួកគេ... កូនស្រីក្រមុំ តំណាងឱ្យភាពប្រុងប្រយ័ត្ន សុភាពរាបសារ ភាពបរិសុទ្ធ ភាពស្លូតត្រង់ និងភាពងាយរងគ្រោះមិនត្រឹមតែសម្រាប់ខ្លួនពួកគេ ប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់គ្រួសារទាំងមូលផងដែរ។"

ចំណុចទីពីរដែលកត់សម្គាល់ពីការត្រួតពិនិត្យ ឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធគឺវត្តមាននៃភាពទ្វេស្តង់ដាររវាងយេនឌ័រ ដែលបានគូសបញ្ជាក់ដោយ Hoefinger ផងដែរ៖

"ខណៈដែល **ការថែរក្សាព្រហ្មចារីត្រូវបានចាត់ទុកជាកាតព្វកិច្ចដាច់ខាតសម្រាប់កូនក្រមុំ** និងការប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ខាងផ្លូវភេទគឺជាតួនាទីរបស់ភរិយា ប្តី/ប្តី ត្រូវបានគេរំពឹងថាត្រូវមានបទពិសោធន៍ផ្លូវភេទនៅពេលរៀបការ...ចំណែកឯ... ស្ត្រី ត្រូវតែបង្ហាញការអត់ធ្មត់ ឬភាពឆោតល្ងង់ខាងផ្លូវភេទ ហើយបុរសខ្មែរត្រូវបានចាត់ទុកថាមានចំណង់ផ្លូវភេទមិនចេះឆ្អែតឆ្អន់ដោយសារតែកត្តាធម្មជាតិ និងកត្តាជីវសាស្ត្រ។"

នៅក្នុងការសិក្សាស្រាវជ្រាវអំពីអាកប្បកិរិយាផ្លូវភេទរបស់នារីនៅលីវវ័យក្មេងដែលធ្វើការក្នុងវិស័យកាត់ដេរក្នុងរាជធានីភ្នំពេញ Nishigaya [៩] ក៏ឆ្លុះបញ្ចាំងពីការរំពឹងទុកខុសៗគ្នារវាងបុរស និងស្ត្រីថា៖

"ដើម្បីស័ក្តិសមជាបុរស និងបុរិសភាវរូប បុរសគួរតែមានដៃគូរួមភេទច្រើននាក់ និងបទពិសោធន៍ផ្លូវភេទផ្សេងៗគ្នា... ផ្ទុយទៅវិញ **រាងកាយ និង សេរីភាពដើរហើររបស់ស្ត្រីគឺ ស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង**... ការបាត់បង់ព្រហ្មចារីរបស់ក្មេងស្រីមុនពេលរៀបការ...នាំមកនូវភាពអាប់អោនដល់កិត្តិយស និងឋានៈ គ្រួសាររបស់ នាងក្នុងសង្គម។"

ចុងក្រោយ អ៊ុល ណារិទ្ធ [១០] បានពន្យល់អំពីស្លាកស្នាម និងភាពអាម៉ាស់សម្រាប់ស្ត្រីដែលបានរួមភេទមុនពេលរៀបការ (ទោះបីជាពិភាក្សាអំពីស្ត្រីប្រកបរបរផ្លូវភេទក៏ដោយ)៖

"...មានការទទួលយកជាទូទៅថា បុរសដែលបានរៀបការ ឬមិនទាន់រៀបការ អាចទៅប្រើប្រាស់សេវាកម្មផ្លូវភេទ ឬមានទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍បាន។ ដូច្នេះ ស្ត្រីប្រកបរបរផ្លូវភេទត្រូវបានគេចាត់ទុកថា "កខ្វក់" ឬ "ស្ត្រីមិនល្អ" ដោយសារពួកគេបានបំពេញចំណង់ផ្លូវភេទរបស់បុរសខ្មែរ ហើយពួកគេមិនទទួលបានការការពារពីសង្គមឡើយ...។"

# ការពិនិត្យ និងវិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ (បន្ត) ៣/៣



តាមរយៈរបកគំហើញរបស់អ្នកស្រាវជ្រាវមុនៗបានបង្ហាញថាមានការដាក់កម្រិតយ៉ាងតឹងរឹងខាងផ្នែកវប្បធម៌ សាសនា និងសង្គមទៅលើស្ត្រី និងជំរុញស្ត្រីមិនឲ្យរួមភេទមុនពេលរៀបការ ខណៈបុរសមិនបានទទួលរងនូវ ការរឹតត្បឹត និងគ្រប់គ្រងរាងកាយក្នុងកម្រិតដូចស្ត្រីនោះទេ។

ដោយមានការលេចឡើង និងការកើនឡើងនៃយុវជនជំនាន់ថ្មី ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលមានការ យល់ដឹងកាន់តែច្រើនទាក់ទងនឹងប្រព័ន្ធឌីជីថលតើបទដ្ឋាន សង្គមទាក់ទងនឹងការរួមភេទមុនពេលរៀបការ និងព្រហ្មចារីនេះមានការផ្លាស់ប្តូរដែរ ឬទេហើយផ្លាស់ប្តូរដោយរបៀបម៉េច?

យុវវ័យជំនាន់ហ្សី នៅកម្ពុជា (អ្នកដែលចាប់កំណើតចាប់តាំងឆ្នាំ ១៩៩៧) និងយុវវ័យសហស្សវត្សរ៍ (អ្នកដែលចាប់កំណើតនៅចន្លោះឆ្នាំ ១៩៨៩ និង ១៩៩៦) ត្រូវបានចាត់ ទុកថាជាក្រុមដែលបានកើនឡើងយ៉ាងឆាប់រហ័សនិងមានលទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់បណ្តាញសង្គមនិងកម្មវិធី ផ្ញើសារផ្សេងៗ។ បន្ថែមលើនេះវត្តមាននៃកម្មវិធីកម្សាន្តដ៏ពេញនិយមដូចជារឿងភាគស្នេហារបស់កូរ៉េ និងក្រុមហ៊ុនផលិតកម្មថ្មីៗ តាមរយៈ Netflix ដែលអាចឱ្យអ្នកទស្សនាចូលមើលកម្មវិធីកំពុងពេញនិយមជាច្រើនដូចជាខ្សែភាពយន្ត Sex Education និង Bridgerton។

យើងនឹងពិភាក្សាឡើងវិញដោយលម្អិតបន្ថែមទៀតអំពីឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់នៅតាមផ្នែកនីមួយៗក្នុងរបាយការណ៍នេះ។ តាមរយៈការកំណត់បរិបទនៃរបកគំហើញជាក់ស្តែងនៃគម្រោងស្រាវជ្រាវ  ក៏ដូចជាការប្រៀបធៀបរបកគំហើញថ្មីៗជាមួយបទវិភាគដែលមានស្រាប់។

# ៤.០ ការរំពឹងទុក

## របកគំហើញទាក់ទងនឹងការរំពឹងទុក ជុំវិញព្រហ្មចារីនៅកម្ពុជា

នេះគឺជាផ្នែកទីមួយ នៅក្នុងចំណោមផ្នែកទាំងបួននៃរបាយការណ៍ដែលស្វែងយល់ពី ទស្សនៈ និងឥរិយាបថរបស់អ្នកចូលរួមចំពោះការរួមភេទមុនពេលរៀបការនៅប្រទេសកម្ពុជា។ ផ្នែកទីមួយនេះ ពិនិត្យមើលពីរបៀបដែលអ្នកចូលរួមយល់ឃើញទាក់ទងនឹងការរួមភេទមុនពេលរៀបការដែលនាំឱ្យមាន 'ការរំពឹងទុក' ខុសៗគ្នា ទៅតាមយេនឌ័រផ្សេងគ្នា ហើយការរំពឹងទុកទាំងនោះ ត្រូវបានបែងចែកចេញជាបីផ្នែកសំខាន់ៗដែលមានភាពអន្តរប្រសព្វគ្នាទៅវិញទៅមក។

ផ្នែកទីមួយ សិក្សាស្វែងយល់អំពីការរំពឹងទុកទាក់ទងនឹងព្រហ្មចារី ដែលត្រូវបានណែនាំ និងថែរក្សាដោយផ្ទាល់ពីបទដ្ឋានវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណី។ ផ្នែកទីពីរស្វែងយល់ពីការរំពឹងទុកពីសំណាកប្រជាពលរដ្ឋកម្ពុជានាសម័យបច្ចុប្បន្ននេះ ជុំវិញសកម្មភាពផ្លូវភេទរបស់សមាជិកគ្រួសារដែលមិនទាន់រៀបការ។

ចុងក្រោយ ជាផ្នែកនៃចំណុចប្រសព្វរវាងផ្នែកទាំងពីរខាងលើគឺការយល់ឃើញរបស់អ្នកចូលរួមទាំងអស់ អំពីការរំពឹងទុករបស់សង្គមធំចំពោះផ្នែកទីមួយ និងទីពីរ។

វប្បធម៌

គ្រួសារ

សង្គម



## ៤.១ ការរំពឹងទុកផ្នែក វប្បធម៌

**"ព្រហ្មចារីបានក្លាយជាផ្នែកមួយនៃវប្បធម៌ខ្មែរ ដោយផ្អែកលើទំនៀមទម្លាប់ប្រពៃណី។ មូលហេតុនោះគឺតាំងពីសម័យដើមមក ប្រជាជនខ្មែរតែងតែទូន្មានកូនៗរបស់ពួកគាត់ មិនឱ្យរួមភេទមុនពេលរៀបការដែលជាកត្តានាំឱ្យព្រហ្មចារីក្លាយជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ខ្មែរ។"** ( Z23 F )

ឆ្លងកាត់ប្រវត្តិសាស្ត្រដ៏យូរលង់របស់ប្រទេសកម្ពុជា កន្លងមកការប្រតិបត្តិរបស់ប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់ បានក្លាយទៅជាវប្បធម៌មួយដែលមានមូលដ្ឋានរឹងមាំ និងខុសប្លែកពីគេ ជាមួយនឹងបទដ្ឋានសង្គម និងជំនឿផ្សេងៗគ្នា។ ដូចដែលបានស្វែងយល់រួចមកហើយនៅក្នុងការពិនិត្យ និង វិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ មុខងារសំខាន់នៃវប្បធម៌ខ្មែរគឺត្រូវបានកំណត់ និងថែរក្សាដោយផ្អែកលើគោលការណ៍នៃ 'ការអនុគ្រោះ' និង ទំនាក់ទំនងសង្គមដែលមានការពឹងផ្អែកគ្នាទៅវិញទៅមក ប៉ុន្តែមានវិសមភាពធំរវាងតួនាទីរបស់ស្ត្រី និងបុរសក្នុងសង្គម ដែលក្នុងនោះបុរសទទួលបាននូវអំណាច និងបុព្វសិទ្ធិច្រើនលើសលប់ជាងស្ត្រីនៅគ្រប់កម្រិតទាំងអស់ក្នុងសហគមន៍។

ទាក់ទិននឹងស្ថានភាពផ្លូវភេទវិញ "ភាពទ្វេស្តង់ផ្លូវភេទដ៏តឹងរឹង គ្រប់គ្រងយ៉ាងខ្លាំងលើការរួមភេទដែលបុរសត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយសង្គមក្នុងការធ្វើការរួមភេទមុនពេលរៀបការ និងរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ ចំណែកឯ ស្ត្រីវិញមិនទទួលបាននូវការទទួលស្គាល់ និងអនុញ្ញាតពីសង្គមនោះទេ [១១]។ ហេតុនេះក៏ព្រោះថា នៅក្នុងសង្គមកម្ពុជា ស្ត្រីត្រូវបានអប់រំឲ្យគោរពនូវការបង្រៀន បទដ្ឋានសង្គម និងទំនៀមទម្លាប់យ៉ាងល្អិតល្អន់ដើម្បីក្លាយជាស្ត្រី «គ្រប់លក្ខណ៍» និងនាំកិត្តិយសដល់ក្រុមគ្រួសារ។

ជាឧទាហរណ៍ មានគំនិតដែលលើកឡើងថាស្ត្រីមានតួនាទីក្នុងការថែរក្សា "ភាពសុខដុមរមនានៃអាពាហ៍ពិពាហ៍ និងក្នុងក្រុមគ្រួសារ" ឬតាមសុភាសិតខ្មែរមួយ គេនិយាយថា "ស្ត្រីនៅតែក្នុងផ្ទះបាយ"។

ការយល់ឃើញបែបនេះ ត្រូវបានអ្នកចូលរួមជាច្រើនលើកឡើងនៅពេលពួកគេផ្តល់បទសម្ភាសន៍។ ជាការពិតណាស់ ការឆ្លើយតបបែបនេះ ភាគច្រើនជាចម្លើយរបស់មនុស្សវ័យចំណាស់ ដែលពួកគាត់មិនចាត់ទុកការរួមភេទមុនពេលរៀបការរបស់ស្ត្រីខ្មែរថា ជាទង្វើជាច់ដោយឡែកនោះទេ ផ្ទុយទៅវិញ ពួកគាត់យល់ឃើញថា វាគឺជាផ្នែកសំខាន់មួយដែលចូលរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរ និងការចាកឆ្ងាយពីបទដ្ឋានសង្គម ក៏ដូចជាបែបបទប្រពៃណីខ្មែរដែលបានចាក់ឫសគល់ជាច្រើនសតវត្សរ៍មកហើយ។

ដូច្នេះហើយ ការរក្សានូវភាពថ្លៃថ្នូរ និងភាពបរិសុទ្ធរបស់ស្ត្រីដែលមិនទាន់រៀបការត្រូវបានមនុស្សជាច្រើនចាត់ទុកថា ជាចំណងដែលមិនអាចកាត់ផ្តាច់បានពីសកម្មភាពនៃការបន្តថែរក្សា និងការពារវប្បធម៌ខ្មែរ ដោយការធានាឱ្យបាននូវកិត្យានុភាព និងកិត្តិយស របស់ស្ត្រីខ្មែរទាំងមូល។

# ការរំពឹងទុកពីវប្បធម៌ (បន្ត) ២/៧

សូម្បីតែ អ្នកចូលរួមវ័យចំណាស់ដែលមិនបានជំទាស់ដាច់ខាតចំពោះគំនិតនៃការរួមភេទមុនពេលរៀបការក៏ពួកគាត់នៅតែចាត់ទុកវាថាជាបញ្ហាដែលពាក់ព័ន្ធជាមួយ នឹង "ការបាត់បង់" នៃវប្បធម៌ខ្មែរផងដែរដូចការដកស្រង់ខាងក្រោមៈ

"ខ្ញុំគិតថា [ការរួមភេទមុនរៀបការ] មិនចាំបាច់ត្រូវតែចាត់ទុកថាជារឿងខុសនោះទេ ទោះយ៉ាងណាក៏ដោយ វាផ្ទុយនឹងទំនៀមទំលាប់ និងវប្បធម៌ខ្មែរយើង... យើងក៏ ត្រូវថែរក្សាវប្បធម៌ និងប្រពៃណីរបស់យើងដែរ... យើងមិនចង់ឱ្យបាត់បង់នូវគោលគំនិតរបស់ដូនតាយើងទេ។ វប្បធម៌ និងប្រពៃណី គឺជាអ្វីដែលធ្វើឱ្យបរទេសស្គាល់ ប្រទេសរបស់យើង។ ប្រសិនបើយើងបាត់បង់ទាំងអស់នេះ វាមិនល្អសម្រាប់ប្រទេសយើងនោះទេ...។" (O6M)

គំនិតដែលគិតថា ការការពារវប្បធម៌ និងភាពបរិសុទ្ធរបស់ ស្រ្តីត្រូវបានផ្សារភ្ជាប់គ្នាទៅវិញទៅមកនេះត្រូវបានឆ្លុះបញ្ចាំងមិនត្រឹមតែនៅក្នុងទំនៀមទម្លាប់ និងសុភាសិតប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានបង្ហាញនៅក្នុងគោលនយោបាយ និងច្បាប់នានារបស់រដ្ឋាភិបាលកម្ពុជាផងដែរ។ ឧទាហរណ៍ សេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈឆ្នាំ ២០២០ ដែលរួមបញ្ចូលការហាមប្រាមលើ ស្រ្តី និងបុរស ក្នុងការស្លៀកពាក់បង្ហាញ ឬ មើលឃើញថ្លុះសំលៀកបំពាក់ដែលមានចែងនៅក្នុងជំពូកមួយនៃច្បាប់នេះ ក្រោមចំណងជើង "ប្រពៃណី និងសេចក្តីថ្លៃថ្នូររបស់ជាតិ។" [១២]

យោងតាមគំហើញនៃការស្រាវជ្រាវ បានបង្ហាញថា វប្បធម៌ព្រហ្មចារីកំពុងត្រូវបានលើកយកមកតស៊ូមតិដោយអ្នកតស៊ូ មតិផ្នែកយេនឌ័រ និងក្រុមស្ត្រីវ័យក្មេងដែលមិនទាន់រៀបការ ហើយមានបុរសមួយចំនួនក៏ចូលរួមក្នុងការតស៊ូមតិនេះផងដែរ។

អ្នកចូលរួមទាំងនេះបានរៀបរាប់ដោយជឿជាក់ថា ស្ត្រីគួរតែត្រូវបានផ្តល់សេរីភាព និងភាពជាទីភ្នាក់ងារក្នុងការសម្រេចចិត្ត ថាតើពួកគេចង់រួមភេទមុនពេលរៀបការដែរ ឬអត់។ ឧទាហរណ៍ ការវែកញែកដែលលើកឡើងថា "ខ្ញុំមិនយល់ថា ហេតុអ្វីបានជាវប្បធម៌ខ្មែរឱ្យតម្លៃខ្លាំងម្លេះដល់ព្រហ្មចារី" (C2F) ឬ "ពួកគេមិនចង់ត្រូវបានគេមើលឃើញថា ជាអ្នកនាំភាពអាម៉ាស់ និងការអាប់អោនកិត្តិយស ដល់គ្រួសារនោះទេ ប៉ុន្តែតាមពិតទៅ បញ្ហាទាំងនោះមិនមានការជាប់ទាក់ទងគ្នាទេ។ នេះគ្រាន់តែជា វប្បធម៌មួយ ដែលសង្គមចូលចិត្តបន្ទោស ទៅលើស្រ្តី ហើយការអនុវត្តនេះពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងវប្បធម៌ស្តីបន្ទោសជនរងគ្រោះ" (C3F)

ដើម្បីស្វែងយល់ពីការពិភាក្សាអំពីភាពចម្រូងចម្រាសនេះ ការពិភាក្សាខាងក្រោមមានដកស្រង់សម្តី ចេញពីទិន្នន័យ ដែលបង្ហាញពីឥទ្ធិពលវប្បធម៌សំខាន់ៗមួយចំនួន ដែលបន្តផ្សព្វផ្សាយការរំពឹងទុកទៅលើភាពបរិសុទ្ធរបស់ស្រ្តី។ ឥទ្ធិពលវប្បធម៌ទាំងនេះ រួមមានការទូន្មាន បទដ្ឋានសង្គម និងទំនៀមទម្លាប់ប្រពៃណីអក្សរសិល្ប៍បុរាណ ព្រមទាំងសាសនាផងដែរ។

## ការទូន្មាន បទដ្ឋានសង្គម និងទំនៀមទម្លាប់ប្រពៃណី

បទដ្ឋាន និងទំនៀមទម្លាប់ប្រពៃណីខ្មែរ មួយចំនួនធំ ដែលមានប្រភពចេញមកពី ក្រមច្បាប់ស្រីដែលនិពន្ធដោយព្រះសង្ឃនៅក្នុងកំឡុងសតវត្សរ៍ទី ១៤ បាន ជះឥទ្ធិពលយ៉ាងខ្លាំងទៅ លើរបៀបនៃការចិញ្ចឹមបីបាច់ និងអប់រំក្មេងស្រី និងស្ត្រីខ្មែរ។ ក្រមច្បាប់ស្រីបានកំណត់នូវក្រមសីលធម៌ និងអាកប្បកិរិយា ដែលកំណត់សម្គាល់ថា នារីប្រភេទណាដែលអាចចាត់ទុកជា ស្ត្រីគ្រប់លក្ខណ៍។ ដូចគ្នាដែរ ក្រមច្បាប់ប្រុសបាកំណត់សម្គាល់អំពីបុគ្គលិកលក្ខណៈរបស់ប្រុសខ្មែរផងដែរ។

ស្រដៀងនឹងក្រមសីលធម៌ទាំងពីរនេះ ដែលបានកំណត់យ៉ាងជាក់លាក់អំពីអាកប្បកិរិយាប្រចាំថ្ងៃរបស់ស្ត្រី និងបុរសខ្មែររៀងៗខ្លួននោះ ក៏នៅមានការបង្រៀន និងសុភាសិតខ្មែរជាច្រើនទៀតដែលបានក្លាយទៅជាទំនៀមទម្លាប់ និងបទដ្ឋានសង្គម  និងបានបន្តពង្រឹងការរំពឹងទុកផ្នែកវប្បធម៌ទាក់ទងនឹងព្រហ្មចារី។ ដូចដែលអ្នកចូលរួមម្នាក់បានលើកឡើងថា "សង្គមយើងគិតថា ស្ត្រីគឺដូចជាសំពត់ក្នុងផ្នត់អញ្ចឹង ហើយការរក្សាព្រហ្មចារី គឺជាផ្នែកមួយនៃវប្បធម៌ខ្មែរ។" (Z26F)

បន្ថែមលើនេះ នៅមានការទទួលស្គាល់ជាទូទៅថា "បុរសប្រៀបដូចជាមាសទឹកដប់ ហើយស្ត្រីប្រៀបបាននឹងក្រណាត់ស" ពោលគឺមានន័យថា នៅពេលដែលមនុស្សស្រីត្រូវប្រឡាក់ដោយភក់មិនអាចជូតសម្អាតជ្រះបានឡើយដែលផ្ទុយពីបុរសដែលតែងតែអាចដុសខាត់កេរ្តិ៍ឈ្មោះរបស់ពួកគេឱ្យភ្លឺថែងចាំងវិញបានជានិច្ច។ យុវជនវ័យក្មេងម្នាក់បានលើកឡើងថា៖

"យើងអាចមើលឃើញថានៅក្នុងសង្គមខ្មែរយើងមានសុភាសិតមួយចំនួនដែលបង្ខំស្ត្រីឱ្យគោរពតាមវប្បធម៌ ដូចជា 'ស្ត្រីជាក្រណាត់សដែលមិនអាចលាងសម្អាតបានទេប្រសិនបើបានប្រឡាក់ភក់ហើយ'។ សុភាសិតនេះអាចជះឥទ្ធិពលឲ្យស្ត្រីរក្សាភាពបរិសុទ្ធរបស់ខ្លួន។" (Z25M)

ទិដ្ឋភាពនេះបង្ហាញយ៉ាងច្បាស់ថាបុរសទទួលបានបុព្វសិទ្ធិច្រើនជាងស្ត្រី ហើយមិនប្រឈមជាមួយផលវិបាកដូចមនុស្សស្រីនោះទេ ប្រសិនបើពួកគេជ្រើសរើសរួមភេទមុនពេលរៀបការ។ ការយល់ឃើញបែបនេះ ក៏ត្រូវរកឃើញផងដែរនៅក្នុងទិន្នន័យនៃការស្ទង់មតិ ដែលស្ទើរតែ ២/៣ នៃអ្នកឆ្លើយតបជឿថា បុរសមានសេរីភាពច្រើនជាងស្ត្រីក្នុងការជ្រើសរើសយកការរួមភេទមុនពេលរៀបការ (Figure 2)។

**គំនូសសម្គាល់ទី ២៖ តើបុរសមានសេរីភាពច្រើន នៅក្នុងការសម្រេចចិត្តថា តើគួររួមភេទមុនពេលរៀបការដែរឬទេ?**



បន្ថែមលើនេះ នៅក្នុងការផ្តល់ចម្លើយទាក់ទងនឹងសំនួរស្ទង់មតិ ដែលតម្រូវឲ្យអ្នកឆ្លើយតបធ្វើការកត់សម្គាល់ថា តើបុរស និងស្ត្រីខ្មែរមានភាពងាយស្រួលកម្រិតណាក្នុងការរួមភេទមុនរៀបការ? ជម្រើសចម្លើយ "ងាយស្រួលណាស់" ត្រូវបានជ្រើសចំនួន ២,៨៩៨ដង សម្រាប់បុរស ប៉ុន្តែត្រឹមតែ ១២១ដង ប៉ុណ្ណោះសម្រាប់ស្ត្រី៖

**កំណត់សម្គាល់ទី ៣៖ តើមានភាពងាយស្រួលប៉ុណ្ណាសម្រាប់បុរស និងស្ត្រីខ្មែរ ក្នុងការរួមភេទមុនរៀបការ?**







ដូច្នេះ ទិន្នន័យស្ទង់មតិបែបបរិមាណវិស័យទាំងនេះ ក៏បានគាំទ្រនូវគំនិតដែលថា បុរសទទួលរងការរឹតត្បឹតតិចជាងស្ត្រី ទាក់ទងនឹងការសម្រេចចិត្តពាក់ព័ន្ធនឹងការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍។ ចំណុចនេះនឹងត្រូវលើកយកមកពិភាក្សាឡើងវិញនៅក្នុងផ្នែកបន្ទាប់ (ផ្នែកទី ៥) ដែលពិនិត្យអំពីប្រភេទផ្សេងៗគ្នា និងកម្រិតខុសគ្នានៃផលវិបាកនានា សម្រាប់បុរស និងស្ត្រីខ្មែរ ដែលជ្រើសរើសការរួមភេទក្រៅអាពាហ៍ពិពាហ៍។

## អក្សរសិល្ប៍បុរាណ

ការបង្រៀនជុំវិញទំនៀមទម្លាប់វប្បធម៌ព្រហ្មចារីក៏ត្រូវបានបង្ហាញនៅក្នុងអក្សរសិល្ប៍ខ្មែរបុរាណផងដែរដែលត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃកម្មវិធីសិក្សាក្នុងប្រទេសកម្ពុជាទៀតផង។ អត្ថបទទាំងនោះ មិនត្រឹមតែអប់រំណែនាំសិស្ស ឱ្យចេះគិតគូរ និងគោរពគ្នាទៅវិញទៅមកប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានណែនាំសិស្សកុំឲ្យបាត់បង់ព្រហ្មចារីមុនពេល រៀបការផងដែរ។

អ្នកចូលរួមជាច្រើន បានលើកឡើងអំពីអក្សសិល្ប៍បែបប្រជាប្រិយរឿង "ទុំទាវ" ដែលជារឿងសោកនាដកម្មស្នេហា ដែលបង្ហាញអំពីប្រធានបទទាក់ទងនឹងអាកប្បកិរិយាដែលកូនស្រីគួរតែប្រកាន់ខ្ជាប់ និងអ្វីដែលជាការរំពឹងទុកជាទូទៅ ទៅលើស្ត្រីខ្មែរមុនពេលរៀបការ។

តួលេខនៃចំនួនសរុបមិនស្មើគ្នាដោយសារតែសំណួរនេះមានចម្លើយមួយចំនួនដែលអាចមានការឆ្លើយតបជាច្រើនដូចជា "ងាយស្រួលបន្តិច ប៉ុន្តែត្រូវរក្សាភាពស្ងៀមស្ងាត់ដោយសារតែការនិយាយដើម"។ ចម្លើយទាំងពីរដែលបានបង្ហាញត្រូវបានជ្រើសរើស និងដាក់បញ្ចូលគ្នាជាមួយគ្នា។

# ការរំពឹងទុកពីវប្បធម៌ (បន្ត) ៥/៧

យុវជនវ័យក្មេងម្នាក់បានឆ្លុះបញ្ចាំងអំពីការយល់ឃើញផ្ទាល់ខ្លួនជុំវិញរឿងទុំទាវថា៖

"ខ្ញុំគិតថាបញ្ហាព្រហ្មចារីក៏អាចធ្វើការឆ្លុះបញ្ចាំងតាមរយៈអក្សរសីល្ប៍ប្រជាប្រិយខ្មែរផងដែរ ឧទាហរណ៍នៅក្នុងរឿងទុំទាវ...តាមរយៈសកម្មភាពរបស់តួអង្គឯក ខ្ញុំគិតថាសាច់រឿងនេះព្យាយាមបង្ហាញថា ការរួមភេទមុនពេលរៀបការគឺជារឿងមិនត្រឹមត្រូវទេ។" *(Z25M)*

យុវជនវ័យក្មេងម្នាក់ទៀតបានលើកយករឿងទុំទាវជាឧទាហរណ៍នៃឥទ្ធិពលវប្បធម៌ដែលគាត់យល់ថាគួរតែត្រូវ បានពិនិត្យឱ្យស៊ីជម្រៅ ឬហ្មត់ចត់បន្ថែមទៀត ដើម្បីធ្វើឱ្យ សមភាពយេនឌ័រ និងស្វ័យភាពផ្លូវភេទរបស់ស្ត្រី ត្រូវបាន ទទួលស្គាល់នៅក្នុងប្រទេសកម្ពុជា។

"ខ្ញុំគិតថា [វប្បធម៌ព្រហ្មចារី] គឺមានតាំងពីសម័យបុរាណ។ ប្រសិនបើ យើងក្រឡេកមើលអក្សរសិល្ប៍ ដូចជា រឿងទុំទាវ ផ្នត់គំនិតរបស់យើងត្រូវបានផ្តោតទៅលើស្ត្រី និងរបៀបដែលស្ត្រីមិនអាចបាត់បង់ព្រហ្មចារី ប្រសិនបើ គាត់មិនទាន់រៀបការ។ នោះហើយគឺជាមូលហេតុ ដែល ផ្នត់គំនិតបែបនេះ ... នៅតែមានរហូតមកដល់សម័យបច្ចុប្បន្ន។

ពួកយើងត្រូវតែព្យាយាមពន្យល់...សារៈសំខាន់នៃសេរីភាពរបស់បុគ្គលម្នាក់ៗ...យើងគួរសង្កត់ធ្ងន់ថា បុរស និងស្ត្រីគឺដូចគ្នា...មិនគួរមានការដាក់សម្ពាធលើស្ត្រីច្រើនជាងបុរសនោះទេ... [ប៉ុន្តែនៅក្នុង] សង្គមខ្មែរ ដូចដែលយើងអាចឃើញនៅក្នុងរឿងទុំទាវ ស្ត្រីត្រូវតែនៅផ្ទះ។" (Z32M)

ជាចុងក្រោយ យុវជនវ័យក្មេងម្នាក់ទៀតបានពន្យល់ថា គាត់យល់ដឹងរាងទូលំទូលាយទៅលើ វប្បធម៌ព្រហ្មចារី និងបទដ្ឋានបែបប្រពៃណីទាក់ទងនឹងយេនឌ័រ។ ការយល់ដឹងនេះមានផ្នែកខ្លះតាមរយៈអក្សរសិល្ប៍ខ្មែរ៖

"តាមរយៈការរៀនអំពីអក្សរសីល្ប៍ខ្មែរ នៅកម្រឹតវិទ្យាល័យ ខ្ញុំយល់ឃើញថា ព្រហ្មចារីគឺពិតជាសំខាន់ខ្លាំងណាស់នៅក្នុងវប្បធម៌របស់យើង...ជាពិសេសសម្រាប់មនុស្សស្រី។ ស្ត្រីខ្មែរ ត្រូវតែបរិសុទ្ធ ចេះធ្វើម្ហូប និងចេះមើលថែស្វាមី និងក្រុមគ្រួសារ។ ពួកគេត្រូវតែធ្វើតាមប្រពៃណី វប្បធម៌ និងបំពេញកាតព្វកិច្ចនោះឱ្យបានល្អ។ នៅក្នុងកម្រិតជាក់លាក់មួយ ខ្ញុំគិតថា វាជាប្រការមួយក្នុងការការពារស្ត្រី។ ទោះយ៉ាងណាក៏ដោយ ពេលខ្លះការដាក់កម្រិតនេះ មិនមែនជាការការពារទេ ប៉ុន្តែជាការគាបសង្កត់ទៅលើស្ត្រីទៅវិញទេ។" *(Z30M)*

ប្រធានបទទាក់ទងនឹង 'ភាពបរិសុទ្ធ' របស់ស្ត្រីត្រូវបានផ្សារភ្ជាប់ទៅនឹង 'កាតព្វកិច្ច' សង្គម និងសហគមន៍របស់ពួកគេ ត្រូវបានលើកឡើងជាច្រើនដង នៅក្នុងការឆ្លើយតបជាច្រើន និងបានបង្ហាញអំពីស្ថានភាពនៃវប្បធម៌ព្រហ្មចារីនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ។ នៅក្នុងឧទាហរណ៍បន្ទាប់ យុវជនវ័យក្មេងម្នាក់ទៀតបានពង្រីកប្រធានបទទាំងនេះបន្ថែមទៀត ដោយបានដាក់ភាពបរិសុទ្ធរបស់ស្ត្រីឱ្យស្មើជាមួយនឹង "លក្ខណៈសម្បត្តិល្អត្រឹមត្រូវ" របស់ពួកគេ និងការរក្សាខ្លួនឱ្យនៅក្នុង 'ស្ថានភាពល្អ'៖

"ចំពោះវប្បធម៌ខ្មែរ *[ការរួមភេទមុនពេលរៀបការ]* ត្រូវបានហាមប្រាមយ៉ាងតឹងរ៉ឹង ដោយសារតែ យើងត្រូវគោរពតាមប្រពៃណីដែលប្រកបដោយការដាក់ខ្លួន និងចរិតល្អត្រឹមត្រូវ។ ដូច្នេះហើយ ទើបពួកគេយកចិត្តទុកដាក់លើរឿងព្រហ្មចារី ដើម្បីរក្សាខ្លួនប្រាណមនុស្សស្រីឱ្យស្ថិតក្នុងស្ថានភាពដ៏ល្អបំផុតមួយ... សម្រាប់ខ្ញុំដែលជាអ្នកមានផ្នត់គំនិតបែបប្រពៃណី... ខ្ញុំគិតថាការថែរក្សាព្រហ្មចារីជាការនាំមកនូវកិត្តិយសដល់គ្រួសារ... ការដែលស្ត្រីអាចថែរក្សា ព្រហ្មចារីបានគឺជាការបង្ហាញគុណតម្លៃពិតប្រាកដរបស់ខ្មែរទៅបរទេស ដែលមិនប្រព្រឹត្តផ្ទុយពីប្រពៃណី។" (Z33M)

សញ្ញាណនៃ ភាពសុភាពរាបសារ ភាពល្អឥតខ្ចោះ និង ភាពបរិសុទ្ធទាំងនេះ ត្រូវបានចងភ្ជាប់ជាមួយនឹងស្ថានភាពផ្លូវភេទរបស់ស្ត្រីដែលចង្អុលបង្ហាញពីមូលហេតុដែលនាំឲ្យស្ត្រីត្រូវប្រឈមមុខនឹងផលវិបាក ខាងសីលធម៌ និងទទួលរងភាពអាម៉ាស់ នៅពេលដែល ពួកគេរួមភេទមុនពេលរៀបការ។ ចំណុចនេះនឹងត្រូវ លើកមកពិភាក្សាលម្អិតនៅក្នុងផ្នែកទី ៥ នៃការសិក្សានេះ។

ប្រធានបទដ៏គួរឱ្យចាប់អារម្មណ៍ និងត្រូវបានលើកឡើងដដែលៗ នៅក្នុងសម្រង់ខាងលើគឺ ទស្សនៈនៃការបន្ត 'រារាំង' មិនឱ្យស្ត្រីដែលមិនទាន់រៀបការពីការប្រឡូកក្នុងជីវភាពផ្លូវភេទ គឺជាការអនុវត្តមួយដើម្បីបង្ហាញទៅកាន់បរទេសថា វប្បធម៌ខ្មែរនៅរស់រានមានជីវិតយ៉ាងល្អ។ ស្ត្រីវ័យចំណាស់ម្នាក់បានអះអាងថា៖

"...ព្រហ្មចារី ត្រូវបានអនុវត្តតាំងពីសម័យបុរាណមកម្ល៉េះ... នៅកម្ពុជា... ការរក្សាព្រហ្មចារីក៏ជាផ្នែកមួយក្នុងការតំណាងឱ្យប្រពៃណី និងវប្បធម៌របស់យើងផងដែរ... ប្រសិនបើជនបរទេសសិក្សាអំពីវប្បធម៌របស់យើង និងយល់ពីវប្បធម៌របស់យើង ពួកគេនឹងផ្តល់តម្លៃកាន់តែខ្លាំងលើរបៀបដែលយើងថែរក្សាប្រពៃណីរបស់យើង។" (*O11F*)

ការលើកឡើងនេះឆ្លើយតបទៅនឹង អំណះអំណាងរបស់ Jacobsen ថា "ប្រពៃណីពីអតីតកាល ឬ ការអនុវត្តន៍ទាំងឡាយដែលឆ្លុះបញ្ចាំងពីសង្គមកម្ពុជាថាគ្មានការជ្រៀតជ្រែកពីវប្បធម៌ខាងក្រៅ មានភាពទាក់ទងគ្នាយ៉ាងធំធេងនៅក្នុងសង្គមកម្ពុជាសម័យទំនើប។" [១៣]

Jacobsen ហៅអំណះអំណាងនេះថា 'អាចយល់បាន' ដោយសារតែវប្បធម៌ខ្មែរបានទទួលរងនូវការប៉ះពាល់យ៉ាងខ្លាំងនៅក្នុងកំឡុងសតវត្សរ៍ទី ២០ពីសំណាក់របបអាណានិគមនិយមបារាំង របបខ្មែរក្រហម និងការត្រួតត្រារបស់ប្រទេសវៀតណាម ដែលពេលនោះ "ប្រទេសវៀតណាម... បានព្យាយាមយ៉ាងខ្លាំង ក្នុងការបញ្ជ្រាបវប្បធម៌ និងប្រជាពលរដ្ឋវៀតណាមនៅប្រទេសខ្មែរ។" Jacobsen ក៏បានអះអាងផងដែរថា ចាប់តាំងពីឆ្នាំ ១៩៩៣ មក "ប្រជាពលរដ្ឋកម្ពុជាបានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគំរូ និងឧត្តមគតិ ដែលត្រូវតែស្វែងរក និងធ្វើឱ្យរស់ឡើងវិញនូវ 'ភាពបរិសុទ្ធ' ដែលជាផ្នែកមួយដ៏សំខាន់នៅក្នុងវប្បធម៌កម្ពុជា។"

បទវិភាគខាងលើនេះ បានផ្តល់នូវការយល់ដឹងបន្ថែមអំពីមូលហេតុដែលអ្នកចូលរួមមួយចំនួន បង្ហាញការបារម្ភអំពីការបាត់បង់វប្បធម៌ខ្មែរនាពេលខាងមុខ និងផ្តល់នូវហេតុផលដែលអ្នកចូលរួមមួយចំនួនទៀតគិតថាជាការចាំបាច់ដែលត្រូវ 'បង្ហាញ' ដល់ជនបរទេសទាក់ទងនឹងភាពរឹងមាំនៃវប្បធម៌ខ្មែរ។

## សាសនា

ព្រះពុទ្ធសាសនា ត្រូវបានទទួលស្គាល់ថាជាសាសនារបស់រដ្ឋនៅក្នុងប្រទេសកម្ពុជា ហើយប្រជាពលរដ្ឋកម្ពុជាប្រមាណ ៩៥% បានកំណត់អត្តសញ្ញាណថាជាពុទ្ធសាសនិកជន [14]។ ជាការពិត បាវចនាជាតិ នៃព្រះរាជាណាចក្រកម្ពុជា គឺ 'ជាតិ សាសនា ព្រះមហាក្សត្រ' ទិដ្ឋភាពនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃការបដិបត្តិគោលការណ៍នៃព្រះពុទ្ធសាសនានៅក្នុងជីវភាពប្រចាំថ្ងៃខាងផ្នែកវប្បធម៌ និងសង្គមនៅកម្ពុជា។

យោងតាមទស្សនៈព្រះពុទ្ធសាសនាបែបថេរវាទដែលបាននឹងកំពុងតែបដិបត្តិសព្វថ្ងៃនេះ ការរួមភេទក្រៅអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាជាទង្វើមិនសមរម្យទាំងសម្រាប់មនុស្សប្រុស និងមនុស្សស្ត្រីផងដែរ។ យ៉ាងណាមិញ យោងតាមរបកគំហើញនៅក្នុងការសិក្សាបែបគុណវិស័យរបស់ អង្គការក្លាហាននាពេល ថ្មីៗនេះ គ្រហស្ថ និងអ្នកបដិបត្តិសាសនាមួយចំនួនបានចាត់ទុកថា ការរួមភេទមុនរៀបការ គឺជាការបំពានផ្នែកធម៌វិន័យនៅក្នុងកម្រិតស្រាល និងមិនសូវធ្ងន់ធ្ងរដូចការប្រព្រឹត្តអំពើផិតក្បត់នោះទេ។

អ្នកផ្តល់បទសម្ភាសជាច្រើនបានលើកឡើងអំពីកត្តាសាសនា។ យុវតីវ័យក្មេងម្នាក់បានពន្យល់ថា៖ "យោងតាមប្រពៃណីមនុស្ស ស្រីត្រូវតែរក្សាព្រហ្មចារី រហូតដល់ពេលរៀបការ។ នេះជាការអនុវត្តន៍តាមផ្នត់គំនិតបុរាណជាពិសេសចំពោះអ្នកដែលកាន់សាសនា។" (Z44F)

បន្ថែមពីលើការបដិបត្តិតាមព្រះពុទ្ធសាសនា នៅកម្ពុជាក៏មានសហគមន៍ឥស្លាមធំល្មមផងដែរ។ អ្នកផ្តល់បទសម្ភាសបានរៀបរាប់អំពីភាពច្បាស់លាស់ និងតឹងរ៉ឹង នៅក្នុងច្បាប់សាសនាឥស្លាមថាបានហាមឃាត់ការរួមភេទមុនរៀបការ។ យុវជនមួយរូបបានបញ្ជាក់ថា៖

"...ប្រសិនបើគាត់ជាស្ត្រីខ្មែរ និងជាជនជាតិខ្មែរឥស្លាម ហើយបានរួមភេទមុនរៀបការនោះ សកម្មភាពនេះរបស់គាត់គឺពិតជាខុសខ្លាំងណាស់ ព្រោះជាការប្រព្រឹត្តផ្ទុយទៅនិងច្បាប់សាសនា ហើយសកម្មភាពនេះចាំបាច់ត្រូវតែបញ្ឈប់។" (*Z43M*)

ជាសេចសរុបនៅក្នុងផ្នែកនេះ យើងអាចសន្និដ្ឋានថា ការរំពឹងទុកផ្នែកវប្បធម៌នៅតែមានឥទ្ធិពលខ្លាំងនៅក្នុងការជម្រុញ និងរារាំងស្ត្រីមិនឲ្យប្រទ្បុកជាមួយការរួមភេទមុនរៀបការ។ សំណួរទាក់ទងនឹងវប្បធម៌ និងការអភិរក្សវប្បធម៌ ត្រូវបានសាកសួរទៅកាន់អ្នកផ្តល់បទសម្ភាសន៍គ្រប់វ័យ ដើម្បីស្វែងយល់អំពីទំនាក់ទំនងនៃគោលការណ៍នៃការមិនប្រទ្បូកក្នុងការរួមភេទមុនរៀបការសព្វថ្ងៃ។

អ្នកផ្តល់សម្ភាសដែលជាព្រះសង្ឃមួយអង្គមានសង្ឃដីកាបង្ហាញអំពីទស្សនៈយល់ឃើញរបស់ ព្រះអង្គចំពោះវប្បធម៌ព្រហ្មចារី និងវប្បធម៌ខ្មែរថា អាចច្របាច់បញ្ចូលគ្នាបាន៖

"ការរក្សាព្រហ្មចារី គឺជាអ្វីដែលប្រជាពលរដ្ឋកម្ពុជាបានអនុវត្តតាំងពីយូរយារណាស់មកហើយ...ទង្វើនេះគឺជាកត្តាសំខាន់ដែលបង្កើតទៅជាផ្នែកមួយនៃវប្បធម៌ខ្មែរ។" (*Z6Monk*)

ការលើកឡើងនេះបានឆ្លុះបញ្ចាំងអំពីទស្សនៈរួម ដែលបានពិភាក្សា និងរបកគំហើញ ដែលបង្ហាញថាសូម្បីតែយុវជនកម្ពុជាសព្វថ្ងៃក៏នៅតែយល់ថា វប្បធម៌ខ្មែរពិតជាឱ្យតម្លៃខ្ពស់ទៅលើព្រហ្មចារីរបស់ស្ត្រី ហើយការឱ្យតម្លៃនេះបានជះឥទ្ធិពលទៅលើការរំពឹងទុករបស់សង្គមចំពោះស្ត្រីមិនទាន់រៀបការនាពេលបច្ចុប្បន្ននេះ។

## ៤.២ ការរំពឹងទុកពីគ្រួសារ

"នៅក្នុងសង្គមកម្ពុជា ការរំពឹងទុករបស់ក្រុមគ្រួសារទៅលើកូនស្រីគឺ មនុស្សស្រីត្រូវតែស្អាតបាត បរិសុទ្ធ ឬ ដូចជាក្រដាសស។ ប្រសិនបើមិនដូចការដែលបានរំពឹងទុកទេ មានន័យថាកូនស្រីនោះ មិនមែនជាមនុស្សស្រីដែលល្អសម្រាប់គ្រួសារទេ។" ( Z35M )

នៅក្នុងផ្នែកមុន បានពិភាក្សាខ្លះៗអំពីការដែលរចនាសម្ព័ន្ធ និងទំនាក់ទំនងគ្រួសារនៅក្នុងសង្គមខ្មែរ ដែលបានចូលរួមចំណែកក្នុងការរំលេចនូវការរំពឹងទុកយ៉ាងតឹងរ៉ឹងទាំងនេះ ទៅលើការរក្សាភាពបរិសុទ្ធរបស់នារីវ័យក្មេង។ ការរំពឹងទុកទាំងនេះ បានអន្តរប្រសព្វ និងត្រូវបានទទួលរងឥទ្ធិពលពីបទដ្ឋានវប្បធម៌ និងទំនៀមទម្លាប់។

ជាឧទាហរណ៍ Kent ពន្យល់ថា ក្រមច្បាប់ស្រីបង្ហាញពីគុណលក្ខណៈរបស់ស្ត្រីខ្មែរថា "មានគុណធម៌ និងលះបង់សម្រាប់សុខុមាលភាពគ្រួសារ និងសង្គមរបស់ខ្លួន" [១៥]។ គុណធម៌របស់ស្ត្រីខ្មែរ ជាពិសេសពាក់ព័ន្ធនឹងរឿងផ្លូវភេទ "នៅតែសំខាន់សម្រាប់ខ្លួននាងផ្ទាល់ និង...សាច់ញាតិរបស់នាង។"

### គំនូសសម្គាល់ទី ៤

**តើអ្នកគិតថាឪពុកម្តាយក្នុងសង្គមខ្មែរ មានការបារម្ភដូចគ្នាដែរឬទេ ចំពោះកូនប្រុស និងកូនស្រីរបស់ពួកគេដែលអាយុពី ១៥ ដល់១៨ឆ្នាំរួមភេទមុនរៀបការ?**




ការឆ្លើយតបសរុប = ៣៦៥៧ ។ កត់សម្គាល់ថា គ្មានការតម្រូវឲ្យអ្នកចូលរួមឆ្លើយត្រូវតែឆ្លើយតបគ្រប់សំណួរនោះទេ ដូច្នេះហើយ មានអ្នកឆ្លើយសំណួរប្រហែល ៤០ នាក់ បានរំលងសំណួរនេះ។

# ការរំពឹងទុកពីគ្រួសារ (បន្ត) ២/៦

Nishigaya ក៏បានពិភាក្សាអំពីចំណុចទាំងនេះ នៅក្នុងការសិក្សាឆ្នាំ២០១០របស់គាត់ថា៖ "កូនស្រីត្រូវបានគេរំពឹងថាត្រូវនៅជិតឪពុកម្តាយរបស់ពួកគេ ដើម្បីធ្វើខ្លួនឱ្យសមជាមនុស្សស្រីដែលមានគុណធម៌។ ស្ត្រីមានគុណធម៌បម្រើ និងគោរពស្វាមី ដឹងគុណមាតាបិតា ចេះថែទាំកូន និងមានភាពសុភាពរាបសារ ទាំងរៀបចំខ្លួន និងប្រើប្រាស់ពាក្យសម្តី [១៦]។"

មានអ្នកឆ្លើយតបគ្រប់វ័យជាច្រើននាក់ បានបញ្ជាក់ថា ការរក្សាព្រហ្មចារីរបស់ស្ត្រីវ័យក្មេង គឺជាកាតព្វកិច្ច ឬការទទួលខុសត្រូវរបស់ពួកគេចំពោះគ្រួសារ។ ដូចដែលអ្នកចូលរួមម្នាក់បានលើកឡើងថា៖ "ព្រហ្មចារីសម្រាប់មនុស្សស្រី មិនមែនសម្រាប់តម្លៃបុគ្គលផ្ទាល់ខ្លួននោះទេ ប៉ុន្តែតំណាងឱ្យតម្លៃនៃក្រុមគ្រួសាររបស់នាង កេរ្តិ៍ឈ្មោះ និងភាពថ្លៃថ្នូរនៅក្នុងសង្គមផងដែរ។" (O12F)

អ្នកឆ្លើយតបសម្ភាសជាច្រើនបានបញ្ជាក់ថា ការខកខានក្នុងការប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវនេះ មិនត្រឹមតែធ្វើឱ្យអាម៉ាស់ និងបាត់បង់កិត្តិយសផ្ទាល់ខ្លួនរបស់ស្ត្រីតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងអំពីការប៉ះពាល់យ៉ាងខ្លាំងដល់សាច់ញាតិផ្សេងទៀតផងដែរ។ អ្នកឆ្លើយតបជាច្រើនបានលើកឡើងនូវប្រយោគមួយឃ្លាថា "មានកូនស្រីមួយ ប្រៀបបាននឹងមានប្រហុកមួយក្រឡ" ក្នុងន័យនេះគឺចង់សំដៅថា នៅពេលបើកក្រឡប្រហុកអ្នកជិតខាងនឹងធំក្លិនស្អុយ (Z25M) ។ ចំពោះបុរសវិញ មិនការលើកឡើងណាមួយដែលដាក់សម្ពាធដល់ពួកគេឡើយ៖

"សម្រាប់បុរស សង្គមយើងមិនបានបន្ទោសបង្អាប់ ធ្វើការមាក់ងាយមនុស្សប្រុសដែលរួមភេទជាមួយមនុស្សស្រីទេ។ គ្រួសាររបស់គាត់មិនខ្វល់ថាកូនប្រុសនៅមានព្រហ្មចារីឬអត់នោះទេ។" (Z20F)

ការរំពឹងទុកយ៉ាងមុតមាំទាំងនេះ ទៅលើការមិនប្រឡូកក្នុងជីវភាពផ្លូវភេទមុនរៀបការរបស់ស្ត្រីបានកើតឡើងដោយសារតែផលវិបាកនានា ដែលនឹងកើតមានចំពោះគ្រួសារ នៅពេលដែលកូនស្រីត្រូវបានគេដឹងថាបានរួមភេទមុនរៀបការ៖ **"មនុស្សស្រីដែលរួមភេទមុនរៀបការបាននាំមកនូវភាពអាម៉ាស់យ៉ាងខ្លាំងសម្រាប់គ្រួសារនៅពេលដែលមានគេដឹងឭរឿងនេះ ហើយក៏បានបង្កការលំបាកដល់គ្រួសារនៅក្នុងទំនាក់ទំនងសង្គមផងដែរ។"** (Z6Monk)

ផ្ទុយទៅវិញ កូនស្រីណាដែលសុភាពរាបសារ នឹងមិនប្រឡូកក្នុងជីវភាពផ្លូវភេទមុនរៀបការត្រូវបានចាត់ទុកថា នាងបានរក្សាកិត្តិយសគ្រួសារទាំងមូល ដូចដែលយុវតីម្នាក់បានបញ្ជាក់យ៉ាងច្បាស់ថា៖

**"ខ្ញុំគិតថា សម្រាប់មនុស្សស្រី ការរក្សាព្រហ្មចារីរហូតដល់ពេលរៀបការពិតជាសំខាន់ណាស់... ប្រសិនបើមនុស្សស្រីអាចរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ នេះបង្ហាញពីមោទនភាព និងសេចក្តីថ្លៃថ្នូររបស់គ្រួសារ... ព្រហ្មចារីរបស់កូនស្រីពិតជាសំខាន់សម្រាប់គ្រួសារនីមួយៗ ព្រោះថាមិនត្រឹមតែកិត្តិយសគ្រួសារនោះទេ សេចក្តីថ្លៃថ្នូរនៃគ្រួសារ ក៏ឆ្លុះបញ្ចាំងតាមរយៈការរក្សាព្រហ្មចារីរបស់កូនស្រីផងដែរ។" (Z47F)**

# ការរំពឹងទុកពីគ្រួសារ (បន្ត) ៣/៦

ចំណុចនេះត្រូវបានលើកឡើងដោយ អ្នកចូលរួមជាស្ត្រីវ័យចំណាស់ម្នាក់ដែរ គាត់បានលើកឡើងអំពីគោលការណ៍សីលធម៌ ដោយកំណត់ថាស្ត្រីដែលអាចរក្សាព្រហ្មចារីបានគឺជាស្ត្រីដែលមានចរិយាមាយាទល្អ ក្នុងករណីនេះ នៅក្នុងន័យនេះមានន័យស្ត្រីរូបនោះមានការគោរពចំពោះឪពុកម្តាយផងដែរ៖

"ប្រសិនបើក្មេងស្រី ឬស្ត្រី អាចរក្សាព្រហ្មចារីដល់ពេលរៀបការនោះគឺជាការឆ្លុះបញ្ចាំងពីអាកប្បកិរិយាល្អ ការចេះគិតគូរវែងឆ្ងាយ និងចេះគោរពចំពោះឪពុកម្តាយរបស់ពួកគេ។ មានន័យថា ពួកគេបានធ្វើតាមការទូន្មានរបស់ឪពុកម្តាយរបស់ពួកគេ។" (O6F)

ទាក់ទងនឹងភាពខុសគ្នានៃទិន្នន័យសម្ភាសន៍ផ្អែកលើជំនាន់ យុវជនជាច្រើនមានអារម្មណ៍ថា ការមានសម្ពាធជាច្រើនជុំវិញរឿងព្រហ្មចារីគឺមានប្រភពមកពី "មនុស្សជំនាន់មុនៗ"៖

"ការរំពឹងទុកគឺភាគច្រើនបានមកពីមនុស្សចាស់ ដូចជាពីក្រុមគ្រួសារជាដើម។ អ៊ំ ពូ មីង នៅក្នុងក្រុមគ្រួសារ គិតថាការរួមភេទមុនរៀបការ អាចធ្វើឱ្យកេរ្តិ៍ឈ្មោះគ្រួសារអាប់អោន។" (Z28M)

ទោះជាយ៉ាងណា របកគំហើយសំខាន់ដែលកត់សម្គាល់ក្នុងចំណុចនេះគឺមានការឆ្លើយតបយ៉ាងច្រើនពីអ្នកចូលរួមវ័យក្មេង [ទាំងស្ត្រី និងបុរស] បង្ហាញពីការយល់ស្របរបស់ពួកគេជាមួយនឹងបទដ្ឋានព្រហ្មចារី៖

"ការរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ គឺជារឿងសំខាន់សម្រាប់មនុស្សស្រី ដោយសារតែវាជួយការពារកិត្តិយសផ្ទាល់ខ្លួន និងក្រុមគ្រួសារ...ស្ត្រីហាក់ដូចបន្ទាបតម្លៃខ្លួនឯងបើពួកគេរួមភេទមុនពេលរៀបការ។" (Z33M)

អ្នកចូលរួមមួយចំនួនតូច រាប់បញ្ចូលទាំងបុគ្គលិកអង្គការសង្គមស៊ីវិល ដែលធ្វើការទាក់ទងនិងការលើកកម្ពស់សមភាពយេនឌ័រ បានជំទាស់យ៉ាងខ្លាំងទៅលើការសន្មត់របស់សង្គមដែលថា កូនស្រីគួរតែនៅមានព្រហ្មចារីដល់ពេលរៀបការ។

ខណៈពេលដែលអ្នកឆ្លើយតបមកពីអង្គការសង្គមស៊ីវិលទាំងនេះ បានយល់ស្របជាមួយនឹងការសន្មត់ថា ការរំពឹងទុករបស់គ្រួសារចំពោះព្រហ្មចារីកូនស្រី ត្រូវបានប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹង ពួកគេក៏បានធ្វើការវែកញែកបន្ថែមទៅលើការវិភាគរបស់ពួកគេអំពីបញ្ហាទាំងនេះ ដូចដែលឧទាហរណ៍ខាងក្រោមបង្ហាញថា៖

**"ផ្អែកលើបទពិសោធន៍របស់ខ្ញុំ ដែលធ្វើការជាមួយយុវជននៅកម្រិតមូលដ្ឋាន ឪពុកម្តាយភាគច្រើនបង្ខំកូនរបស់ពួកគេឱ្យធ្វើតាមវប្បធម៌ព្រហ្មចារី ដើម្បីរក្សាកិត្តិយសគ្រួសារ និងដើម្បីកុំឱ្យគ្រួសារទទួលរងនូវភាពអាម៉ាស់ជាសាធារណៈ។ ពួកគេធ្វើបែបនេះដោយមិនបានដឹងថាពួកគេកំពុងតែរឹតត្បិតសិទ្ធិ និងបង្កភាពគ្រោះថ្នាក់លើកូនស្រីពួកគេនោះទេ។ ខ្ញុំគិតថានេះមកពីការខ្វះការអប់រំ និងលទ្ធភាពទទួលបានព័ត៌មាននៅមានកម្រិត។" *(C4F)***

## គំនូសសម្គាល់ទី ៥

### តើអ្នកគិតថាអ្នកណា ដែលជាអ្នកដាក់សម្ពាធដល់ស្ត្រីវ័យក្មេងឱ្យថែរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ?




ការឆ្លើយតបសរុបគឺច្រើនជាងនេះ ដោយសារអ្នកឆ្លើយអាចជ្រើសរើសចម្លើយបានច្រើនតាមដែលពួកគេមានអារម្មណ៍ថាត្រូវបានអនុវត្ត។

## គំនូសសម្គាល់ទី៦

**តើអ្នកគិតថាអ្នកណា ដែលជាអ្នកដាក់សម្ពាធដល់បុរសវ័យក្មេងឱ្យថែរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ?**




ការឆ្លើយតបសរុបគឺច្រើនជាងនេះ ដោយសារអ្នកឆ្លើយអាចជ្រើសរើសចម្លើយបានច្រើនតាមដែលពួកគេមានអារម្មណ៍ថាត្រូវបានអនុវត្ត។

# ការរំពឹងទុកពីគ្រួសារ (បន្ត) ៦/៦

គំនិតទាក់ទងនឹងការត្រួតត្រាលើកូនប្រុស កូនស្រីដែល 'បង្កគ្រោះថ្នាក់' ដល់ស្ត្រីក៏ត្រូវបានលើកឡើងដោយអ្នកឆ្លើយតបសម្ភាសមកពីអង្គការសង្គមស៊ីវិលផងដែរ។ ឧទាហរណ៍ខាងក្រោមបញ្ជាក់ និងបង្ហាញអំពីការដាក់សម្ពាធ ស្មើទៅនឹងការគាបសង្កត់ និងការបង្ខិតបង្ខំផងដែរ៖

"ស្ត្រី (ម្ដាយ បងប្អូនស្រី និងជីដូន) សុទ្ធសឹងតែជាអ្នកធ្វើការសង្កត់ខ្លាំងជាងគេ ក្នុងការដាក់សម្ពាធលើក្មេងស្រីឱ្យគោរពតាមវប្បធម៌ព្រហ្មចារី។ នៅពេលដែលកូនស្រី មិនបានប្រព្រឹត្តតាមបទដ្ឋានទាំងនេះ គ្រួសារ និងសង្គម នឹងដាក់ការស្ដីបន្ទោសទៅលើស្ត្រីជាម្ដាយ។ ដូច្នេះដើម្បី...ទទួលបានការគោរពនៅក្នុងសង្គម ម្ដាយត្រូវបង្ខំកូនស្រីឱ្យធ្វើតាមបទដ្ឋានទាំងនេះ។" (C5F)

បន្ថែមលើនេះ ការរក្សាព្រហ្មចារីរបស់ស្ត្រីមិនទាន់រៀបការក៏ជាការរំពឹងទុកដ៏ធំបំផុតរបស់គ្រួសារផងដែរ (នៅក្នុងកម្រិតមួយដែលអ្នកឆ្លើយតបម្នាក់ពោលថា ស្ត្រីដែលរួមភេទមុនរៀបការប្រឈមមុខនឹងការ "ត្រូវបានបណ្ដេញចេញពីផ្ទះដោយគ្រួសាររបស់ពួកគេ" (Z38M) អ្នកឆ្លើយតបសម្ភាសជាច្រើនបានរៀបរាប់ថា ការរក្សាព្រហ្មចារីរបស់ស្ត្រីក៏សំខាន់ខ្លាំងណាស់ដែរ សម្រាប់ក្រុមគ្រួសារអនាគតស្វាមីរបស់គាត់៖

**"ខ្ញុំគិតថា ការរក្សាព្រហ្មចារីរបស់ស្ត្រីរហូតដល់ពេលរៀបការ គឺពិតជាមានសារៈសំខាន់ និងល្អបំផុតសម្រាប់អនាគតរបស់ពួកគេ ដោយសារតែ ពួកគេនឹងត្រូវបានឱ្យតម្លៃពីសំណាក់គ្រួសារ និងស្វាមីរបស់ពួកគេ...**

**សង្គមតែងតែធ្វើការវាយតម្លៃអវិជ្ជមានទៅលើស្ត្រីដែលបាត់បង់ព្រហ្មចារី ថាជាមនុស្សស្រីមិនល្អ ដែលពិតជាប៉ះពាល់យ៉ាងខ្លាំងទៅលើគ្រួសារខាងបុរស ប្រសិនបើគាត់ស្រឡាញ់នារីម្នាក់នោះ ពីព្រោះគ្រួសារខាងប្រុសនឹងមិនទទួលយកនារីម្នាក់នោះទេ។" (*Z40M*)**

សម្រង់នេះ គួរឱ្យចាប់អារម្មណ៍ដោយសារតែបានបង្ហាញ ពីការយល់ឃើញទៅលើ ស្ត្រីដែលបានប្រើប្រាស់នូវស្វ័យភាពផ្លូវភេទនិងការសម្រេចចិត្តទៅលើរាងកាយនាង តែបែជាត្រូវបានមើលឃើញថាបង្កការ 'ប៉ះពាល់' ដល់អ្នកដទៃដែលគាត់មិនទាំងស្គាល់ច្បាស់ផង ដោយសារតែ កង្វះនូវឆន្ទៈរបស់ពួកគេក្នុងការ 'ទទួលយកនាង'។ ចំណុចនេះបង្ហាញអំពីទិដ្ឋភាពស្មុគ្រស្មាញមួយជុំវិញ បញ្ហាព្រហ្មចារី នៅក្នុងបរិបទគ្រួសារនៅកម្ពុជា។ ចំពោះគំនិតដែលយល់ឃើញថា ស្ត្រីនឹងមិនត្រូវបានផ្ដល់តម្លៃពីស្វាមី បើសិនជាពួកគេមិនអាចរក្សាព្រហ្មចារី នឹងត្រូវបកស្រាយបន្ថែមទៀតនៅក្នុងផ្នែក ៥.៣ ដែលសិក្សាទៅលើ ផលវិបាកនៃការរួមភេទមុនរៀបការ ទាក់ទិននឹងជីវិតអាពាហ៍ពិពាហ៍។

# ៤.៣ ការរំពឹងទុកពីសង្គម

"បើនរណាម្នាក់ហ៊ានអនុវត្តខ្លួនមិនស្របតាមបទដ្ឋានដែលកំណត់ដោយសង្គម ពួកគេនឹងត្រូវបានអ្នកនៅក្នុងសហគមន៍ដាក់នាមថាមិនល្អ និងមាក់ងាយ ។" (*C5F*)

"ព្រហ្មចារី បង្ហាញពីភាពបរិសុទ្ធ កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រី ដែលមនុស្សស្រីម្នាក់ៗត្រូវតែមាន និងយកចិត្តទុកដាក់ខ្ពស់ បើមិនដូច្នោះទេ ពួកគេអាចបាត់បង់តម្លៃរបស់ខ្លួន ហើយបន្ទាប់មក នឹងទទួលការវិនិច្ឆ័យអវិជ្ជមានពីសង្គម។" (*Z38M*)

បន្ទាប់ពីស្វែងយល់រួចមកហើយអំពីការរំពឹងទុកផ្នែកវប្បធម៌ និងគ្រួសារ ទៅលើបញ្ហាព្រហ្មចារី ផ្នែកចុងក្រោយនេះនឹងពិភាក្សាអំពីការរំពឹងទុកដ៏ទូលំទូលាយក្នុងកម្រិតសហគមន៍ និងសង្គមកម្ពុជាទាំងមូល។ ជាញឹកញយ អ្នកឆ្លើយតបបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ នៃការថែរក្សាព្រហ្មចារីរបស់ស្ត្រីមិនទាន់រៀបការ ដោយអះអាងថាស្ត្រីត្រូវតែអនុវត្តឱ្យបាន ដើម្បីរក្សា 'តម្លៃ' នៃភាពជាស្ត្រីដែលត្រូវបានសន្មត់ដោយក្នុងសង្គម។

ទិន្នន័យដែលទទួលបានពីការសម្ភាសន៍ បង្ហាញពីការលំបាក ក្នុងការបែងចែកឱ្យដាច់ស្រលះ ថាតើអ្នកតបសម្ភាសដែលបានអះអាងថា ព្រហ្មចារីមានសារៈសំខាន់ខ្លាំងនោះ គឺជាការបង្ហាញពីទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ ឬគ្រាន់តែបង្ហាញអំពីការយល់ឃើញរបស់ពួកគេ ទាក់ទងនឹងប្រធានបទនេះ នៅក្នុងបរិបទកម្ពុជានាពេលបច្ចុប្បន្ន។

## គំនូសសម្គាល់ទី៧

### តើប្រយោគខាងក្រោមនេះត្រឹមត្រូវដែរទេ៖ បុរសមានសេរីភាពច្រើនក្នុងការសម្រេចចិត្តថា តើត្រូវរួមភេទមុនពេលរៀបការឬក៏អត់?




ការឆ្លើយតបសរុប = ៣៥៩៨ កត់សម្គាល់ថា គ្មានការតម្រូវឱ្យអ្នកចូលរួមឆ្លើយត្រូវតែឆ្លើយតបគ្រប់សំណួរនោះទេ ដូច្នេះហើយមានអ្នកឆ្លើយសំណួរប្រហែល ១០០ នាក់ បានរំលងសំណួរនេះ។

# ការរំពឹងទុកពីសង្គម (បន្ត) ២/៦

យ៉ាងណាមិញ សម្រាប់អ្នកឆ្លើយតបដែលជាបុគ្គលិកអង្គការសង្គមស៊ីវិល បានបង្ហាញពីការរឹតត្បិតលើសេរីភាពផ្លូវភេទរបស់ស្ត្រីដូចការរំពឹងទុកពីគ្រួសារដែរ។ ខណៈពេលដែលពួកគេបានពន្យល់ពីសារៈសំខាន់នៃព្រហ្មចារីនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ពួកគេក៏បានបង្ហាញការរិះគន់ទៅលើវប្បធម៌ព្រហ្មចារី ដោយភ្ជាប់ការដែលសង្គមចាត់ទុករាងកាយស្ត្រីជាកម្មវត្ថុផងដែរ។ នៅក្នុងឧទាហរណ៍បន្ទាប់ទៀតដែលចង្អុលបង្ហាញពីភាពប្រសព្វគ្នារវាង បទដ្ឋានវប្បធម៌ និងសង្គម ដូចដែលអ្នកឆ្លើយតបមកពីអង្គការសង្គមស៊ីវិលម្នាក់បានសំដៅលើសុភាសិតខ្មែរថា ជាការបង្ហាញពីយុទ្ធសាស្ត្រនៃ 'ការគ្រប់គ្រង' និង 'ភាពអាម៉ាស់'៖

"មនុស្សឱ្យតម្លៃច្រើនដល់ព្រហ្មចារី ពីព្រោះសង្គមកម្ពុជា គឺជាសង្គមបិតាធិបតេយ្យ។ មនុស្សប្រើប្រាស់ ព្រហ្មចារី ជាឧបករណ៍ដើម្បីគ្រប់គ្រងលើសេរីភាពផ្លូវភេទរបស់ស្ត្រី ក៏ដូចជាមាក់ងាយពួកគេ ដោយការចាត់ទុករាងកាយស្ត្រីជាកម្មវត្ថុ តាមរយៈការប្រៀបធៀបស្ត្រី ទៅនឹងប្រហុក និងជាក្រណាត់ស។" (*C1F*)

ទោះជាយ៉ាងណា មានអ្នកឆ្លើយតបជាច្រើនដែលមិនមែនជាបុគ្គលិកអង្គការសង្គមស៊ីវិល បានលើកឡើងថា 'តម្លៃ' ស្ត្រីនៅក្នុងសង្គមអាចត្រូវបានវាស់វែងតាមរយៈស្ថានភាពនៃការរួមភេទមុនរៀបការ មានអ្នកឆ្លើយតបមួយចំនួនតូចប៉ុណ្ណោះ ដែលបានបញ្ចេញមតិមិនយល់ស្របទាំងស្រុងទៅលើការលើកឡើងនេះនៅក្នុងអំឡុងពេលសម្ភាស។

អ្នកឆ្លើយតបមួយចំនួនបានរាយការណ៍ថា ព្រហ្មចារីមិនគ្រាន់តែឆ្លុះបញ្ចាំងពីកម្រិតដែលសង្គមចាត់ទុកស្ត្រីថាមានតម្លៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានកំណត់ថា តើស្ត្រីបានឱ្យតម្លៃខ្លួនឯងដល់កម្រិតណាផងដែរ ដូចដែលព្រះសង្ឃមួយអង្គបានមានសង្ឃដីកាចង្អុលបង្ហាញថា៖

"ព្រហ្មចារីបង្ហាញពីការពិតនៃការផ្តល់តម្លៃដល់ខ្លួនឯង ការពារខ្លួនឯង និងរក្សាកេរ្តិ៍ឈ្មោះគ្រួសាររហូតដល់ពេលរៀបការ... សម្រាប់មនុស្សស្រីដែលលេងសើច និងមិនផ្តល់តម្លៃដល់ខ្លួនឯងមិនសមនឹងទទួលបានតម្លៃច្រើននោះទេ។" (Z8Monk)

## ទ្វេស្តង់ដារ

ទាក់ទងនឹងកម្រិតនៃការវិនិច្ឆ័យពីសង្គមដែលមនុស្សប្រុសបានជួបប្រទះ អ្នកតបសម្ភាសទាំងអស់បានសម្តែងទស្សនៈថា ប្រសិនបើធ្លាប់បានទទួលបទពិសោធន៍ទាំងនោះ បទពិសោធន៍ដែលបុរសបានជួបប្រទះនោះ គឺតិចជាងអ្វីដែលមនុស្សស្រីជួបប្រទះនោះទេ។ ចំណុចនេះ ត្រូវបានបង្ហាញតាមរយៈការឆ្លើយតបពីព្រះសង្ឃមួយអង្គ ដែលមុននេះបានបរិយាយព្រហ្មចារីថាជា "សក្ខីភាពបញ្ជាក់ពីតម្លៃរបស់មនុស្សស្រី"៖

**"បុរសទំនងជាមិនសូវត្រូវបានគេរិះគន់ទេបើប្រៀបធៀបនឹងស្ត្រី ព្រោះជាទូទៅ វប្បធម៌ព្រហ្មចារីត្រូវបានអនុវត្តចំពោះតែមនុស្សស្រីប៉ុណ្ណោះ។ បុរសដែលរួមភេទមុនរៀបការ មិនមែនជារឿងធំដុំនោះទេ ពីព្រោះ... វប្បធម៌យើងដាក់សម្ពាធតែទៅលើស្ត្រីប៉ុណ្ណោះ។"**

ទិន្នន័យស្ទង់មតិ ដែលបានបង្ហាញនៅក្នុង *Figure 7* នៅក្នុងទំព័រមុន បង្ហាញយ៉ាងច្បាស់អំពីការអនុវត្តន៍ទ្វេស្តង់ដារនេះ។ អ្នកចូលរួមត្រូវបានសួរដើម្បីវាយតម្លៃថា តើការថ្លែងបែបនេះពិតកម្រិតណាដែលថា "បុរសមានសេរីភាពច្រើនជាងក្នុងការសម្រេចចិត្តថា តើត្រូវរួមភេទមុនរៀបការដែរ ឬទេ។"

# ការរំពឹងទុកពីសង្គម (បន្ត) ៣/៦

ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់ អ្នកឆ្លើយតបចំនួន ៦៣៤ នាក់ មានអារម្មណ៍ថាការលើកឡើងបែបនេះ គឺមិនពិតទេ ហើយស្ត្រី និងបុរស មានសេរីភាពស្មើគ្នា ក្នុងការចូលរួមការរួមភេទមុនពេលរៀបការ។ ផ្ទុយទៅវិញ ស្ទើរតែបួនដងនៃចំនួននោះ (២,៣២៦ នាក់) បានឆ្លើយតបថា ការលើកឡើងខាងដើម គឺពិតណាស់ ហើយថាបុរសពិតជាទទួលបានសេរីភាពផ្លូវភេទមុនពេលរៀបការច្រើនជាងស្ត្រី។

សម្រាប់អ្នកឆ្លើយតបមួយចំនួន ទាំងក្មេង និងចាស់ ពួកគេមានអារម្មណ៍ថា ភាពទ្វេស្តង់ដារនេះ ជាធាតុបង្កធំបំផុតនៃការមាក់ងាយផ្នែកសង្គមទៅលើការបាត់បង់ព្រហ្មចារីរបស់ស្ត្រីមុនពេលរៀបការ។ អ្នកឆ្លើយតបជាស្ត្រីវ័យក្មេងម្នាក់ ហាក់ដូចជាមិនរិះគន់លើការរំពឹងទុករបស់សង្គមទៅលើស្ត្រីទេ លើកលែងតែ ក្នុងន័យថា ការរំពឹងទុកទាំងនេះ គួរតែត្រូវបានដាក់កម្រិតទៅលើបុរសផងដែរ៖

"សម្រាប់មនុស្សប្រុសវិញ ខ្ញុំគិតថា គួរតែដូចគ្នាទៅនឹងស្ត្រីដែរ។ ការរក្សាព្រហ្មចារីរហូតដល់ពេលរៀបការសម្រាប់បុរសក៏សំខាន់ដូចគ្នាសម្រាប់ស្ត្រីដែរ។ ទោះបីជាមនុស្សប្រុសមិនមានផ្ទៃពោះ ឬមិនទទួលការមាក់ងាយផ្នែកសង្គមដូចមនុស្សស្រីក្តី ក៏បុរសមានព្រហ្មចារីដូចស្ត្រីដែរ ដូច្នេះហើយពួកគេគួរតែរក្សារហូតដល់ពេលរៀបការ។" (*Z26F*)

ការលើកឡើង ពីអ្នកតបសម្ភាសដែលជាស្ត្រីវ័យក្មេងនេះ បង្ហាញយ៉ាងច្បាស់ពីទំនោរនៃការមិនប្រឡូកក្នុងការរួមភេទមុនពេលរៀបការ ដែលរំលេចពីភាព ស្មុគស្មាញនៃការយល់ឃើញផ្សេងៗគ្នាក្នុងចំណោមប្រជាពលរដ្ឋខ្មែរ និងតម្រូវការនៃការវែកញែកភាពស្មុគស្មាញទាំងនេះ នៅពេលពិភាក្សាអំពីការផ្លាស់ប្តូរអាកប្បកិរិយាតាមជំនាន់នីមួយៗ។

នៅពេលដែលពិភាក្សាអំពីប្រភពដែលនាំឱ្យមានការរំពឹងទុកផ្នែកសង្គមជុំវិញវប្បធម៌ព្រហ្មចារី អ្នកឆ្លើយតបមកពីអង្គការសង្គមស៊ីវិលម្នាក់បាននិយាយថា ចំណុចទាំងនេះកើតចេញមកពី 'មនុស្សគ្រប់គ្នា និងគ្រប់ទីកន្លែង'៖

"ប្រសិនបើ យើងគិតអំពីកម្រិតនៃឥទ្ធិពល គឺចេញមកពីមនុស្សគ្រប់គ្នា និងគ្រប់ទីកន្លែង៖ ឥទ្ធិពលដែលមើលមិនឃើញ ដូចជារឿងភាពយន្ត (ដែលបន្តការដាក់កំណត់របស់សង្គមមកលើស្ត្រី និងភាពបរិសុទ្ធរបស់ពួកគេ) ប្រព័ន្ធផ្សព្វផ្សាយសង្គម គ្រួសារ និងអ្នកជិតខាង ព្រមទាំងតួអង្គដែលអាចមើលឃើញដ៏ទៃទៀត ដូចជារដ្ឋាភិបាល និងស្ថាប័នសាសនានានា។" (C4F)

## ភាពខុសគ្នារវាង ទីក្រុង និងជនបទ ?

ទាក់ទងទៅនឹងភាពខុសគ្នាផ្នែកភូមិសាស្ត្រវិញ អ្នកឆ្លើយតបមួយចំនួន គិតថានៅតាមតំបន់ជនបទស្ត្រីត្រូវបានគេរំពឹងថាគួរតែនៅព្រហ្មចារីរហូតដល់ពេលរៀបការនៅក្នុងកំរិតខ្ពស់ ជាងការរំពឹងទុករបស់អ្នកដែលរស់នៅរាជធានីភ្នំពេញ។ ចំណុចនេះ បង្ហាញពីផ្នែកដ៏គួរឱ្យចាប់អារម្មណ៍ដែលអ្នកស្រាវជ្រាវអាចធ្វើការសិក្សាស្វែងយល់បន្ថែមនាពេលអនាគត។ ក្នុងនោះដែរក៏មានការលើកឡើងពីអ្នកចូលជារួមស្ត្រីវ័យចំណាស់ ដែលរំលេចពីមុខងារ និងឋានៈសង្គមទាក់ទងនឹងរឿងព្រហ្មចារីដែលអាចសិក្សាស្រាវជ្រាវបន្ថែមនាពេលអនាគត៖

**"...អាចពិបាកខ្លាំងនៅតំបន់ជនបទ។ ប៉ុន្តែនៅក្នុងរាជធានីភ្នំពេញ...របៀបដែល *[ក្មេងស្រី]* ធ្វើខ្លួន និងស្លៀកពាក់ ខ្ញុំគិតថានឹងទាក់ទាញមនុស្សប្រុស...ហើយនៅភ្នំពេញ មនុស្សស្រីអាចអាន និងសរសេរបានស្វែងរកការងារធ្វើ និងអាចធ្វើការបាន។"(*O10F*)**

## គំនូសសម្គាល់ទី ៨

### តើអ្នកគិតថាសង្គមខ្មែរយើងផ្តល់សារៈសំខាន់បែបណា ទៅលើការរក្សាព្រហ្មចារីរបស់ស្ត្រី រហូតដល់ពេលរៀបការ?




## គំនូសសម្គាល់ទី ៩

### តើអ្នកគិតថាសង្គមខ្មែរយើងផ្តល់សារៈសំខាន់បែបណា ទៅលើការរក្សាព្រហ្មចារីរបស់បុរស រហូតដល់ពេលរៀបការ?



## ទំនាក់ទំនងស្និទ្ធស្នាលមួយរាត្រី៖ ដំណើរនៅវែងឆ្ងាយ?

និន្នាការគួរឱ្យចាប់អារម្មណ៍មួយទៀត លេចឡើងស្ទើរតែនៅក្នុងគ្រប់បទសម្ភាស ជាមួយអ្នកឆ្លើយតបដែលមិនមែនជាបុគ្គលិកអង្គការសង្គមស៊ីវិលនោះ គឺការខ្វះការយល់ព្រម និងទទួលស្គាល់ ចំពោះការរួមភេទដោយគ្មានទំនាក់ទំនងផ្នែកមនោសញ្ចេតនា រួមទាំងទំនាក់ទំនងស្និទ្ធស្នាលមួយរាត្រី ឬការរួមភេទរវាងបុគ្គលដែលជាមិត្តភក្តិ។ សូម្បីតែអ្នកឆ្លើយតបមួយចំនួនដែលបង្ហាញការបើកចិត្តទូលាយចំពោះការរួមភេទមុនពេលរៀបការបានសង្កត់ធ្ងន់ថា ពួកគេមិនគាំទ្រទៅលើករណីនៃការរួមភេទជាមួយ "មនុស្សចម្លែកមុខ" នោះទេ។

ស្ត្រីវ័យក្មេងម្នាក់បានលើកឡើងថា៖ "ខ្ញុំគិតថាការរួមភេទរវាងអ្នកដែលមានទំនាក់ទំនងជាគូដណ្តឹងនឹងគ្នាមិនគួរជារឿងគួរហាមឃាត់ទេព្រោះពួកគេពិតជាស្រឡាញ់គ្នាមែន។"(Z44F) ការយល់ឃើញទៅលើសេរីភាពផ្លូវភេទនៅក្នុងព្រំដែនកំណត់ជាក់លាក់នេះ នឹងត្រូវពិភាក្សាបន្ថែមទៀតនៅក្នុងចំណុច 'ផលវិបាក' នៃរបាយការណ៍នេះ។ ទោះជាយ៉ាងណាការបង្ហាញនូវកម្រិតខុសគ្នានៃការទទួលយកពីសង្គមទៅលើការរួមភេទមុនពេលរៀបការរបស់ស្ត្រីផ្អែកលើជម្រៅនៃសេចក្តីស្រឡាញ់ និងភាពស្មោះត្រង់ របស់បុរសដែលជាដៃគូរនៅទីនេះអាចជាប្រយោជន៍សម្រាប់អ្នកអាន។ ចំណុចនេះបង្ហាញនៅក្នុងបទសម្ភាសខាងក្រោម ដែលធ្វើឡើងជាមួយអ្នកឆ្លើយតបជាបុរសវ័យចំណាស់ម្នាក់ដែលយើងអាចចាត់ទុកថាគាត់ជាបុគ្គលដែលមានគំនិតទំលំទូលាយទៅលើសេរីភាពផ្លូវភេទ៖

អ្នកសម្ភាស៖ "តើអ្នកមានការយល់ឃើញយ៉ាងដូចម្តេចចំពោះស្ត្រីខ្មែរដែលរួមភេទមុនពេលរៀបការ?"
អ្នកតបសម្ភាស៖ "សម្រាប់ខ្ញុំ គ្មានបញ្ហាទេ ការរួមភេទកើតឡើងសម្រាប់មនុស្សទាំងពីរនាក់ សម្រាប់ទាំងបុរស និងស្ត្រី។ ការរួមភេទមុន ឬក្រោយពេលរៀបការ វាមិនគួរជាបញ្ហាទាល់តែសោះ។"
អ្នកសម្ភាស៖ "តើអ្នកគិតថាស្ត្រីវ័យក្មេងគួរតែអាចរួមភេទជាមួយដៃគូស្និទ្ធស្នាលយូរអង្វែង (ឬដៃគូដែលបានភ្ជាប់ពាក្យហើយ) ជាជាងរួមភេទជាមួយមិត្តភក្តិ ឬមនុស្សចម្លែកមុខមែនទេ? "

អ្នកតបសម្ភាស៖ "**រយៈពេលនៃទំនាក់ទំនងស្នេហាគឺជាកត្តាសំខាន់ណាស់**។ សម្រាប់អ្នកដែលទើបតែស្គាល់គ្នាមួយរយៈខ្លី...**គេមិនដឹងថា ពួកគេនឹងចាប់ផ្តើមគ្រួសារ**ជាមួយគ្នាដែរ ឬអត់ទេ។ ដូច្នេះពួកគេមិនគួរសម្រេចចិត្តរួមភេទឆាប់ពេកទេ... អាចមានផលអវិជ្ជមាន... [ហើយផលអវិជ្ជមានទាំងនេះ] ប៉ះពាល់ដល់ស្ត្រីខ្លាំងជាងបុរស។ ផលអវិជ្ជមានទាំងនេះរួមមានការខូចចិត្ត ការមិនអាចផ្តោតអារម្មណ៍លើការអប់រំ និងការងារ ហើយកាន់តែអាក្រក់ទៅទៀតនោះ **ពួកគេ អាចគិតថារាងកាយរបស់ពួកគេមិនបរិសុទ្ធទៀតទេ** ព្រោះមនុស្សប្រុសបានប៉ះពាល់រួចហើយ។ ពួកគេអាចមានអារម្មណ៍ថា ខ្លួនឯងហាក់មិនមែនជាស្ត្រីល្អទៀតទេ។ ចំពោះបុរសកម្រិតនៃការខូចចិត្តគឺតិចជាងស្ត្រី។ ស្ត្រីគួរតែ... ធ្វើការប៉ាន់ស្មាន និងវាយតម្លៃថា តើដៃគូរបស់ពួកគេបានលះបង់គ្រប់យ៉ាងដើម្បីរស់នៅជាមួយពួកគេរហូតដល់អាយុចាស់ ឬអត់។ បើពិតជាមានការប្តេជ្ញាចិត្តមែន ពួកគេអាចមានទំនាក់ទំងផ្លូវភេទបាន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគ្មានការប្តេជ្ញាចិត្តណាច្បាស់លាស់ទេ ខ្ញុំមិនចង់លើកទឹកចិត្តស្ត្រីណាម្នាក់ឱ្យរួមភេទជាមួយដៃគូពួកគេនោះទេ។ ខ្ញុំមិនវាយតម្លៃពួកគេទេ បើសិនជាគេធ្វើរឿងហ្នឹង ខ្ញុំគ្រាន់តែមិនចង់ឱ្យពួកគេខូចចិត្ត និងខូចខាត។ ដើម្បីជៀសវាងការខូចចិត្ត និងការខកចិត្តណាមួយ **ស្ត្រីគួរតែវាយតម្លៃដោយប្រុងប្រយ័ត្ន នូវកម្រិតនៃការប្តេជ្ញាចិត្តរបស់ដៃគូ និងការលះបង់របស់ពួកគេ មុនពេលរួមភេទ**។" (O2M)

# ការរំពឹងទុកពីសង្គម (បន្ត) ៦/៦

ដូច្នេះសូម្បីតែក្នុងចំណោមបុគ្គលដែលចាត់ទុកថា មានទស្សនៈទូលំទូលាយ និងជឿនលឿន ចំពោះការរួមភេទមុនរៀបការក៏ដោយ ក៏សម្រង់សម្តីនេះបង្ហាញថា គំនិតនៃស្វ័យភាពផ្លូវភេទ និងលទ្ធភាពនៃការសម្រេចចិត្តរបស់ស្ត្រីនៅតែត្រូវបានរារាំង នៅក្នុងព្រំដែននៃការដាស់តឿនពីសង្គម។ ទស្សនៈដែលថាស្ត្រីងាយនឹង "ខូចចិត្ត" និងដែលអាចបាត់បង់ការផ្តោតអារម្មណ៍ ឬមានអារម្មណ៍ថា "មិនមែនជាស្ត្រីល្អទៀតទេ" ដោយសារតែពួកគេ "ត្រូវបានខូចខាត" និង "លែងបរិសុទ្ធ" បន្ទាប់ពីរួមភេទហើយ នៅតែបន្តមាននៅក្នុងគុណតម្លៃ និងការគិត របស់អ្នកតបសម្ភាសដែលចំណុចនេះសំខាន់សម្រាប់ការវិភាគបន្ថែមទៀត នៅក្នុងការស្រាវជ្រាវនាពេលអនាគត។

សម្រង់នេះឆ្លុះបញ្ចាំងពីការយល់ឃើញទាក់ទងនឹងការរួមភេទមុនពេលរៀបការថា ស្ត្រីគួរតែមានការប្រុងប្រយ័ត្ន និងការត្រួតពិនិត្យឱ្យបានល្អិតល្អន់ជាងបុរសគ្រប់ពេលដែលធ្វើសេចក្តីសម្រេចចិត្ត។ អាកប្បកិរិយា និងការសម្រេចចិត្ត ទាក់ទងនឹងរឿងផ្លូវភេទរបស់ស្ត្រី ផ្សារភ្ជាប់ទៅនឹងកម្រិតនៃផលវិបាកផ្នែកផ្លូវចិត្ត ផ្លូវកាយ និងសូម្បីតែអាពាហ៍ពិពាហ៍ ដែលអាចកើតឡើងលើពួកគេ ជាពិសេសស្ត្រីដែលរួមភេទមុនពេលរៀបការ។ ផលវិបាកទាំងនេះនឹងលើកយកមកពិភាក្សានៅផ្នែកបន្ទាប់នេះ។

## គំនូសសម្គាល់ទី ១០

**តើអ្នកគិតថាសង្គមទទួលយកគូស្នេហ៍ ដែលរស់នៅជាមួយគ្នាមុនពេលរៀបការដែរឬទេ?**



# ៥.០ ផលវិបាក

សកម្មភាពដូចគ្នា ផលវិបាកខុសគ្នា?
របកគំហើញទាក់ទងនឹងផលវិបាកដែលជះត្រឡប់មកវិញ ទៅលើអ្នកដែលរួមភេទមុនរៀបការ

## សេចក្តីផ្តើម

បន្ទាប់ពីបានពិនិត្យមើលការរំពឹងទុកផ្នែកវប្បធម៌ គ្រួសារ និងសង្គម ជុំវិញបញ្ហាព្រហ្មចារី ក្នុងប្រទេសកម្ពុជារួច របាយការណ៍ផ្នែកនេះនឹងត្រួតពិនិត្យមើលសេចក្តីរាយការណ៍របស់អ្នកតបសម្ភាស ជុំវិញផលវិបាកនានាដែលកើតឡើងចំពោះអ្នកដែលសម្រេចចិត្តរួមភេទមុនរៀបការ។

ដូចទៅនឹងផ្នែកមុនដែរ ការពិភាក្សាអំពីផលវិបាកនេះ ត្រូវបានចែកចេញជាបីផ្នែក។ ផ្នែកទីមួយគឺស្វែងយល់ អំពីផលប៉ះពាល់ខាងផ្លូវចិត្ត ដែលអ្នកចូលរួមបានរាយការណ៍ថាស្ត្រីមានការឈឺចាប់ដោយសារតែការបាត់បង់ព្រហ្មចារី។ ផ្នែកទីពីរផ្តោតទៅលើទំនាក់ទំនងផលប៉ះពាល់ផ្នែករាងកាយដូចជា 'ការខូចខាត' ដល់សុខភាពបន្តពូជរបស់ស្ត្រី ជំងឺកាមរោគ (STIs) និងការមានផ្ទៃពោះឥតព្រាងទុក។

ផ្នែកចុងក្រោយ ពិភាក្សាអំពីការយល់ឃើញទាក់ទងនឹងផលប៉ះពាល់ទៅលើជីវិតអាពាហ៍ពិពាហ៍ ទាំងក្នុងលក្ខខណ្ឌនៃការលំបាកក្នុងការរៀបការ ("ស្ត្រីនឹងប្រឈមមុខនឹងការលំបាកក្នុងការស្វែងរកប្តី" Z49F) និងការលំបាកក្នុងជីវិតអាពាហ៍ពិពាហ៍ ("ការបាត់បង់ភាពបរិសុទ្ធសម្រាប់ប្តី... អាចនាំឱ្យមានជម្លោះក្នុងគ្រួសារ។" (Z33M)

### គំនូសសម្គាល់ទី ១១

**តើប្រយោគខាងក្រោមនេះត្រឹមត្រូវដែរទេ៖ ស្ត្រីអាចក្លាយជាជនរងគ្រោះនៃការនិយាយដើម និងរងនូវភាពអាម៉ាស់ ប្រសិនបើពួកគេរួមភេទមុនរៀបការ?**



# ៥.១ ការយល់ឃើញពីផលវិបាកខាង ផ្លូវចិត្ត ១/៤

"...បុរសមានសេរីភាពច្រើនជាង។ សម្រាប់មនុស្សប្រុស ការមានដៃគូរួមភេទប៉ុន្មាននាក់ ក៏មិនមែនជាបញ្ហាដែរ ពីព្រោះ នៅពេលដែលពួកគេសុំនរណាម្នាក់រៀបការ គ្មាននរណាម្នាក់សួរគាត់អំពីស្ថានភាពព្រហ្មចារីរបស់ពួកគេឡើយ... ពួកគេមិនចាំបាច់ទ្រាំទ្រនឹងការមាក់ងាយពីសង្គម ការស៊ូទ្រាំផ្នែកផ្លូវចិត្ត ឬការវាយតម្លៃពីឪពុកម្តាយពួកគេឡើយ។" (*Z22F*)

របកគំហើញនៃការសិក្សាស្រាវជ្រាវនេះ បញ្ជាក់យ៉ាងច្បាស់ថា ជាទូទៅ ស្ត្រីខ្មែរដែលត្រូវបានគេដឹងថាបានរួមភេទមុនរៀបការ តែងតែទទួលរងនូវភាពអាម៉ាស់ និងការមាក់ងាយពីសង្គមជាខ្លាំង។

ទោះបីជាទស្សនៈរួមរបស់អ្នកចូលរួមបានបង្ហាញថា វប្បធម៌ព្រហ្មចារីបាននឹងកំពុងតែផ្លាស់ប្តូរតាមបរិបទនៃពេលវេលា ជាពិសេសយុវជនជំនាន់ក្រោយកាន់តែមានគំនិតជឿនលឿន និងបើកចំហក៏ដោយ ក៏ជំនឿថាស្ត្រីគួរតែរក្សាព្រហ្មចារីរហូតដល់ពេលរៀបអាពាហ៍ពិពាហ៍ត្រូវបានរាយការណ៍ថា នៅតែប្រកាន់ខ្ជាប់ដោយប្រជាពលរដ្ឋកម្ពុជាភាគច្រើននៅឡើយ។

ជាការពិត និងជាញឹកញាប់ គេបានកំណត់សម្គាល់ថា ព្រហ្មចារីមានសារៈសំខាន់បំផុតសម្រាប់ស្ត្រីមិនទាន់រៀបការ ក្នុងន័យនេះ ប្រសិនបើស្ត្រីបាត់បង់ព្រហ្មចារីមុនរៀបការនោះ នាងត្រូវទទួលរងនូវផលវិបាកជាច្រើនដែលមានលក្ខណៈធ្ងន់ធ្ងរ និងយូរអង្វែង។

ជាក់ស្តែងដោយសារតែព្រហ្មចារីត្រូវបានផ្សារភ្ជាប់ជាមួយ "តម្លៃ" របស់ស្ត្រី ដូច្នេះការរួមភេទមុនរៀបការត្រូវបានគេនិយាយថាប៉ះពាល់ដល់តម្លៃ និងសេចក្តីថ្លៃថ្នូររបស់នាង ដូចអ្នកឆ្លើយតបសម្ភាសជាបុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់បានលើកឡើងថា៖ "[ចំពោះសង្គម] ការបាត់បង់ព្រហ្មចារី មានន័យថាបាត់បង់តម្លៃទាំងអស់" (C2F) ។

ជាថ្មីម្តងទៀត អ្នកឆ្លើយតបសម្ភាស ក៏បានរាយការណ៍ថា ប្រសិនបើបុរសបានរួមភេទមុនរៀបការទម្ងន់នៃភាពអាម៉ាស់ និងការមាក់ងាយ ហាក់ដូចជាមានតិចជាងស្ត្រី៖

"សង្គមដាក់សម្ពាធកាន់តែខ្លាំងលើស្ត្រី ដោយសារពួកគេគិតថា ចំណង់ផ្លូវភេទគឺជាបុព្វសិទ្ធិរបស់បុរស។ បុរសអាចមានដៃគូច្រើន និងអាចប្រព្រឹត្តអំពើផិតក្បត់ដោយមិនត្រូវប្រឈមនឹងការវាយតម្លៃពីសង្គមទេ។ ចំណុចនេះឆ្លុះបញ្ចាំងពីវិសមភាពនៃទំនាក់ទំនងអំណាច និងតួនាទីយេនឌ័រក្នុងសង្គម" (C2F)។

# ការយល់ឃើញពីផលវិបាកខាងផ្លូវចិត្ត (បន្ត) ២/៤

## ស្រីខាតល័ក្ខណ៍

គំនិតនៃការយល់ឃើញថាការបាត់បង់ព្រហ្មចារីរបស់ស្ត្រីនឹងធ្វើឱ្យខូចខាត ឬបន្ទាបតម្លៃ និងសេចក្តីថ្លៃថ្នូរពីកំណើតនៃភាពជាស្ត្រីត្រូវបានអ្នកឆ្លើយតបយល់ឃើញថាជាលទ្ធផល នឹងផ្តល់ផលវិបាកជាច្រើនដែលបណ្តាលឱ្យស្ត្រីមានការឈឺចាប់ខាងផ្លូវចិត្ត។

ជាក់ស្តែង នៅពេលក្រុមគ្រួសារបានដឹងថា កូនស្រីបានបាត់បង់ព្រហ្មចារីនោះ កូនស្រីនឹងត្រូវបានគេចាត់ទុកថាមិនបានប្រកាន់ខ្ជាប់នូវគំនិត "កូនស្រីត្រឹមត្រូវ" ដែលគោរពដំបូន្មាន និងការរំពឹងទុករបស់ឪពុកម្តាយទេ។

អ្នកឆ្លើយតបម្នាក់ (Z38M) បានផ្តល់ដំបូន្មានថា កូនស្រីអាចប្រឈមមុខនឹងការបណ្តេញចេញពីផ្ទះដោយឪពុកម្តាយពួកគេផ្ទាល់ ខណៈដែលអ្នកចូលរួមម្នាក់ទៀតបានឆ្លុះបញ្ចាំង ពីប្រតិកម្មទូទៅរបស់ឪពុកម្តាយដូចខាងក្រោម៖

"ផលវិបាកដែលស្ត្រីត្រូវប្រឈមមុខ...ស្ថិតនៅក្នុងសម្ពាធផ្លូវចិត្ត [និង] សម្ពាធពីខាងក្រៅ...ការបាត់បង់ព្រហ្មចារីរបស់កូនស្រីត្រូវបានចាត់ទុកថាជាភាពអាម៉ាស់ដល់គ្រួសារទាំងមូល ដោយគេគិតថាកូនស្រីរបស់ពួកគេបាត់បង់តម្លៃ..." (Z25M) ។

គំនិតនៃ 'ភាពអាម៉ាស់' នេះ គឺជាប្រធានបទដែលត្រូវបានលើកឡើងដដែលៗ ក្នុងចំណោមអ្នកឆ្លើយតបនៅពេលពិភាក្សាអំពីផលវិបាកដែលស្ត្រីត្រូវប្រឈមនៅពេលដែល ការបាត់បង់ព្រហ្មចារីរបស់ពួកគេ ត្រូវបានដឹងឮជាសាធារណៈ។

ការមាក់ងាយត្រូវបានរាយការណ៍ថាកើតឡើងតាមរយៈការ 'ដាក់រហ័សនាម' ទៅលើស្ត្រី ដូចដែលអ្នកឆ្លើយតបម្នាក់បានពណ៌នាថា៖ "វប្បធម៌យើង គឺជាវប្បធម៌អភិរក្សនិយម ហើយយើងឱ្យតម្លៃស្ត្រីដោយផ្អែកលើព្រហ្មចារីរបស់ពួកគេ។ ប្រសិនបើពួកគេបាត់បង់ព្រហ្មចារីមុនរៀបការពួកគេក៏បាត់បង់តម្លៃដែរ។ ពួកគេក៏នឹងត្រូវបានគេហៅថាជា ស្រីចិត្តងាយផងដែរ" (Z18F)។

ជាការពិតណាស់ ស្ត្រីដែលមិនអាចរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ ត្រូវគេចាត់ទុកថាជាស្រីខាតល័ក្ខណ៍។ អ្នកតបសម្ភាសមកពីអង្គការសង្គមស៊ីវិលម្នាក់បានពន្យល់ថា "ស្ត្រីវ័យក្មេង ដែលបានរួមភេទតែងតែត្រូវបានគេដាក់ឈ្មោះថាជា ស្រីងប់ងល់នឹងតណ្ហា និងជាស្រីខាតល័ក្ខណ៍" (C1F)។

ស្រដៀងគ្នានេះដែរ យោងតាមអ្នកតបសម្ភាសជាស្ត្រីវ័យចំណាស់ម្នាក់បានលើកឡើងថា "...ប្រសិនបើការរួមភេទមុនរៀបការរបស់ពួកគេត្រូវបានគេដឹងឮ... ពួកគេនឹងត្រូវបានគេរិះគន់ និងនិយាយដើម ហើយនឹងត្រូវបានគេហៅថាជា ស្រីចិត្តងាយ" (O1F)។

ជាចុងក្រោយ អ្នកឆ្លើយតបមួយរូបទៀតបានអះអាងថា ស្ត្រីដែល "សកម្ម និងនិយាយដោយបើកចំហអំពីរឿងរ៉ាវផ្លូវភេទ មិនត្រឹមតែ "ត្រូវបានគេដាក់ងារជាស្រីមិនល្អ និងទទួលបានការមាក់ងាយពីសង្គម" ប៉ុណ្ណោះទេ ថែមទាំងត្រូវបានអ្នកភូមិចាត់ទុកថាជា ស្ត្រីរកស៊ីផ្លូវភេទ និង "ដាក់រហ័សនាមថាជា ស្រីសំផឹង" ទៀតផង (C4F) ។

# ផលប៉ះពាល់ខាងផ្លូវចិត្ត

សម្រាប់ស្ត្រីវ័យក្មេង (ដូចនិងស្ត្រីមិនទាន់រៀបការទូទៅនៅក្នុងប្រទេសកម្ពុជា) ការមាក់ងាយបែបនេះ ស្ទើរតែនាំឱ្យមានបញ្ហាប្រឈមខាងសុខភាពផ្លូវចិត្ត ដែលអាចមានលក្ខណៈធ្ងន់ធ្ងរ និងអូសបន្លាយរយៈពេលវែង។

ឧទាហរណ៍ យុវតីម្នាក់បានរៀបរាប់អំពីការសម្រេចចិត្តរួមភេទមុនរៀបការថា ជាកម្មវត្ថុនៃការវាយតម្លៃផលប៉ះពាល់ និងអត្ថប្រយោជន៍។ ស្ត្រីដែលធ្លាប់រួមភេទ ពួកគេ "ប្រឈមនឹងហានិភ័យ ការរិះគន់ និងការវិនិច្ឆ័យពីអ្នកដទៃដែលអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្ត។" ទោះជាយ៉ាងនេះក៏ដោយ "ប្រសិនបើយើងថែរក្សាព្រហ្មចារីបានដល់ពេលរៀបការ យើងមិនចាំបាច់ព្រួយបារម្ភអំពីការវិនិច្ឆ័យទាំងនេះទេ"។ (Z13F)

អ្នកតបសម្ភាសជាយុវតីម្នាក់ទៀត បានលើកឡើងអំពីអ្វីដែលនាងមើលឃើញថា ជាផលប៉ះពាល់ខាងផ្លូវចិត្តដ៏ធ្ងន់ធ្ងររាប់បញ្ចូលទាំង ការស្អប់ខ្លួនឯង និងរហូតដល់ការធ្វើអត្តឃាត៖

**"ស្ត្រីដែលរួមភេទមុនពេលរៀបការ ត្រូវប្រឈមមុខនឹងគ្រួសារ និងខ្លួននាងផ្ទាល់ ក៏ដូចជាសង្គមផងដែរ។ គ្រួសាររបស់នាងអាច... ដាក់សម្ពាធលើនាង ដែលបណ្តាលឱ្យមានការប៉ះពាល់ផ្លូវអារម្មណ៍ ដែលអ្នកខ្លះអាចធ្វើអត្តឃាត ដោយសារតែការមិនទទួលយកពីសំណាកគ្រួសារនេះ ខណៈដែលការមាក់ងាយពីសង្គម នឹងនាំឱ្យស្ត្រីមានការស្អប់ខ្លួនឯង។ បញ្ហាទាំងនេះកើតឡើងដោយសារតែការរួមភេទ។" *(Z47F)***



# ការយល់ឃើញពីផលវិបាកខាងផ្លូវចិត្ត (បន្ត) ៤/៤

ផលវិបាកខាងផ្លូវចិត្តពីការរួមភេទមុនពេលរៀបការត្រូវបានគេមើលឃើញថា ស្ត្រីប្រឈមនឹងការ 'ការខូចចិត្ត' ផងដែរនៅពេលដែលទំនាក់ទំនងស្នេហាបានបែកបាក់មុនពេលឈានដល់ការរៀបការ។

ការយល់ឃើញបែបនេះ ត្រូវបានស្វែងយល់តាមរយៈសម្រង់សម្ដីនៅក្នុងផ្នែកដើម ដែលបានដាស់តឿនស្ត្រីមិនឱ្យរួមភេទ លុះត្រាតែនាងអាចប្រាកដថាទំនាក់ទំនងរបស់ពួកគេនឹងឈានទៅដល់ការរៀបការ និងការសម្រាលកូន។ ចំណុចនេះបង្ហាញពីការយល់ឃើញកាន់តែទូលំទូលាយថា ស្ត្រីតែងតែប្រឈមមុខនឹងការបោះបង់ចោល បន្ទាប់ពីបាត់បង់ព្រហ្មចារី ហើយថែមទាំងបង្ហាញថា ស្ត្រីងាយនឹងខូចចិត្ត ខណៈដែល "សម្រាប់បុរស កម្រិតនៃការខូចចិត្តគឺ មានតិចជាង" (O2M) ។

ចំណុចនេះគូសបញ្ជាក់ មិនត្រឹមតែភាពធ្ងន់ធ្ងរនៃផលវិបាក ដែលជួបប្រទះដោយស្ត្រីដែលបាត់បង់ព្រហ្មចារី ទាំងដែលមិនទាន់មាន "ការធានា" ថានឹងមានស្វាមីនៅចាំទទួលខុសត្រូវតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង បង្ហាញឲ្យឃើញពី (ប្រហែលអាចជាលទ្ធផល) អតុល្យភាពនៃអំណាចខុសគ្នានៅក្នុងទំនាក់ទំនងមុនពេលរៀបការ ដែលសំដៅលើលទ្ធភាពក្នុងការសម្រេចចិត្តរបស់បុរស ខណៈមានការដាក់កំហិតលើលទ្ធភាពនៅក្នុងសម្រេចចិត្តរបស់ស្ត្រី។

ការកត់សម្គាល់ចុងក្រោយ គំនិតដែលថា ស្ត្រីអាចទទួលបាន ភាពអង់អាច ឬអារម្មណ៍នៃការដឹងពីភាពជាទីភ្ជាក់ងាររបស់ខ្លួននៅក្នុងទំនាក់ទំនងមិនអចិន្ត្រៃយ៍ ឬបទពិសោធន៍ដែលមិនមែនជាទំនាក់ទំនងស្នេហា ដូចជា ទំនាក់ទំនងស្និទ្ធស្នាលមួយរាត្រី មិនត្រូវបានឆ្លុះបញ្ចាំងពីសំណាក់អ្នកតបសម្ភាសណាមួយនៅក្នុងទិន្នន័យសម្ភាសន៍នោះទេ ទោះបីជាអ្នកចូលរួមវ័យក្មេងជាច្រើននាក់បញ្ជាក់ថា ការគ្មានទំនាក់ទំនងផ្នែកមនោសញ្ចេតនា "មិនគួរមានបញ្ហា" ក៏ដោយ (Z22F) ។

ផ្ទុយទៅវិញ អ្នកឆ្លើយតបជាច្រើនមើលឃើញ និងផ្ដល់ការបរិយាយអំពីផលប៉ះពាល់ខាងផ្លូវចិត្តយ៉ាងស៊ីជម្រៅក្នុងទម្រង់នៃការបាត់បង់ការគោរពចំពោះខ្លួនឯង បន្ទាប់ពីទទួលរង 'ការឈឺចាប់' និង 'ការខូចខាត' ដែលបង្កឡើងដោយការបាត់បង់ព្រហ្មចារីមុនរៀបការ (Z34F) ។

ជាការពិតណាស់ អ្នកឆ្លើយតបជាច្រើនបានពោលសរសើរដល់អ្នកដែលរក្សាព្រហ្មចារីបានថា ជាស្ត្រីដែល "គិតដល់ខ្លួនឯងខ្ពស់" (Z26F) ខណៈដែលបុរសតបសម្ភាសម្នាក់បាននិយាយថា ស្ត្រីដែលបាត់បង់ព្រហ្មចារី "ប្រហែលជាគិតថា រាងកាយរបស់ពួកគេលែងបរិសុទ្ធទៀតហើយ [ហើយ] នឹងមានអារម្មណ៍ថា ហាក់បីដូចជាមិនមែនជាស្ត្រី"។ ផលប៉ះពាល់ខាងផ្លូវចិត្ត និងសរីរាង្គនៃការបាត់បង់ព្រហ្មចារី ត្រូវបានមើលឃើញថា មានភាពប្រសព្វគ្នានឹងត្រូវពិភាក្សាបន្ថែមទៀតនៅក្នុងផ្នែកខាងក្រោម។

# ៥.២ ការយល់ឃើញពីផលវិបាក ផ្លូវកាយ ១/៥

អ្នកចូលរួមជាមួយការសិក្សានេះជាច្រើននាក់បានរាយការណ៍ពីការយល់ឃើញថាការបាត់បង់ព្រហ្មចារីរបស់ស្ត្រីមុនរៀបការអាចមានផលប៉ះពាល់ជាច្រើនដល់រាងកាយ។ ការរកឃើញទាំងនេះមានសារៈសំខាន់ជាពិសេសចំពោះអ្នកតស៊ូមតិយេនឌ័រ ដោយផ្តោតលើសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ ដោយសារតែពួកគេមានការយល់ដឹងអំពីការយល់ឃើញទាក់ទងនឹងសុខភាព និងស្វ័យភាពផ្លូវភេទរបស់ស្ត្រី។

ទីមួយ មានការយល់ឃើញមួយ ដែលត្រូវបានរាយការណ៍ដោយអ្នកឆ្លើយសំណួរជាច្រើននាក់ថា ស្ត្រីដែលរួមភេទមុនពេលរៀបការបណ្តាលឱ្យ "ខូចខាត" ដល់សរីរាង្គបន្តពូជរបស់ពួកគេ។ យុវជនម្នាក់ បានរៀបរាប់ពីគំនិតនេះតាមសុភាសិតខ្មែរមួយថា៖

"បើនិយាយពីវប្បធម៌ និងទំនៀមទម្លាប់ខ្មែរ យើងតែងតែប្រៀបធៀបនារីទៅនឹងផ្កា...ពួកគេបាននិយាយថា នៅពេលដែលស្ត្រីបាត់បង់ព្រហ្មចារី នាងប្រៀបដូចជាផ្កាដែលរលួយស្អុយ។ ពួកគេប្រៀបធៀបព្រហ្មចារីទៅនឹងផ្កា ពីព្រោះផ្កាងាយនឹងរងការប៉ះពាល់ដល់រូបរាង។ ហេតុដូច្នេះហើយ បានជាក្នុងវប្បធម៌ខ្មែរ ពេលស្ត្រីបាត់បង់ព្រហ្មចារី នាងនឹងបាត់បង់តម្លៃដូចទៅនឹងផ្កាបាត់សម្រស់។" (*Z29M*)

គំនិតនៃ 'ផ្កាដែលរលួយស្អុយ' នេះត្រូវបានលើកឡើងដោយអ្នកចូលរួមផ្សេងទៀត ទាក់ទងនឹងការដែលអាច 'បញ្ជាក់' ថាស្ត្រីនៅព្រហ្មចារី ឬបាត់បង់ព្រហ្មចារីហើយ។ អ្នកតបសម្ភាសជាបុរសចំណាស់ម្នាក់បានឆ្លើយថា 'គេអាចដឹង' ថាស្ត្រីនៅព្រហ្មចារី ឬអត់តាមរយៈ ការពិនិត្យមើលរាងកាយ៖

"ក្នុងនាមជាមនុស្សប្រុស ពួកគេមិនមានអ្វីត្រូវខាតបង់នោះទេ នៅពេលពួកគេរួមភេទមុនពេលរៀបការ។ ជាឧទាហរណ៍ គ្មាននរណាម្នាក់អាចដឹង និងគ្មាននរណាម្នាក់អាចកំណត់ដឹងបានថា តើមនុស្សប្រុសនៅព្រហ្មចារី ឬអត់នោះទេ...ខុសគ្នាទាំងស្រុងពីមនុស្សស្រី។ គេអាចដឹង ជាពិសេសដៃគូ/ស្វាមីរបស់នាង ប្រសិនបើស្ត្រីនៅព្រហ្មចារី ឬអត់" (*O2M*)។

# ការយល់ឃើញពីផលវិបាកផ្លូវកាយ (បន្ត) ២/៥

ការយល់ឃើញបែបនេះ ត្រូវបានរាយការណ៍ដោយអ្នកឆ្លើយតបសំណួរជាច្រើននាក់ បើទោះបីជាការពិតផ្អែកតាមការស្រាវជ្រាវបែបវេជ្ជសាស្ត្របានបង្ហាញថា "មិនមានសញ្ញាសម្គាល់លើរាងកាយ [ឬ] ការពិនិត្យលើរាងកាយណាមួយ [ដែល] នឹងអាចបញ្ជាក់ថា បុគ្គលម្នាក់នៅព្រហ្មចារី ឬអត់នោះទេ មិនថាបុរស ឬស្ត្រីឡើយ។ "នេះគឺដោយសារតែភ្នាសសន្ទះព្រហ្មចារី គឺ "អាចបត់បែនបានគ្រប់គ្រាន់ ដើម្បីបញ្ចូលអង្គជាតិដោយគ្មានការដាច់រហែក ប៉ុន្តែវាក៏អាចនឹងត្រូវដាច់រហែកដោយសកម្មភាពផ្សេងៗទៀតក្រៅពីសកម្មភាពរួមភេទ" [១៧]។

អ្នកតបសម្ភាសម្នាក់មកពីអង្គការសង្គមស៊ីវិលបានឱ្យដំបូន្មានថា "គេនិយាយអំពីមធ្យោបាយមួយចំនួនដើម្បីធ្វើការកំណត់ និងសម្គាល់ ប្រសិនបើ និងពេលណា ដែលស្ត្រីបានបាត់បង់ព្រហ្មចារីរួចហើយ ឬនៅ។" យោងតាមទិន្នន័យស្ទង់មតិអ្នកចូលរួមហាក់មានទស្សនៈទូលំទូលាយមួយថា គេអាចមានលទ្ធភាពបញ្ជាក់ថាតើស្ត្រីនៅព្រហ្មចារី ឬអត់ ដែលក្នុងចំណោមនោះមានការឆ្លើយតបភាគច្រើន (៥៧%) ជ្រើសរើសជម្រើសថា ការបញ្ជាក់ពីព្រហ្មចារីអាចធ្វើទៅបានតាមរយៈការពិនិត្យបែបវេជ្ជសាស្ត្រ។

**គំនូសសម្គាល់ទី ១២**

**តើអាចបញ្ជាក់ថានរណាម្នាក់នៅព្រហ្មចារីបានដែរឬទេ?**



## ជំងឺឆ្លងតាមរយៈការរួមភេទ (STIS)

ប្រធានបទមួយទៀត ដែលបានលេចឡើងទាក់ទងទៅនឹងផលវិបាកខាងផ្លូវកាយដោយសារតែការរួមភេទមុនរៀបការ គឺជំងឺកាមរោគ។ អ្នកឆ្លើយតបភាគច្រើនបានបង្ហាញថា ជំងឺឆ្លងទាំងនេះ បង្ហាញពីហានិភ័យស្មើគ្នា សម្រាប់ទាំងស្ត្រី និងបុរស ទោះជាយ៉ាងណាក៏ដោយ មានអ្នកឆ្លើយតបមួយចំនួនតូចបានរៀបរាប់ថាផលវិបាកទាក់ទងនឹងសុខភាពបន្តពូជដោយសារតែ ការរួមភេទមុនរៀបការ គឺជាផលវិបាកចម្បង ឬជាផលវិបាកដែលស្ត្រីត្រូវប្រឈមច្រើនជាងបុរស៖

"ខ្ញុំគិតថា ស្ត្រីអាចប្រឈមនឹងផលវិបាកជាច្រើនដូចជា បញ្ហាសុខភាពបន្តពូជរបស់ពួកគេ ព្រោះមនុស្សស្រីខ្លះមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការរួមភេទ ខ្ញុំមិនគិតថា បុរសប្រឈមនឹងផលវិបាកដូចគ្នានេះនោះទេ" (O13F)។

ទិដ្ឋភាពដ៏គួរឱ្យចាប់អារម្មណ៍មួយទៀត ទាក់ទងទៅនឹងជំងឺឆ្លងតាមរយៈការរួមភេទនោះ គឺគំនិតដែលថា "ប្រសិនបើដៃគូរួមភេទរបស់ពួកគេមិនដឹងអំពីការការពារទេនោះ ពួកគេអាចមានលទ្ធភាពឆ្លងជំងឺដែលឆ្លងតាមរយៈការរួមភេទទាំងនោះ" (Z24M) ។ ចំណុចនេះសបញ្ជាក់ឱ្យឃើញថា វាអាស្រ័យលើមនុស្សប្រុស ដើម្បី 'ដឹងអំពីការការពារខ្លួនពីជំងឺកាមរោគ' ហេតុដូច្នេះហើយ វាមានភាពចាំបាច់សម្រាប់ការធ្វើឱ្យប្រសើរជាងមុននៅក្នុងការអប់រំអំពីវិធីសាស្ត្រការពារពីជំងឺឆ្លងតាមរយៈការរួមភេទទាំងនេះ (STIs។





## ការមានផ្ទៃពោះ

អ្នកឆ្លើយតបសម្ភាសជាច្រើន បានពិភាក្សាអំពីផលវិបាកនៃការមានផ្ទៃពោះមុនរៀបការ ព្រមទាំងគ្រោះថ្នាក់ផ្នែករាងកាយនៅពេលដែលប្រើប្រាស់សេវារំលូតមិនស្របច្បាប់។ អ្នកចូលរួមជាច្រើននាក់បានរៀបរាប់អំពីកម្រិតខ្ពស់នៃការមាក់ងាយ និង ភាពអាម៉ាស់ដែលស្ត្រីត្រូវប្រឈមពេលមានផ្ទៃពោះមុនពេលរៀបការ។

ចំណុចនេះក៏ប្រសព្វជាមួយនឹងបញ្ហាដែលត្រូវបានសិក្សានៅក្នុងផ្នែកកន្លងទៅផងដែរ៖ ផលប៉ះពាល់ផ្នែករាងកាយនៃការមានផ្ទៃពោះ ត្រូវបានរួមផ្សំដោយផលប៉ះពាល់ផ្លូវចិត្ត ដែលបណ្ដាលមកពីប្រតិកម្មតបរបស់សង្គម ចំពោះការមានផ្ទៃពោះក្រៅអាពាហ៍ពិពាហ៍។ ការយល់ឃើញបែបនេះត្រូវបានគូសបញ្ជាក់ពី អ្នកតបសម្ភាសវ័យក្មេងដែលជាអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ថា៖

**"ពួកគេ *[ស្ត្រី]* មិនអាចគិចផុតពីការវាយតម្លៃពីសង្គមបានទេ នៅពេលដែលពួកគេមានផ្ទៃពោះដោយមិនបានរៀបការ។ ពួកគេនឹងត្រូវបានសួរថាតើឪពុករបស់កូនដែលនៅក្នុងផ្ទៃនៅឯណា។ សង្គមអាចរិះគន់ទាំងម្ដាយ និងកូន ដែអាចផ្ដល់ផលប៉ះពាល់អវិជ្ជមានដល់សុខភាពផ្លូវចិត្តនិងការអភិវឌ្ឍរបស់កុមារ" (*Z21M*)។**

## ផលប៉ះពាល់នៃវប្បធម៌ព្រហ្មចារីទៅលើការទទួលបានព័ត៌មានរបស់ស្ត្រីអំពីសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ

ផលប៉ះពាល់មួយពីវប្បធម៌ព្រហ្មចារី ដែលត្រូវបានរាយការណ៍នោះគឺ ស្ត្រីវ័យក្មេងជាច្រើន ខ្វះចំណេះដឹងក្នុងការការពារការមានផ្ទៃពោះដោយចៃដន្យ ឬ ខ្វះចំណេះដឹង ក្នុងការធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងអំពីភាពស្និទ្ធស្នាល និងការបង្ហាញចេញទាក់ទងនឹងរឿងរ៉ាវផ្លូវភេទ។ ចំណុចនេះត្រូវបានសង្ខេបតាមរយៈសម្រង់សម្ដីពីអ្នកតបសម្ភាសមកពីអង្គការសង្គមស៊ីវិលម្នាក់ដែលឆ្លុះបញ្ចាំងពី "គុណតម្លៃបិតាធិបតេយ្យ" ដែលបានសម្ដីពីអ្នកតបសម្ភាសមកពីអង្គការសង្គមស៊ីវិលម្នាក់ដែលឆ្លុះបញ្ចាំងពី "គុណតម្លៃបិតាធិបតេយ្យ" ដែលបានផ្សារភ្ជាប់មកជាមួយនូវបម្រាមទាក់ទងនឹងផ្លូវភេទ៖

"ពួកយើងធំឡើងជាមួយនឹងគុណតម្លៃ និងប្រពៃណីទាំងនេះ ដែលបានទទួលឥទ្ធិពលពីគុណតម្លៃបិតាធិបតេយ្យ។ ខ្ញុំមិនដឹងថាវាចាប់ផ្តើមនៅពេលណាទេ ប៉ុន្តែយើងបានចាប់កំណើតមក ហើយត្រូវបានទូន្មានប្រៀនប្រដៅជាមួយគុណតម្លៃទាំងនោះ។ ជាឧទាហរណ៍ ខ្ញុំមិនមានមិត្តប្រុសទេ កាលនៅរៀនវិទ្យាល័យ។ ខ្ញុំត្រូវបានបង្រៀនឱ្យការពារព្រហ្មចារីរបស់ខ្ញុំ ទោះបីនៅក្នុងតម្លៃណាក៏ដោយ។ ខ្ញុំត្រូវបានគេប្រាប់ថា ប្រសិនបើបុរសណាម្នាក់ប៉ះដៃរបស់ខ្ញុំនៅពេលដែលខ្ញុំមានរដូវ ខ្ញុំនឹងមានផ្ទៃពោះ។ ដូច្នេះ តើអ្នកដឹងថាយ៉ាងម៉េចទេ? ខ្ញុំបានជឿវា ហើយនៅពេលនោះ ខ្ញុំមានអាយុ ១៦ឆ្នាំហើយ។

មនុស្សជាច្រើននៅតែមិននិយាយអំពីព្រហ្មចារី និងការរួមភេទដោយបើកចំហ ពីព្រោះ អស់រយៈពេលជាយូរណាស់មកហើយ ប្រធានបទទាំងនេះត្រូវបានចាត់ទុកថាជា ប្រធានបទដែលត្រូវហាមប្រាម... ជាពិសេសសម្រាប់អ្នកដែលរស់នៅតាមតំបន់ដាច់ស្រយាល" (*C4F*)។

# ៥.៣ ផលវិបាកក្នុង អាពាហ៍ពិពាហ៍ ១/៣

"ខ្ញុំគិតថាពិតជាសំខាន់ណាស់សម្រាប់ស្ត្រីក្នុងការរក្សាព្រហ្មចារី ដើម្បីការពារជម្លោះនិងអំពើហិង្សាក្នុងគ្រួសារ។ ប្រសិនបើស្ត្រីបាត់បង់ព្រហ្មចារីមុនរៀបការ ជារឿយ។ អាចនឹងនាំឱ្យមានអំពើហិង្សាធ្ងន់ធ្ងរកើតឡើងនៅក្នុងទំនាក់ទំនងរវាងប្ដី និងប្រពន្ធ"( ***O***13***F*** )។

ផ្នែកចុងក្រោយនេះនឹងពិនិត្យមើលទៅលើ ការយល់ឃើញចំពោះផលវិបាកជាក់ស្ដែងដែលកើតឡើងនៅក្នុងចំណងអាពាហ៍ពិពាហ៍ដោយសារតែការរួមភេទមុនរៀបការ។ ចំណុចទីមួយ ដូចដែលសម្រង់សម្ដីខាងលើបានបង្ហាញ គឺមានការយល់ឃើញថា ជាពិសេសក្នុងចំណោមអ្នកតបសម្ភាសវ័យចំណាស់ ការបាត់បង់ព្រហ្មចារី មុនរៀបការរបស់ស្ត្រីអាចជាមូលហេតុនាំឲ្យមានកំហឹង និងជម្លោះនៅក្នុងអាពាហ៍ពិពាហ៍ និងអាចឈានទៅដល់ការប្រព្រឹត្តអំពើហិង្សាផងដែរ។ យុវជនតបសម្ភាសម្នាក់ បញ្ជាក់ថា "ពួកគេ មិនមានភាពបរិសុទ្ធសម្រាប់ដៃគូ ឬស្វាមីរបស់ពួកគេទេ [ដូច្នេះ] វាអាចនាំឱ្យមានជម្លោះ។" (Z33M)

ស្រដៀងគ្នានេះដែរ អ្នកឆ្លើយតបសំណួរជាច្រើននាក់បានលើកឡើងអំពីកង្វះនៃការអលទ្ធភាពរបស់ភរិយាក្នុងការបង្ហាញភក្ដីភាព និងភាពស្មោះត្រង់ចំពោះស្វាមីប្រសិនបើពួកគេរួមភេទមុនពេលរៀបការ៖

"...សម្រាប់ស្ត្រី គឺចាំបាច់ណាស់ដែលត្រូវរក្សាព្រហ្មចារីរហូតដល់ថ្ងៃរៀបការ។ ព្រហ្មចារី តំណាងឱ្យភាពស្មោះត្រង់ និងទំនុកចិត្តរបស់ស្ត្រី សម្រាប់បុគ្គលដែលនាងនឹងរៀបការជាមួយ។" (Z7F)

អ្នកតបសម្ភាសជាយុវតីជាច្រើននាក់ ហាក់បីដូចជាយល់ស្របនឹងបទដ្ឋានទាំងនេះ និងបានផ្ដល់ការបកស្រាយថា ការប្រតិបត្តិតាមបទដ្ឋានទាំងនេះជួនកាល ជាការចាំបាច់ ពីព្រោះដើម្បីចៀសវាងនូវផលប៉ះពាល់ខាងផ្លូវចិត្ត ដែលអន្តរប្រសព្វជាមួយនឹងបទពិសោធន៍នៃការរួមភេទមុនរៀបការរបស់ស្ត្រី៖

"ខ្ញុំគិតថា [ព្រហ្មចារី] មានសារៈសំខាន់នៅក្នុងទិដ្ឋភាពជាច្រើន។ ទីមួយ ប្រសិនបើនាងអាចរក្សាព្រហ្មចារីរហូតដល់ពេលរៀបការបាន មានន័យថា នាងមិនបានជាប់ជំពាក់ខាងផ្លូវចិត្ត ផ្លូវកាយ ឬមនោសញ្ចេតនាជាមួយបុរសផ្សេងទៀត ក្រៅពីប្ដីនាងឡើយ។ ដូច្នេះនាងនឹងមិនខូចចិត្តដែលមិនអាចរៀបការជាមួយអ្នកផ្សេងនោះទេ។" (Z13F)

សម្រង់សម្ដីនេះឆ្លុះបញ្ចាំងឱ្យឃើញពីការយល់ឃើញជាទូទៅថា សេចក្ដីស្នេហា និងការរួមភេទ យ៉ាងហោចណាស់សម្រាប់ស្ត្រី គឺមានដំណើរស្របគ្នា។ បើប្រៀបធៀបទៅនឹងស្ថានភាពបុរស ចំពោះការយល់ឃើញខាងលើនេះ ជុំវិញការរងនូវការឈឺចាប់ផ្លូវចិត្តដោយសារតែ 'ការជាប់ចិត្ត' ឬខូចចិត្ត បន្ទាប់ពីការរួមភេទមុនពេលរៀបការនោះ មិនមានបង្ហាញនៅក្នុងទិន្នន័យសម្ភាសន៍នោះទេ។

# ការយល់ឃើញពីផលវិបាកក្នុងអាពាហ៍ពិពាហ៍ (បន្ត) ២/៣

## គំនូសសម្គាល់ទី ១៣

### តើនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ បុរសនៅតែប្រាថ្នាចង់រៀបការជាមួយនារីដែលនៅព្រហ្មចារីដែរឬទេ?




## គំនូសសម្គាល់ទី ១៤

### តើនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ស្ត្រីប្រាថ្នាចង់រៀបការជាមួយបុរសនៅព្រហ្មចារីដែរឬទេ?



# ការយល់ឃើញពីផលវិបាកក្នុងអាពាហ៍ពិពាហ៍ (បន្ត) ៣/៣

សេចក្តីប្រាថ្នានៅក្នុងចំណោមបុរស (ដែលបានបញ្ជាក់ម្តងហើយម្តងទៀត អំពីគ្រួសារខាងបុរស) អំពីការចង់បានភរិយាដែលនៅព្រហ្មចារី ត្រូវបានគេរាយការណ៍ថាពេលខ្លះនៅតែត្រូវបានប្រកាន់ខ្ជាប់ខ្លាំង ដែលអាចបង្កការលំបាកដល់ស្ត្រីដែលរួមភេទរួចហើយ ក្នុងការស្វែងរកស្វាមីនៅពេលក្រោយក្នុងជីវិត៖

"...នាងនឹងប្រឈមជាមួយការលំបាកក្នុងការស្វែងរកដៃគូ បន្ទាប់ពីពួកគេដឹងថានាងធ្លាប់ពាក់ព័ន្ធនឹងរឿងនោះ។ អ្នកខ្លះ ប្រហែលជាមិនព្រមទទួលយកនាង ឬមើលងាយនាង។" (Z49F)

របកគំហើញនេះក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិន្នន័យស្ទង់មតិផងដែរ ដែលមានអ្នកឆ្លើយតបជិតមួយពាន់នាក់ (៩៩៧) បានបញ្ជាក់ថា ប្រសិនបើស្ត្រីត្រូវបានគេដឹងថាបានរួមភេទមុនរៀបការ នាងនឹងកាន់តែមានការលំបាកក្នុងការស្វែងរកស្វាមីនៅពេលអនាគត ខណៈដែលមានអ្នកឆ្លើយតបតិចជាងមួយរយនាក់ (៨៨) មានអារម្មណ៍ថានេះក៏ជាករណីសម្រាប់បុរសផងដែរ។

ទោះបីជាយ៉ាងនេះក្តី អ្នកតបសម្ភាសជាច្រើននាក់ក៏បានផ្តល់មតិផងដែរថា បុរសគួរតែប្រកាន់ខ្ជាប់ស្តង់ដារនេះឲ្យស្មើគ្នា ដូចស្ត្រីដែរ នៅពេលពួកគេស្វែងរកភរិយាដូចដែលអ្នកតបសម្ភាសជាបុរសវ័យចំណាស់ម្នាក់បានលើកឡើងថា៖

"ខ្ញុំគិតថា ដូចគ្នានឹងបុរសចង់បានស្ត្រីនៅព្រហ្មចារីដែរ បុរសគួរតែអាចបញ្ជាក់ថា ពួកគេមានភាពបរិសុទ្ធ និងមិនមានទំនាក់ទំនងជាមួយមនុស្សស្រីណាផ្សេងទេ មុនពេលដែលឈានចូលដល់ទំនាក់ទំនងផ្លូវការ។" (O6M)

ផលវិបាកក្នុងអាពាហ៍ពិពាហ៍ផ្សេងទៀត ដែលត្រូវបានរាយការណ៍រួមមាន នៅពេលដែលគូស្នេហ៍វ័យក្មេងត្រូវបានគេដឹងថាបានរួមភេទ ឪពុកម្តាយរបស់ពួកគេនឹងចាត់ការរៀបចំអាពាហ៍ពិពាហ៍ជាបន្ទាន់ និងយ៉ាងឆាប់រហ័ស ហើយដាក់សម្ពាធឱ្យគូស្នេហ៍ទាំងពីរយល់ព្រម៖

"ឪពុកម្តាយរបស់ពួកគេមិនមានជម្រើសអ្វីផ្សេងទេក្រៅតែបង្ខំចិត្តរៀបការឱ្យពួកគេ...នៅពេលដែលដឹងថាកូនស្រីបាត់បង់ព្រហ្មចារី ពួកគាត់ស្វែងរកបុរសនោះឲ្យមករៀបការជាមួយកូនរបស់ពួកគេ។" (Z28M)

ជាចុងក្រោយ អ្នកឆ្លើយតបសម្ភាសមកពីអង្គការសង្គមស៊ីវិលមួយរូប បានឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃវប្បធម៌ព្រហ្មចារីដែលបានជះឥទ្ធិពលលើស្ត្រីសូម្បីនៅក្រោយពេលដែលពួកគេបានរៀបការរួចហើយក៏ដោយ ដោយសារតែមានការរំពឹងទុកថាជាទូទៅស្ត្រីខ្មែរ គួរតែបង្ហាញពីភាពខ្មះខ្មាសនិងសោធន៍របស់ខ្លួន ឬបង្ហាញថាពួកគេមានចំណង់ផ្លូវភេទតិចជាងដៃគូរបស់ពួកគេ។

"មនុស្សស្រីខ្លះមិនហ៊ានសូម្បីតែបង្ហាញចំណង់ផ្លូវភេទជាមួយដៃគូ ឬស្វាមី ដោយសារតែភ័យខ្លាចការវាយតម្លៃ។"(C2)

ចំណុចនេះ បានបញ្ជាក់អំពីផលប៉ះពាល់ទៅលើស្ថានភាពជាទីភ្ញាក់ងារ ការសម្តែងអារម្មណ៍ និងការបំពេញសេចក្តីត្រូវការផ្នែកផ្លូវភេទរបស់ស្ត្រី ដែលចំណុចសំខាន់ៗទាំងនេះអាចជាប្រធានបទសម្រាប់ការស្រាវជ្រាវនាពេលអនាគត។

# បទពិសោធន៍ពី
# ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា

បទពិសោធន៍ និងការយល់ឃើញទាក់ទងនឹងព្រហ្មចារីរបស់អ្នកស្រឡាញ់ភេទដូចគ្នា ១/៥

## សេចក្ដីផ្ដើម

រហូតមកទល់ពេលនេះ របាយការណ៍នេះបានផ្ដោតការយកចិត្តទុកទៅលើ ការយល់ឃើញពាក់ព័ន្ធនឹងបទដ្ឋានព្រហ្មចារីនៅក្នុងទំនាក់ទំនងស្និទ្ធស្នាលរបស់ក្រុមបុគ្គលស្រឡាញ់ភេទផ្ទុយគ្នា និងស៊ីសយេនឌ័រ។

ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍ផ្លូវភេទរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា គឺមាសារៈសំខាន់ និងមានភាពពាក់ព័ន្ធគ្នា ព្រមទាំងបង្ហាញពីចំណុចដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់ការស្រាវជ្រាវនាពេលអនាគត អំពីរបៀបដែលយុវជនកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នា យល់ឃើញ និងចាត់ចែងបញ្ហាទាំងនេះ។

បន្ថែមពីនេះ វត្តមានអ្នកស្រលាញ់ភេទដូចគ្នាក៏មាននៅក្នុង ចំណោមក្រុមអ្នកស្រាវជ្រាវសកម្មផងដែរ ហើយក្រុមស្រាវជ្រាវក៏បានស្វះស្វែងជួបសម្ភាសន៍ជាមួយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីស្វែងយល់អំពីការយល់ដឹងរបស់ពួកគេជុំវិញបញ្ហាទាំងនេះ។ ទន្ទឹមនេះផងដែរ អ្នកចូលរួមផ្ដល់បទសម្ភាសន៍ និងអ្នកឆ្លើយតបសំណួរស្ទង់មតិ ដែលកំណត់អត្តសញ្ញាណថា មិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នា ក៏ត្រូវបានសាកសួរអំពីការយល់ឃើញរបស់ពួកគេជុំវិញបញ្ហាព្រហ្មចារីរបស់សហគមន៍អ្នស្រឡាញ់ភេទដូចគ្នាផងដែរ។

## ការយល់ឃើញអំពីសារៈសំខាន់នៃព្រហ្មចារីរបស់អ្នកស្រឡាញ់ភេទដូចគ្នា

អ្នកចូលរួមដែលមិនបានកំណត់អត្តសញ្ញាណជាអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងកំឡុងពេលសម្ភាសន៍បានផ្ដល់គំនិត និងការយល់ឃើញផ្សេងៗគ្នា នៅពេលចោទសួរថា តើបទដ្ឋានព្រហ្មចារីគួរអនុវត្តនៅក្នុងសហគមន៍ស្រឡាញ់ភេទដូចគ្នាដែរឬទេ ខណៈ បច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅមិនទាន់មានច្បាប់ទទួលស្គាល់សមភាពអាពាហ៍ពិពាហ៍នៅឡើយ។

ទីមួយ ក្នុងចំណោមអ្នកឆ្លើយតបជាច្រើននាក់ដែលបានចូលរួមនៅក្នុងការសិក្សានេះ បានបង្ហាញ ការយល់ឃើញជាក់លាក់មួយថា អ្នកស្រឡាញ់ភេទដូចគ្នា មិនចាំបាច់ត្រូវប្រតិបត្តិតាមបទដ្ឋានព្រហ្មចារីនោះទេ។ ចំណុចគួរឱ្យចាប់អារម្មណ៍នោះគឺថា ទស្សនៈនេះ ត្រូវបានទទួលស្គាល់ជាទូទៅ សូម្បីតែនៅក្នុងចំណោមអ្នកឆ្លើយតបវ័យចំណាស់ដែលបានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការរក្សាព្រហ្មចារីរបស់ស្ត្រីដែលមិនទាន់រៀបការរហូតដល់រៀបអាពាហ៍ពិពាហ៍ក៏ដោយ។

# បទពិសោធន៍ និងការយល់ឃើញទាក់ទងនិងព្រហ្មចារីរបស់ អ្នកស្រឡាញ់ភេទដូចគ្នា( បន្ត ) ២/៥

ជាឧទាហរណ៍ ខណៈពេលដែលមនុស្សវ័យចំណាស់ម្នាក់ហាក់បីដូចជាគាំទ្រដល់ការរឹតបន្តឹងទៅលើស្វ័យភាពផ្លូវភេទរបស់ស្ត្រីដោយផ្អែកលើគុណតម្លៃវប្បធម៌ព្រហ្មចារី គាត់ហាក់ដូចជាមានទស្សនៈសេរីនិយមទាក់ទងនឹងបទដ្ឋានគួរអនុវត្តសម្រាប់ដៃគូស្និទ្ធស្នាលដែលស្រឡាញ់ភេទដូចគ្នា៖

**អ្នកសម្ភាស**៖ តើសំខាន់ចាំបាច់កម្រិតណាសម្រាប់ស្ត្រីក្នុងការរងចាំរហូតដល់ពេលរៀបការហើយទើបរួមភេទ?

**អ្នកតបសម្ភាស**៖ "ខ្ញុំគិតថា ជាការសំខាន់ណាស់សម្រាប់ស្ត្រីព្រោះការអនុវត្តន៍នេះបានប្រតិបត្តិតាំងពីដូនតាយើងរហូតមកដល់សព្វថ្ងៃនេះ នេះគឺជាប្រពៃណី និងវប្បធម៌របស់យើង។"

**អ្នកសម្ភាស**៖ តើសំខាន់ចាំបាច់កម្រិតសម្រាប់ អ្នកស្រលាញ់ភេទដូចគ្នា ក្នុងការរងចាំរហូតដល់ពេលរួមរស់ក្រោមដំបូលផ្ទះតែមួយ ទើបរួមភេទ?

**អ្នកតបសម្ភាស**៖ "ខ្ញុំមិនគិតថា ពួកគេមិនត្រូវរងចាំរហូតដល់ពេលពួកគេរស់នៅក្រោមដំបូលផ្ទះតែមួយជាមួយគ្នានោះទេ។ ខ្ញុំគិតថា ពួកគេអាចរួមភេទបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ ប្រសិនបើពួកគេស្រឡាញ់ និងយល់ព្រមគ្នាទៅវិញទៅមក ហើយវាអាស្រ័យលើការសម្រេចចិត្តរបស់ពួកគេ។" (O15F)

នៅពេលសួរថា តើវប្បធម៌ព្រហ្មចារីគួរអនុវត្តចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាដែរឬទេ អ្នកផ្តល់សម្ភាសជាស្ត្រីចំណាស់ម្នាក់ទៀតបានឆ្លើយយ៉ាងសាមញ្ញថា៖

"ខ្ញុំមិនគិតដូច្នោះទេ...ខ្ញុំមានមិត្តភក្តិដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយពួកគេមិនខ្វល់ពីរឿងនេះទេ។ និយាយឱ្យខ្លី...ពួកគេអាចរួមភេទបានដោយសេរីដរាបណា ពួកគេមិនធ្វើអ្វីបំពានច្បាប់។" (*O16F*)

ទោះជាយ៉ាងណា ជាការគួរឱ្យសោកស្តាយផងដែរដែលមានអ្នកចូលរួមមួយចំនួនបានសម្តែងនូវការខ្វះការយល់ដឹងឬការអត់ឱនចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងទំនាក់ទំនងរបស់ពួកគេ។ ជាឧទាហរណ៍ នៅពេលសួរថា ប្រសិនបើគាត់គិតថាអ្នកស្រឡាញ់ភេទដូចគ្នាគួររង់ចាំរហូតដល់ពេលរស់នៅជាមួយគ្នាទើបរួមភេទឬយ៉ាងណានោះ ស្ត្រីវ័យចំណាស់ម្នាក់បានឆ្លើយដូចខាងក្រោមថា៖

"និយាយតាមត្រង់ទៅ ខ្ញុំមិនយល់ពីមូលហេតុដែលពួកគេជ្រើសរើសធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នានោះទេ ដូច្នេះ ខ្ញុំ
ញុំមិនប្រាកដថាខ្ញុំអាចឆ្លើយសំណួរនេះបានទេ ខ្ញុំមិនដឹងអំពីស្ថានភាពនេះទេ។" (*O17F*)

ការខ្វះការអត់ឱននេះ ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ ដោយអ្នកឆ្លើយតបការស្ទង់មតិចំនួន ៥៣៣នាក់ (គំនូសសម្គាល់ទី១០) ដែលបានបង្ហាញថា ពួកគេមិនគិតថា មនុស្សគួរមានទំនាក់ទំនងផ្លូវភេទជាមួយមនុស្សភេទដូចគ្នាទាល់តែសោះ។

ខណៈចំនួននេះមានត្រឹមតែ ១១.៣% នៃអ្នកឆ្លើយតបសរុប ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែបង្ហាញថាត្រូវមានការខិតខំប្រឹងប្រែងរបន្ថែមទៀត ដើម្បីផ្លាស់ប្តូរអាកប្បកិរិយាទាក់ទងនឹងក្រុមអ្នកសស្រឡាញ់ភេទដូចគ្នាដើម្បីជម្រុញឲ្យមានការយល់ដឹង និងការគោរពគ្នាកាន់តែប្រសើរឡើង។

# បទពិសោធន៍ និងការយល់ឃើញទាក់ទងនិងព្រហ្មចារីរបស់ អ្នកស្រឡាញ់ភេទដូចគ្នា(បន្ត) ៣/៥



# "ប្រសិនបើមនុស្សប្រុសកំណត់លក្ខខណ្ឌថា មនុស្សស្រីត្រូវតែនៅព្រហ្មចារីនោះ សេចក្តីស្រឡាញ់របស់បុគ្គលនោះគឺនៅមានកម្រិត"

អ្នកតបសម្ភាសវ័យក្មេងដែលជាអ្នកស្រឡាញ់ភេទដូចគ្នា (Z21M)

## បទពិសោធន៍ និងការយល់ឃើញក្នុងចំណោមអ្នកចូលរួមដែលជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា

ដូចគ្នាទៅនឹងឥរិយាបថទៅលើព្រហ្មចារីរបស់អ្នកស្រឡាញ់ភេទដូចគ្នា អ្នកឆ្លើយតបសម្ភាស និងការស្ទង់មតិ បានបង្ហាញការយល់ឃើញខុសប្លែកគ្នាដ៏ទូលំទូលាយ ទន្ទឹមនេះទស្សនៈរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ក៏មានភាពខុសប្លែកគ្នាយ៉ាងទូលំទូលាយផងដែរ។

ជាឧទាហរណ៍ គូស្នេហ៍ស្រឡាញ់ស្រីដូចគ្នាមួយគូបានរៀបរាប់ពីទស្សនៈដូចខាងក្រោម៖

សំណួរ៖ តើអ្នកគិតថាអាចទទួលយកបានទេ សម្រាប់នារីវ័យក្មេង...ក្នុងការរួមភេទជាមួយដៃគូរយៈពេលវែង?
ចម្លើយ: ទេ! អត់ទាំងដៃគូរយៈពេលវែង និងដៃគូថ្មី។
សំណួរ៖ ដូច្នេះ សម្រាប់អ្នក នាងមិនត្រូវរួមភេទមុនពេលរៀបការនោះទេ? សូម្បីតែនាងបានភ្ជាប់ពាក្យហើយក៏ដោយ?
ចម្លើយ៖ ចាំ!
-----
សំណួរ៖ តើអ្នកគិតថា អ្នកស្រឡាញ់ភេទដូចគ្នាគួរតែរងចាំរហូតដល់ពេលពួកគេរស់នៅជាមួយគ្នា ទើបរួមភេទ?
ចម្លើយ៖ ខ្ញុំគិតថា ពួកគេគួរតែរងចាំរហូតដល់ពួកគេរស់នៅជាមួយគ្នា និងស្គាល់គ្នាសិន មុនពេលធ្វើអ្វីមួយ។

ការដកស្រង់នេះ គូសបញ្ជាក់អំពីសារៈសំខាន់នៃការបង្ហាញពីទស្សនៈ និងគំនិតខុសៗគ្នា នៅក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

ទោះជាយ៉ាងណាក៏ដោយ ការឆ្លើយតបរបស់អ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ៗ ហាក់បានឆ្លុះបញ្ចាំងពីទស្សនៈសេរីនិយមច្រើនទៅលើបញ្ហាទាក់ទងនឹងស្វ័យភាពផ្លូវភេទ និងវប្បធម៌ព្រហ្មចារី។

ជាឧទាហរណ៍ អ្នកឆ្លើយតបវ័យក្មេងម្នាក់ដែលជាអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រ បានពន្យល់ប្រាប់គូស្នេហ៍ស្រឡាញ់ភេទផ្ទុយគ្នាថា "ជាការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ ថាតើពួកគេសម្រេចចិត្ត រៀបការ ឬអត់" ហើយថា "ការរួមភេទមុនរៀបការមិនមានអ្វីខុសនោះទេ ដរាបណាជាជម្រើសរបស់ពួកគេ។" (Z21M)

នៅពេលសួរថា តើអ្នកស្រឡាញ់ភេទដូចគ្នាគួររងចាំរហូតដល់ពួកគេរស់នៅជាមួយគ្នាឬទេ ទើបរួមភេទ អ្នកឆ្លើយតប ដដែលនេះបានឆ្លើយដូចខាងក្រោម៖

"ខ្ញុំមិនគិតដូច្នោះទេ ពីព្រោះសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា សម្រាប់ខ្ញុំ ខ្ញុំគ្មានអ្វីត្រូវបាត់បង់នោះទេ។ ប្រសិនបើខ្ញុំចង់ធ្វើសកម្មភាពផ្លូវភេទ ដោយសារតែខ្ញុំចង់ស្វែងយល់បន្ថែមទៀត។ សម្រាប់ខ្ញុំ សកម្មភាពផ្លូវភេទគឺសម្រាប់ជាការសប្បាយ។ សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ពួកគេគ្មានព្រហ្មចារីដែលត្រូវបាត់បង់នោះទេ ដូច្នេះសកម្មភាពនេះជាការសប្បាយ និងស្វែងយល់បន្ថែម ដរាបណាយើងអាចប្រើប្រាស់ការការពារ។"

"អ្នកស្រឡាញ់ភេទដូចគ្នាមានភាពក្លាហានច្រើនជាងអ្នកស្រឡាញ់ភេទផ្ទុយគ្នាឆ្ងាយណាស់ នៅពេលដែលនិយាយអំពីការបង្ហាញ និងទំនាក់ទំនងផ្លូវភេទ។ ពួកគេក៏ប៉ិនប្រសប់ផងដែរ នៅពេលដែលនិយាយអំពីការបង្ហាញពីភាពស្និទ្ធស្នាល និងការរួមភេទ។"

អ្នកតបសម្ភាសដែលជាអ្នកស្រឡាញ់ភេទដូចគ្នាមកពីអង្គការសង្គមស៊ីវិល (C5F)

នៅពេលសួរថា តើព្រហ្មចារីត្រូវបានគេមើលឃើញថាមានសារៈសំខាន់ក្នុងចំណោមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដែរឬទេ អ្នកឆ្លើយតបសំណួរបានឆ្លើយថា អ្វីដែលសំខាន់បំផុតនោះ គឺចំណេះដឹងអំពីការប្រព្រឹត្តផ្លូវភេទប្រកបដោយសុវត្ថិភាព និងមានការយល់ព្រមពីភាគីសងខាង។ ចំពោះថា តើព្រហ្មចារីរបស់ដៃគូសំខាន់ចំពោះខ្លួនគាត់ ឬអត់នោះ គាត់បានឆ្លើយថា៖

"ខ្ញុំមិនប្រកាន់ទេ ព្រោះខ្ញុំស្រលាញ់មនុស្សម្នាក់ដោយមិនគិតពីបទពិសោធន៍ផ្លូវភេទរបស់គេនោះទេ។ ខ្ញុំមិនខ្វល់ថាគាត់ធ្លាប់រួមភេទ ឬអត់។ អ្វីដែលសំខាន់នោះគឺថា នាពេលបច្ចុប្បន្ននេះខ្ញុំស្រលាញ់គាត់។" (Z21M)

អ្នកឆ្លើយតបសម្ភាសជាស្រ្តីវ័យក្មេងដែលជាអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ទៀត ក៏បានយល់ស្របជាមួយនឹងគំនិតទាំងនេះផងដែរ ដោយផ្តល់ដំបូន្មានថា អ្វីដែលសំខាន់បំផុតសម្រាប់បុគ្គលស្រឡាញ់ភេទដូចគ្នា ចំពោះសកម្មខាងផ្លូវភេទគឺ 'ការរួមភេទដោយសុវត្ថិភាព' និង 'សុភមង្គល'៖

"ខ្ញុំគិតថា ពួកគេមិនពិភាក្សាអំពីព្រហ្មចារីទេ ប៉ុន្តែពួកគេពិភាក្សាអំពីការរួមភេទប្រកបដោយសុវត្ថិភាព...ជំនួសមកវិញ គឺអំពីរបៀបក្នុងការរស់នៅជាមួយគ្នាតាមមធ្យោបាយដែលមានផាសុខភាព និងផ្តល់សុភមង្គលដល់ពួកគេទាំងពីរ។" (Z22F)

អ្នកឆ្លើយតបសំណួរវ័យក្មេងទាំងនេះម្នាក់ៗ មានទស្សនៈខុសៗគ្នាទៅលើ ថាតើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានឹងពិភាក្សាបន្ថែមអំពី "ការរង់ចាំរហូតដល់ពេលរៀបការ" ក្នុងការរួមភេទនៅពេលដែលប្រទេសកម្ពុជាមានសមភាពអាពាហ៍ពិពាហ៍។

អ្នកឆ្លើយតបជាយុវតីម្នាក់បានតបថា "ខ្ញុំគិតថា អត់ទេ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នារង់ចាំតែការរៀបការរបស់អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានច្បាប់ទទួលស្គាល់... ព្រហ្មចារី មិនមែនជាប្រធានបទនៃការពិភាក្សាសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាទៀតទេ ជាពិសេសសម្រាប់ខ្ញុំ ប្រធានបទសម្រាប់ពិភាក្សាគឺ ទាក់ទងនឹងការរួមភេទប្រកបដោយសុវត្ថិភាព។" (Z22F)

ទោះយ៉ាងណាក៏ដោយ សម្រាប់អ្នកឆ្លើយតបសំណួរជាយុវជនម្នាក់ លោកបានផ្តល់ការយល់ឃើញថា យ៉ាងហោចណាស់ ប្រហែលជានឹងមានការជជែកដេញដោលគ្នានៅក្នុងសហគមន៍៖

"ខ្ញុំគិតថា ប្រធានបទនេះ នឹងត្រូវបានពិភាក្សានៅពេលដែលអាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានទទួលស្គាល់ដោយច្បាប់ ។ គុណសម្បត្តិ និងគុណវិបត្តិនឹងត្រូវបានយកមកពិភាក្សា។ សូម្បីតែក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នាក៏ដោយ របៀបគិតរបស់ពួកគេគឺ ខុសគ្នា ដូច្នេះគួរតែមានការជជែកដេញដោលអំពីអ្វីដែលសមរម្យ។ សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំមិនប្រកាន់ទេ ចំពោះការមិនរង់ចាំរហូតដល់ពេលរៀបការ។" (Z21M)

# ៧.០ ការវិវត្តន៍នៃបរិបទសង្គម ?

"ប្រហែលទសវត្សរ៍ឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧០ នៅមុនរបបប្រល័យពូជសាសន៍ ប្រជាពលរដ្ឋយើងបាន អនុវត្តយ៉ាងតឹងរ៉ឹង និងអនុលោមតាមបទដ្ឋានប្រពៃណី។ មនុស្សស្រីត្រូវបានទទួលស្គាល់ថា ជាស្ត្រីល្អត្រឹមត្រូវ និងគ្រប់លក្ខណ៍ នៅពេលដែលពួកគេបានរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ។ សព្វថ្ងៃនេះបទដ្ឋានសង្គមរបស់យើងបានវិវឌ្ឍ និងផ្លាស់ប្តូរប្រកបដោយវិជ្ជមានចំពោះសេរីភាពរបស់ស្ត្រី។ គេមិនសូវប្រកាន់ពេកទេនៅពេលនារីវ័យក្មេងមានមិត្តប្រុស។ ពួកគេពិតជាកំពុងចាប់ផ្តើមគាំទ្រមនុស្សស្រីក្នុងការដើរហើរគ្រប់ទីកន្លែងដែលពួកគេចង់ទៅ...*[ហើយ]* មិនសំខាន់ពេកទេសម្រាប់ស្ត្រីក្នុងការរក្សាព្រហ្មចារី...បុរស និងស្ត្រី មានសិទ្ធិស្មើគ្នា ដើម្បីធ្វើការសម្រេចចិត្ត នៅពេលនិយាយអំពីការជ្រើសរើសដៃគូស្និទ្ធស្នាល និងទំនាក់ទំនងផ្លូវភេទ។" ( ***O2M*** )

## ការយល់ឃើញទៅលើការផ្លាស់ប្តូរតាមជំនាន់

ដូចដែលផ្នែកនីមួយៗនៃរបាយការណ៍នេះបានបង្ហាញរួចមកហើយ មានការពិបាកក្នុងការធ្វើទូទៅនីយកម្មអំពីរបៀបដែលប្រជាសាស្ត្រជាក់លាក់មួយយល់ឃើញអំពីតួនាទី និងសារៈសំខាន់នៃព្រហ្មចារី នាពេលសព្វថ្ងៃនេះ។ សេចក្តីថ្លែងដែលមានលក្ខណៈ 'ជឿនលឿន' បំផុតមួយចំនួននៅក្នុងទិន្នន័យសម្ភាសន៍ ទទួលបានមកពីអ្នកចូលរួមជាបុរសវ័យចំណាស់ ខណៈដែលអ្នកចូលរួមជានារីវ័យក្មេងជាច្រើន បាននិយាយអំពីសារៈសំខាន់នៃការរក្សាវប្បធម៌ព្រហ្មចារីក្នុងចំណោមស្ត្រីខ្មែរ។

ទោះបីជាយ៉ាងនេះក្តី និន្នាការដែលអាចសង្កេតបានមួយចំនួននៅក្នុងទិន្នន័យបែបគុណវិស័យ ដែលរាប់បញ្ចូលទាំងអ្នកចូលរួមវ័យក្មេង ដែលជាញឹកញាប់ហាក់រៀបរាប់ពីទស្សនៈបែបទូលាយច្រើនជាងមនុស្សជំនាន់មុន។



អ្នកឆ្លើយតបសំណួរវ័យចំណាស់ជាច្រើន បានឆ្លុះបញ្ចាំងពីតម្លៃនៃវប្បធម៌ព្រហ្មចារី ថាជាផ្នែកដ៏សំខាន់មួយនៃបទដ្ឋានវប្បធម៌ និងប្រពៃណី ដែលពួកគេចាត់ទុកថាជាផ្នែកនៃការបង្ហាញដ៏ប្រពៃនៃសម័យបុរាណ និងដែលត្រូវបានផ្សារភ្ជាប់ជាមួយនិងគំនិតនៃមោទនភាព និងអធិបតេយ្យភាពកម្ពុជា។

ផ្ទុយទៅវិញ អ្នកចូលរួមវ័យក្មេងជាច្រើន បានបង្ហាញការសង្កត់ធ្ងន់យ៉ាងខ្លាំងទៅលើសិទ្ធិ និងសេរីភាពបុគ្គល ហើយផ្តោតការយកចិត្តទុកដាក់តិចតួចទៅលើឥទ្ធិពលនៃវប្បធម៌ និងប្រពៃណី។

ទោះជាយ៉ាងណាក៏ដោយ គោលគំនិតបែបសេរីនិយមនៃស្វ័យភាព និងជម្រើសរបស់បុគ្គលម្នាក់ៗ នៅមានដែនកំណត់ អ្នកចូលរួមវ័យក្មេងភាគច្រើនដែលនិយាយអំពីសិទ្ធិរបស់គូស្នេហ៍វ័យក្មេងក្នុងការរួមភេទមុនពេលរៀបការ ក៏បានទូន្មានឲ្យស្ត្រីមានការប្រុងប្រយ័ត្នចំពោះការរួមភេទជាមួយបុគ្គលដែលគ្មានទំនាក់ទំនងផ្នែកមនោសញ្ចេតនា ឬទំនាក់ទំនងសម្រាប់តែសកម្មភាពផ្លូវភេទផងដែរ។

# ការយល់ឃើញទៅលើការផ្លាស់ប្តូរតាមជំនាន់រវាងក្រុមអាយុ (បន្ត) ២/៨

## 'វឌ្ឍនភាព'

ក្នុងចំណោមយុវវ័យដែលបានគាំទ្រជម្រើសស្មើគ្នាទាក់ទងនឹងការរួមភេទមុនពេលរៀបការ ការឆ្លើយតបរបស់ពួកគេក៏បានពិភាក្សាអំពីប្រធានបទទាក់ទងនឹង 'វឌ្ឍនភាព' ដែលជាមធ្យោបាយពន្យល់អំពីអ្វីដែលពួកគេមើលឃើញថា ជាការផ្លាស់ប្តូរការយល់ឃើញទៅតាមជំនាន់។

ឧទាហរណ៍ ចំណុចទាំងនេះរួមបញ្ចូលទាំង លទ្ធភាពទទួលបានសេវាឪជីថល ការប្រសើរឡើងនៃគុណភាពអប់រំ ស្ថិរភាពសង្គម និងនយោបាយ និងការទទួលបានព័ត៌មាន និងគំនិតថ្មីៗកាន់តែទូលំទូលាយ។ គំនិតនេះត្រូវបានបង្ហាញដោយឧទាហរណ៍ពីអ្នកឆ្លើយតបសំណួរជាយុវជនម្នាក់ ដូចខាងក្រោម៖

"ខ្ញុំគិតថា មានការផ្លាស់ប្តូរផ្នែកវប្បធម៌... ក្មេងៗឥឡូវទទួលបានការអប់រំជាច្រើនជុំវិញបញ្ហាទាំងនេះ។" (Z28M)

គំនិតនេះនៃការផ្លាស់ប្តូរនៅក្នុងបទដ្ឋានព្រហ្មចារី ដែលត្រូវបានផ្សារភ្ជាប់ទៅ នឹងគន្លងកាន់តែទូលំទូលាយ នៃ 'វឌ្ឍនភាព' ក៏ត្រូវបានលើកឡើងដោយអ្នកឆ្លើយតបសំណួរមកពីអង្គការសង្គមស៊ីវិលផងដែរ ដូចដែលបានបង្ហាញដោយសម្រង់បទសម្ភាសន៍ខាងក្រោម៖

"យុវជនកាន់តែទទួលបានភាពរីកចម្រើននិងជឿនលឿនជាងមុន ពីព្រោះពួកគេកំពុងរស់នៅជាមួយបទពិសោធន៍របស់ពួកគេនៅក្នុងបរិយាកាសទំនើប។" (C2F)



## ស្នេហាមុនពេលរៀបការ៖

យុវជនអ្នកឆ្លើយតបសំណួរដដែលនេះ ក៏បានពន្យល់ថា យុវជនកាន់តែចាត់ទុកស្នេហា និងភាពស្និទ្ធស្នាលថា អាចបង្ហាញបានតាមរយៈសកម្មភាពផ្លូវភេទ និងបានផ្សាភ្ជាប់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ធ្វើឡើងដោយការរៀបចំដែលមានលក្ខណៈទូទៅសម្រាប់មនុស្សជំនាន់មុន និងវប្បធម៌ព្រហ្មចារីថា៖

"[យុវវ័យ] យល់កាន់តែច្រើនអំពីស្នេហា និងព្រហ្មចារី។ នៅជំនាន់មុន អាពាហ៍ពិពាហ៍ដោយរៀបចំ មានន័យថា ឪពុកម្តាយជាច្រើនបានរៀបចំអាពាហ៍ពិពាហ៍ ដោយមិនបានឱ្យពួកគេដឹងអំពីការចាត់ចែងនេះទេ...ផ្នត់គំនិតនេះកំពុងតែត្រូវបានផ្លាស់ប្តូរបន្តិចម្តងៗ។

មនុស្សដែលបានផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគេ ដឹងថា ពួកគេស្រឡាញ់ដៃគូរបស់ពួកគេ ដោយគំនិតរបស់ពួកគេ និងអ្វីផ្សេងទៀត មិនមែនត្រឹមតែព្រហ្មចារីរបស់ពួកគេនោះទេ។ ស្នេហាមានន័យថា ជាអ្វីដែលលើសពីការរួមភេទ។ បច្ចុប្បន្ន មានការផ្លាស់ប្តូរអំពីការយល់ឃើញទាំងនេះ ពីជំនាន់មុនទៅជំនាន់ថ្មី។"(Z28M)

គំនិតដែលយល់ឃើញថាការរួមភេទ គឺសំដៅដល់សេចក្តីស្រឡាញ់ និងភាពស្និទ្ធស្នាលជាជាងជាកម្មវត្ថុសម្រាប់ផ្តល់ជា "អំណោយ" ឬ "រង្វាន់" ដល់ស្វាមី គឺជាប្រធានបទទូទៅក្នុងចំណោមអ្នកចូលរួមវ័យក្មេងដែលបានបង្ហាញទស្សនៈជឿនលឿន ជុំវិញការរួមភេទមុនពេលរៀបការ។

យុវជនឆ្លើយតបសម្ភាសម្នាក់ទៀត ក៏បានបង្ហាញគំនិតនេះយ៉ាងច្បាស់ ដោយលើកហេតុផលថា៖

"អាពាហ៍ពិពាហ៍មិនគួរជាខ្សែបន្ទាត់ដើម្បីគូសអំពីអ្វីដែលស្ត្រីត្រូវបានអនុញ្ញាត ឬមិនត្រូវបានអនុញ្ញាតឱ្យធ្វើនោះទេ...អាពាហ៍ពិពាហ៍គួរតែជាការប្តេជ្ញាចិត្តនៃសេចក្តីស្រឡាញ់...ដូច្នេះពួកគេមិនគួរខ្វល់អំពីអតីតកាលនោះទេ។" (Z11M)

ការលើកឡើងអំពីបទពិសោធន៍នៃអាពាហ៍ពិពាហ៍ដោយរៀបចំ និងការគាំទ្រដល់វប្បធម៌ព្រហ្មចារីនេះ ក៏អាចជាប្រធានបទដ៏គួរឲ្យចាប់អារម្មណ៍ សម្រាប់ការស្រាវជ្រាវនាពេលអនាគត។

## តម្លៃសង្គម និងទ្វេស្តង់ដារ៖

ខណៈពេលដែលអ្នកចូលរួមវ័យក្មេងជាច្រើននាក់ បានបង្ហាញពីសារៈសំខាន់នៃកេរ្តិ៍ឈ្មោះគ្រួសារ និងឋានៈសង្គម ប្រធានបទទាំងនេះបានបង្ហាញកាន់តែលេចធ្លោក្នុងចំណោមមនុស្សចាស់។ ដើម្បីធានាបាននូវការថែរក្សាតម្លៃសង្គមទាំងនេះ អ្នកចូលរួមបានរាយការណ៍ថា ឪពុកម្តាយមានទំនោរកាន់តែតឹងរ៉ឹងជាមួយកូនស្រីរបស់ពួកគេ បើធៀប នឹងកូនប្រុស តាមរយៈការដាក់កំណត់លើអាកប្បកិរិយា និងសេរីភាពនៃការដើរហើររបស់ពួកគេ ដើម្បីធានាបាននូវការប្រតិបត្តិតាមក្រមសីលធម៌ដូចមានចែងនៅក្នុងក្រមច្បាប់ស្រី។

ផ្ទុយទៅវិញ ដោយសារតែទិន្នន័យនៅក្នុងរបាយការណ៍នេះបានបង្ហាញម្តងហើយម្តងទៀត អំពីសម្ពាធសង្គម និងការវិនិច្ឆ័យលើបុរស ដែលជាលទ្ធផលនៃតម្លៃសង្គមតឹងរ៉ឹង គឺមានលក្ខណៈធូរលុងបើប្រៀបធៀបទៅនឹងស្ត្រី។ ការទាមទារសមភាពរវាងស្ត្រី និងបុរស ដូចដែលបានបញ្ជាក់ដោយអ្នកឆ្លើយតបសំណួរនៅក្នុងបទសម្ភាសន៍បង្ហាញពីរបកគំហើញដ៏គួរឱ្យចាប់អារម្មណ៍មួយគឺ៖

អ្នកចូលរួមវ័យក្មេងមួយចំនួន (ជាទូទៅ ប៉ុន្តែមិនមែនទាំងអស់ទេ) បានសម្តែងការមិនពេញចិត្តជាមួយស្ថានភាពទ្វេស្តង់ដារទាំងនេះ ដែលគោលជំហរនេះបានបង្ហាញដំណោះស្រាយសម្រាប់ការគិតគូឲ្យស្ថានភាពសេរីភាព និង ស្វ័យភាពផ្លូវភេទរបស់ស្ត្រីវ័យក្មេងកាន់តែប្រសើរឡើង។ ម្យ៉ាងទៀត អ្នកឆ្លើយតបសំណួរវ័យចំណាស់មួយចំនួន (ជាទូទៅ ប៉ុន្តែមិនមែនទាំងអស់ទេ) ក៏បានចាត់ទុកទ្វេស្តង់ដារ ថាជាបញ្ហាផងដែរ ប៉ុន្តែបានអះអាងថាជាការពិត អ្វីដែលត្រូវការគឺជាការដាក់សម្ពាធបន្ថែមទៀតទៅលើបុរស ដើម្បីអនុលោមតាមវប្បធម៌ព្រហ្មចារី។

ភាពខុសគ្នាទៅតាមជំនាន់ខាងផ្នែកឥរិយាបថនេះ ត្រូវបានឆ្លុះបញ្ចាំងដោយអ្នកឆ្លើយតបសំណួរមកពីអង្គការសង្គមស៊ីវិលដែលអះអាងថា យុវជន "មានលក្ខណៈជឿនលឿនជាងមនុស្សចាស់" ពីព្រោះថា៖

"ពួកគេហាក់មានឱកាសច្រើនជាងក្នុងការចេញពីផ្ទះ... ទៅសាលារៀន សាកលវិទ្យាល័យ កន្លែងធ្វើការ... ធ្វើការងារនៅឆ្ងាយពីផ្ទះ រស់នៅទីក្រុងផ្សេងៗ ឬសិក្សានៅបរទេស។ កាលណាពួកគេរស់នៅឆ្ងាយពីផ្ទះកាន់តែច្រើន ការដាក់វិន័យតឹងរ៉ឹងពីឪពុកម្តាយរបស់ពួកគេ ក៏កាន់តែកាត់បន្ថយ។ ពួកគេមានឱកាសកាន់តែច្រើនក្នុងការជួបមនុស្ស។ ពួកគេកាន់តែបើកចំហចំពោះការមានមិត្តប្រុស និងមិត្តស្រី។ ជាមួយនឹងបទពិសោធន៍ទាំងនោះ ពួកគេអាចចាប់ផ្តើមចោទសួរពីអ្វីដែលឪពុកម្តាយរបស់ពួកគេបានបង្រៀនអំពីព្រហ្មចារីដូចជា៖ 'តើអ្វីទៅជាភាពជាប់ទាក់ទងគ្នារវាងព្រហ្មចារី និងកិត្តិយស និងការក្បត់គ្រួសារ?' ជាដើម។" (C3F)

សម្រង់សម្តីនេះ បានឆ្លុះបញ្ចាំងពីទស្សនៈដែលថា សម្រាប់ក្មេងជំនាន់ក្រោយ តម្លៃសង្គមដូចជា 'សេចក្តីថ្លៃថ្នូរ' និង 'សីលធម៌' មិនត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំងជាមួយនឹងភាពបរិសុទ្ធ និងសុភាពរាបសារដូចមនុស្សជំនាន់មុននោះទេ។

# ការយល់ឃើញទៅលើការផ្លាស់ប្តូរតាមជំនាន់រវាងក្រុមអាយុ ( បន្ត ) ៥/៨

## បណ្តាញសង្គម និងឥទ្ធិពលពីបស្ចឹមលោក៖

អន្តរកម្មនៅតាមបណ្តាញសង្គម និងការបង្ហាញឱ្យឃើញកាន់តែច្រើនឡើងនូវវប្បធម៌បស្ចឹមប្រទេសក៏ត្រូវបានលើកឡើងដោយអ្នកចូលរួមផងដែរ ដោយចង្អុលបង្ហាញថា កត្តានេះបានរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋានព្រហ្មចារីដោយប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវបានចោទប្រកាន់ថាមានមាតិកា និងខ្លឹមសារជាប់ទាក់ទងនឹង "ការកម្សាន្តខាងផ្លូវភេទដែល...ប៉ះពាល់ដល់ផ្នត់គំនិតរបស់ក្មេងវ័យជំទង់" និងជា "ការរួមចំណែកដ៏សំខាន់ចំពោះការធ្លាក់ចុះនៃវប្បធម៌ព្រហ្មចារី។" (Z5F)

អ្នកឆ្លើយតបសំណួរវ័យចំណាស់ជាច្រើននាក់ បានឆ្លុះបញ្ចាំងជាអវិជ្ជមានទៅលើនិន្នាការទាំងនេះ ដោយចាត់ថាជា កម្លាំងអវិជ្ជមានពីរ ដែលជំរុញឱ្យយុវជនមិនខ្វល់ពី វប្បធម៌ និងប្រពៃណីខ្មែរ និងចូលរួមក្នុងសកម្មភាព និងទំនាក់ទំនងផ្លូវភេទតាំងពីក្មេងវ័យ៖

"វប្បធម៌ព្រហ្មចារីបានផ្លាស់ប្តូរ ហើយសព្វថ្ងៃមិនមានភាពតឹងរ៉ឹងទេ ដោយសារតែមនុស្សរស់នៅជាមួយបច្ចេកវិទ្យាទំនើប ហើយពួកគេមិនស្តាប់ដំបូន្មានឪពុកម្តាយ ឬមនុស្សចាស់ដូចពីមុនទេ។" (O5F)

"សង្គមយើងកាន់តែរីកចម្រើន ជាពិសេសក្មេង។...ដោយសារតែការអប់រំ និងការយល់ដឹង កាន់តែប្រសើរឡើងនៅក្នុងចំណោមសាធារណៈជន ទាំងបុរស និងស្ត្រី។

សហគមន៍អន្តរជាតិដែលកំពុងចូលមកក្នុងប្រទេសរបស់យើង ក៏មានឥទ្ធិពលលើការផ្លាស់ប្តូរមួយចំនួនផងដែរ។

លើសពីនេះទៀត មនុស្សត្រូវបានបង្ហាញឱ្យឃើញនូវរបៀបរស់នៅ និងបរិស្ថានខុសៗគ្នាតាមរយៈ ការធ្វើដំណើរកម្សាន្ត ខ្សែភាពយន្តតន្ត្រី និងប្រព័ន្ធផ្សព្វផ្សាយសង្គម។" ( *O2M* )

# ការយល់ឃើញទៅលើការផ្លាស់ប្ដូរតាមជំនាន់រវាងក្រុមអាយុ (បន្ត) ៦/៨

និន្នាការបែបនេះ ត្រូវបានពិពណ៌នាជាញឹកញាប់ថា ជារឿងគ្រោះថ្នាក់ និងធ្វើឱ្យអន្តរាយ ដល់សង្គមទាំងមូល។ ជាឧទាហរណ៍ អ្នកតបសម្ភាសជាស្ត្រីចំណាស់ម្នាក់បានពន្យល់ថា គាត់មើលមិនឃើញថា វប្បធម៌ខ្មែរ និងការធ្វើឱ្យទៅជាធម្មតានៃការរួមភេទមុនរៀបការ អាចច្របាច់បញ្ចូលគ្នាបាននោះទេ ដូច្នេះហើយគាត់ច្រានចោលការយល់ឃើញទាំងស្រុង៖

សំណួរ៖ "តើអ្នកយល់ស្របនឹងការលើកឡើងថា៖ 'ការរួមភេទមុនពេលរៀបការគឺជាជម្រើស និងជាសិទ្ធិ" ទេ?

ចម្លើយ៖ "ខ្ញុំមិនយល់ស្របជាមួយសេចក្ដីថ្លែងបែបនេះទេ...ប្រសិនបើមនុស្សភាគច្រើននៅក្នុងប្រទេសយើងជឿថា ការរួមភេទមុនរៀបការគឺជាសិទ្ធិ និងជម្រើសរបស់ពួកគេ តើតួនាទីនៃព្រហ្មចារីនៅឯណា? តើអាពាហ៍ពិពាហ៍មានន័យដូចម្ដេច? សរុបមក ជម្រើស និងសិទ្ធិ ដែលប្រឆាំងនឹងវប្បធម៌របស់យើង គឺមិនអាចទទួលយកបានទេ សម្រាប់ខ្ញុំ។"

សំណួរ៖ "តើអ្នកគិតថា ការរួមភេទរបស់នារីវ័យក្មេងជាមួយដៃគូស្និទ្ធស្នាលដែលមានទំនាក់ទំនងស្នេហារយៈពេលវែង អាចទទួលយកបានច្រើនជាងនេះដែរ ឬទេ បើប្រៀបធៀបទៅនឹងការសម្រេចចិត្តរួមភេទជាមួយមិត្តភក្តិ ឬមនុស្សចម្លែកមុខ?"

ចម្លើយ៖ "ខ្ញុំមិនជ្រើសរើសទាំងអស់ មិនថាជាដៃគូយូរអង្វែង មិត្តភក្តិ ឬមនុស្សចម្លែកមុខអ្វីនោះទេ ស្ត្រី ជាទូទៅ ត្រូវរង់ចាំរហូតដល់រៀបការ...ខ្ញុំគិតថាដោយសារតែ សង្គមសម័យទំនើប ពួកគេអាចធ្វើអ្វីបានតាមចិត្ត ប៉ុន្តែនៅក្នុងសម័យរបស់ខ្ញុំ យើងត្រូវធ្វើតាមប្រពៃណី។" (O12F)

អ្នកចូលរួមវ័យចំណាស់ជាច្រើននាក់ បានយល់ថាប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គមកំពុងជះឥទ្ធិពលអវិជ្ជមាន ដល់វប្បធម៌ និងប្រពៃណីខ្មែរ ដោយសារតែអ្វីដែលពួកគាត់មើលឃើញដូចជា មាតិកាអសីលធម៌ និងគោលគំនិតមិនត្រឹមត្រូវ ជាច្រើនដែលនឹងប៉ះពាល់ដល់យុវជនដែលមិនមានចំណេះដឹងគ្រប់គ្រាន់អំពីអ្វីដែលត្រូវ ឬខុស ជាពិសេស នៅតាមតំបន់ជនបទ។ ចំណុចនេះក៏ជាទស្សនៈដែលផ្ដល់ដោយអ្នកឆ្លើយតបសំណួរវ័យក្មេងមួយចំនួនផងដែរ ដូចឧទាហរណ៍ខាងក្រោមបង្ហាញថា៖

"ប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គមពិតជាមានឥទ្ធិពលខ្លាំងណាស់...កម្រិតនៃឥទ្ធិពល [លើយុវវ័យនៅតាមទីក្រុង] គឺតិចជាង បើប្រៀបធៀបទៅនិងយុវវ័យនៅតាមជនបទ ដែលពួកគេផ្ដោតលើវា ជាក់ស្ដែងដូចជាអ្វីដែលពួកគេកំពុងធ្វើនៅលើ TikTok ជាដើម។ មាតិកាខ្លះ សំដៅទៅរកមនុស្សដែលអាចរងឥទ្ធិពល។ ពួកគេគឺជាជនរងគ្រោះនៃមាតិកាណាដែលធ្វើឲ្យពួកគេមានអារម្មណ៍ស្រើបស្រាល និងចង់រួមភេទជាមួយដៃគូរបស់ពួកគេ។" (Z28M)

# ការយល់ឃើញទៅលើការផ្លាស់ប្តូរតាមជំនាន់រវាងក្រុមអាយុ (បន្ត) ៧/៨

គំនិតដែលយល់ថា ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គមបានជម្រុញឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតរបស់យុវជនកម្ពុជាយ៉ាងឆាប់រហ័ស និងនាំឱ្យពួកគេចាប់អារម្មណ៍នឹងរបៀបរស់នៅ និងសេចក្តីប្រាថ្នា "បែបទំនើប" កាន់តែច្រើននោះ ត្រូវបានលើកឡើងដោយអ្នកឆ្លើយតបសម្ភាសមកពីអង្គការសង្គមស៊ីវិល ទោះបីជាមានសុទិដ្ឋិនិយមច្រើនជាងឆ្ងាយក៏ដោយ៖

"ប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម បានដើរតួនាទីយ៉ាងធំក្នុងការបើកចំហព្រំដែនចំណេះដឹងរបស់មនុស្ស។ មនុស្សដឹងថាមានមធ្យោបាយផ្សេងៗទៀតដើម្បីរស់នៅក្នុងជីវិតរបស់ពួកគេ។ ជាមួយនឹងចំណេះដឹង និងព័ត៌មាន មនុស្សបានចាប់ផ្តើមតស៊ូ និងលើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងការដើរលើវិថីជីវិតផ្សេងៗទៀត។ នេះគឺជាប្រតិកម្មដែលធ្វើតៗគ្នា!" (C1F)

ដូច្នេះ មានការយល់ឃើញខុសប្លែកគ្នាយ៉ាងខ្លាំងក្នុងចំណោមអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ ចំពោះរបៀបដែលប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម មានឥទ្ធិពលលើយុវវ័យទាក់ទងនឹងវប្បធម៌ព្រហ្មចារី និងថា តើនេះជាការប្រសើរ ឬអាក្រក់ជាងនេះ។

ទោះជាយ៉ាងណាក៏ដោយ ដូចដែលសម្រង់សម្តីនៅក្នុងរបាយការណ៍នេះបានបង្ហាញម្តងហើយម្តងទៀតថា រឿងសំខាន់ដែលគួរកត់សម្គាល់គឺថា មានអ្នកចូលរួមវ័យក្មេងជាច្រើននៅតែបន្តបង្ហាញការយល់ស្រប និងអនុលោមតាមវប្បធម៌ព្រហ្មចារី ដែលនេះបង្ហាញឱ្យឃើញថាគន្លងនៃការយល់ឃើញតាមជំនាន់ គួរតែត្រូវបានស្វែងយល់ និងវិភាគដោយការប្រុងប្រយ័ត្នខ្ពស់។

យ៉ាងណាក៏ដោយអ្វីដែលអាចនិយាយបានគឺថាមានការយល់ឃើញដ៏ច្បាស់មួយនៅក្នុងបណ្តុំទិន្នន័យទាំងមូល ទាំងយុវវ័យ ទាំងមនុស្សចាស់ គឺថា បរិបទសង្គមគឺពិតជាកំពុងផ្លាស់ប្តូរ មែន៖

"ប្រសិនបើ យើងនិយាយអំពីមនុស្សចាស់ជំនាន់មុនគឺចាំបាច់ណាស់ត្រូវមានការរៀបការជាមុនសិន ទើបគូស្នេហ៍អាចរស់នៅជាមួយគ្នាបាន។ [សម្រាប់] ជំនាន់របស់ខ្ញុំ ខ្ញុំត្រូវការរក្សាព្រហ្មចារីរបស់ខ្ញុំ រហូតដល់ពេលរៀបការ ប៉ុន្តែសព្វថ្ងៃនេះ វាពិបាកនឹងដឹងណាស់ពីព្រោះមនុស្សមួយចំនួនរស់នៅជាមួយគ្នា និងបែកបាក់គ្នាជាដើម...។" (O3F)

ចំណុចនេះ ក៏ត្រូវបានគាំទ្រយ៉ាងខ្លាំងពីទិន្នន័យស្ទង់មតិ ដែលបង្ហាញពីការធ្លាក់ចុះនៃសារៈសំខាន់នៃវប្បធម៌ព្រហ្មចារី៖

# ការយល់ឃើញទៅលើការផ្លាស់ប្តូរតាមជំនាន់ រវាងក្រុមអាយុ (បន្ត) ៨/៨

## គំនូសសម្គាល់ទី ១៦

**បើប្រៀបធៀបទៅនឹងស្ថានភាពឆ្នាំ ២០០០ តើសព្វថ្ងៃនេះ ការដែលស្ត្រីត្រូវរក្សាព្រហ្មចារីរហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍មានសំខាន់ប៉ុណ្ណាដែរ?**



# ៨.០ សន្និដ្ឋាន

## ការរំពឹងទុក និងផលវិបាក

របាយការណ៍នេះបានស្វែងយល់អំពីការយល់ឃើញអំពីវប្បធម៌ព្រហ្មចារី ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាដែលមាន អាយុ ប្រវត្តិអាជីពការងារ និងនិន្នាការភេទខុសៗគ្នា។ របាយការណ៍បានចាប់ផ្តើមដោយធ្វើការពិនិត្យទៅលើការរំពឹងទុកនៃការមិនពាក់ព័ន្ធនឹងជីវភាពផ្លូវភេទមុនរៀបការរបស់ស្ត្រីវ័យក្មេង ដោយផ្តោតជាពិសេសទៅលើទិដ្ឋភាពផ្នែកវប្បធម៌ សង្គម និងគ្រួសារ។ បន្ទាប់មក ក៏បានត្រួតពិនិត្យមើលផលវិបាកជាក់ស្តែងដែលស្ត្រីជួបប្រទះ ក្រោយសម្រេចចិត្តរួមភេទមុនរៀបការ ដែលត្រូវបានរាយការណ៍ដូចខាងក្រោម៖

## ផលវិបាកខាងផ្លូវចិត្ត៖

ការថប់បារម្ភ ជំងឺបាក់ទឹកចិត្ត ការឈឺចាប់ ដែលបណ្តាលមកពី អារម្មណ៍នៃការបាត់បង់ 'ភាពបរិសុទ្ធ' និង 'ភាពជាស្ត្រី' អសមត្ថភាពក្នុងការផ្តោតអារម្មណ៍ និងទំនោរនៃការចង់ធ្វើអត្តឃាត។ ផលវិបាកទាំងអស់នេះ ត្រូវអះអាងថាបណ្តាលមកពីការរងនូវភាពអាម៉ាស់ ការមាក់ងាយ និងការធ្វើទុក្ខបុកម្នេញនៅក្នុងសង្គម ដែលនារីវ័យក្មេងជួបប្រទះ នៅពេលដែលបទពិសោធន៍ផ្លូវភេទរបស់នាងត្រូវបានគេដឹង និង/ឬ ការបែកបាក់នៃទំនាក់ទំនងស្និទ្ធស្នាលមុនពេល រៀបការ ដែលតែងតែ ត្រូវបានរៀបរាប់ក្នុងន័យថាបុរស 'បោះបង់ចោល' ដែលបណ្តាលឱ្យមានការខូចចិត្តយ៉ាងខ្លាំង និងការបាត់បង់ឋានៈសង្គម។

## ផលវិបាកផ្លូវកាយ៖

ការឆ្លងជំងឺកាមរោគ (STIs) ការមានផ្ទៃពោះដោយចៃដន្យ និង 'ការខូចខាត' ដល់សរីរាង្គបន្តពូជរបស់ស្ត្រី ដែលជាសញ្ញាណនាំឱ្យគេដឹងថានាងបានបាត់បង់ព្រហ្មចារី។ ផលវិបាកទាំងនេះ ត្រូវបានគេមើលឃើញថាគ្រាន់តែ ឬជាអាទិ៍ ប៉ះពាល់ចំពោះតែស្ត្រីប៉ុណ្ណោះ បើទោះបីជា បុរសក៏អាចឆ្លងជំងឺកាមរោគផងដែរ និងមិនមានភស្តុតាង វេជ្ជសាស្ត្រណាមួយ ដែលអាច 'បញ្ជាក់' អំពីស្ថានភាពដែលថាស្ត្រីបានបាត់បង់ព្រហ្មចារីក៏ដោយ។

## ផលវិបាកនៅក្នុងអាពាហ៍ពិពាហ៍៖

ផលវិបាកទាំងនេះបានបែងចែកជាបីក្រុម៖ ទីមួយ ការដាក់សម្ពាធទៅលើគូស្នេហ៍វ័យក្មេងឱ្យឆាប់រៀបការ នៅពេលដែលត្រូវបានរកឃើញថាបានរួមភេទ ទីពីរ គឺអសមត្ថភាពរបស់ស្ត្រីវ័យក្មេង (ដែលមិនមែនជាបុរសវ័យក្មេង) ក្នុងការស្វែងរកស្វាមី និងទីបី គឺជម្លោះក្នុងចំណងអាពាហ៍ពិពាហ៍នាពេលអនាគត ដោយសារតែស្ត្រីខ្វះ 'ភាពបរិសុទ្ធ' នៅពេលរៀបការ។ ផលវិបាកចុងក្រោយនេះ ត្រូវបានគេមើលឃើញថា មានភាពធ្ងន់ធ្ងរខ្លាំងបណ្តាលឱ្យមានការខ្វះទំនុកចិត្ត ការលែងលះ និងរហូតដល់អំពើហិង្សាក្នុងគ្រួសារទៀតផង។

ផលវិបាកទាំងនេះ ពាក់ព័ន្ធក្នុងរបៀបជាច្រើន សម្រាប់អ្នកតស៊ូមតិផ្នែកយេនឌ័រ ដែលមានគោលបំណងស្វែងយល់ពីចំណុចប្រសព្វដែលអាចកើតមានរវាងបទដ្ឋានផ្លូវភេទ និងការបន្តពូជ ព្រមទាំងចំណេះដឹងផ្លូវភេទ និងរបៀបដែលស្ត្រីត្រូវបានរើសអើងនៅក្រុមគ្រួសារ និងក្នុងសង្គម។ ជាឧទាហរណ៍ អ្នកឆ្លើយតបសំណួរជាយុវជនម្នាក់បានធ្វើការភ្ជាប់ដោយផ្ទាល់ទៅនឹងទស្សនៈបែបបើកចំហ និងការបដិសេធរបស់គាត់ក្នុងការវាយតម្លៃទៅលើជម្រើសរបស់ស្ត្រី តាមរយៈចំណេះដឹងផ្នែកកាយវិភាគវិទ្យារបស់គាត់ថា៖

"ខ្ញុំមិនមែនជាមនុស្សស្រីទេ ប៉ុន្តែតាមទស្សនៈរបស់ខ្ញុំ [ការរួមភេទមុនពេលរៀបការ សម្រាប់មនុស្សស្រី] មិនមែនជាបញ្ហាទេ។ ខ្ញុំគិតថាព្រហ្មចារីគឺ មិនមែនជាបញ្ហាទេ សូម្បីតែ សម្រាប់មនុស្សស្រីក៏ដោយ ខ្ញុំបានឃើញភស្តុតាងវិទ្យាសាស្រ្តខ្លះអំពីរឿងនេះ។ [ដូច្នេះ] ពាក្យសម្តីរបស់មនុស្សជំនាន់មុន មិនមានន័យពេញលេញទេ នៅពេលដែលខ្ញុំគិតអំពីវា។ ខ្ញុំគិតថាវាមិនមានបញ្ហាទេ ប្រសិនបើស្ត្រីចង់រក្សាព្រហ្មចារីរហូតដល់រៀបការ ឬបើនាងរួមភេទមុនពេលរៀបការ។" (Z11M)

អ្នកដែលចាប់អារម្មណ៍ក្នុងការលើកកម្ពស់ស្វ័យភាព ឬសមភាពផ្លូវភេទរបស់ស្ត្រី ឬគ្រាន់តែកាត់បន្ថយគ្រោះថ្នាក់ និងការមាក់ងាយដែលបង្កឡើងតាមរយៈ "ការដាក់រហ័សនាម និងការធ្វើឱ្យអាម៉ាស់" ពីសង្គម (C5F) ទៅលើស្ត្រីមិនទាន់រៀបការដែលជ្រើសរើសការរួមភេទ គួរតែពិចារណាលើការបង្កើតខ្លឹមសារដែលផ្តល់នូវការយល់ដឹងឱ្យកាន់តែមានភាពត្រឹមត្រូវថាតើការរួមភេទប៉ះពាល់ដល់រាងកាយរបស់ស្ត្រីដោយរបៀបណា។ លើសពីនេះ បទដ្ឋានវប្បធម៌ព្រហ្មចារី ដែលត្រូវបានគេនិយាយថាមានឥទ្ធិពលទៅលើផលវិបាកយូរអង្វែងក្នុងអាពាហ៍ពិពាហ៍ ដែលត្រូវបានលើកឡើងថាអាចបណ្តាលឱ្យស្ត្រីមួយចំនួនខ្វះទំនុកចិត្តក្នុងការបង្ហាញការចង់បានផ្នែកផ្លូវភេទពីស្វាមីរបស់ពួកគេ ការបង្ហាញពីចំណុច សម្រាប់ធ្វើការស្រាវជ្រាវនាពេលអនាគត។

## ទស្សនៈពីក្រុមអ្នកស្រឡាញ់ភេទដូចគ្នា

របាយការណ៍នេះ ក៏បានពិនិត្យមើលទស្សនៈផ្សេងៗទាក់ទងនឹងបទពិសោធន៍ផ្លូវភេទរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងការកសាងព្រហ្មចារី។ ជាថ្មីម្តងទៀត មានទស្សនៈខុសគ្នាយ៉ាងទូលំទូលាយ ដោយមានអ្នកចូលរួមជាច្រើនបង្ហាញពីកម្រិតខ្ពស់នៃស្វ័យភាព និងសេរីភាពផ្លូវភេទ ក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ៗ ខណៈពេលដែលអ្នកផ្សេងទៀតបានដាស់តឿនថា ពួកគេគួរតែរង់ចាំរហូតដល់មានទំនាក់ទំនងរយៈពេលវែង ឬរស់នៅជាមួយគ្នា ដើម្បីស្គាល់គ្នាច្បាស់ និងទុកចិត្តគ្នាទៅវិញទៅមក មុនពេលរួមភេទ។

សម្រាប់អ្នកឆ្លើយតបជាអ្នកស្រឡាញ់ភេទដូចគ្នា អ្នកតបសម្ភាសដែលជាគូស្នេហ៍ស្រឡាញ់ស្រីដូចគ្នាមួយគូ ក៏នៅតែមានទស្សនៈរឹងមាំមួយ អំពីតម្រូវការរបស់ស្រ្តីដែលស្រឡាញ់ភេទដូចគ្នា ក្នុងការរក្សាព្រហ្មចារីរហូតដល់ពេលរៀបការ ហើយសម្រាប់គូស្នេហ៍អ្នកស្រឡាញ់ភេទដូចគ្នាគួរតែរស់នៅជាមួយគ្នាសិន "មុននឹងធ្វើអ្វីមួយ"។ (Z34F)

ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបដែលជាអ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការព្រមព្រៀងគ្នា និងការរួមភេទប្រកបដោយសុវត្ថិភាព ជាជាងទៅលើគោលគំនិតនៃព្រហ្មចារី ដែលអ្នកឆ្លើយតបមួយចំនួនបានចាត់ទុកថាវាមិនអាចអនុវត្តបានចំពោះពួកគេទេ ទោះក្នុងករណីណាក៏ដោយ។ ចំណុចនេះបង្ហាញពី តម្រូវការក្នុងការពិចារណាសម្រាប់ទស្សនៈ និងការយល់ឃើញខុសៗគ្នា នៅក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

# ការសម្លឹងឆ្ពោះទៅមុខ

ជាចុងក្រោយ របាយការណ៍នេះបានពិនិត្យយ៉ាងសង្ខេបអំពីទំនោរសង្គមឆ្ពោះទៅរកការបើកចំហរ និងការទទួលយកកាន់តែទូលំទូលាយចំពោះការរួមភេទមុនរៀបការនៅកម្ពុជានាពេលបច្ចុប្បន្ននេះ។ សរុបមកការសិក្សានេះបានរកឃើញដូចខាងក្រោម៖

1 ទិន្នន័យដែលទទួលបានពីអ្នកចូលរួមមកពីជំនាន់ផ្សេងៗគ្នាបានបង្ហាញយ៉ាងច្បាស់ថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើនយល់ឃើញថា សង្គមជុំវិញខ្លួនរបស់ពួកគេបាននឹងកំពុងតែផ្លាស់ប្តូរដែលសំដៅទៅរកការថយចុះនៃសារៈសំខាន់ទាក់ទងនឹងបទដ្ឋានព្រហ្មចារី ។

2 ទោះជាយ៉ាងណាក៏ដោយ ផ្អែកលើកម្រិតបុគ្គល អ្នកឆ្លើយតបសំណួរភាគច្រើននៅគ្រប់ក្រុមអាយុទាំងអស់នៅតែរាយការណ៍ថា ព្រហ្មចារីសម្រាប់ស្ត្រីមុនពេលរៀបការ គឺជាអ្វីមួយដែលពួកគេរៀងៗខ្លួនចាត់ទុកថាសំខាន់ យ៉ាងហោចណាស់ក៏សំខាន់បន្តិចបន្តួច ប្រសិនបើមិនសំខាន់ខ្លាំងទេនោះ។

ដូច្នេះខណៈដែលមានការសង្កេតឃើញថា បរិបទសង្គមកំពុងតែមានការវិវត្តយ៉ាងឆាប់រហ័សនោះ ការសិក្សានេះបាន រកឃើញថាបទដ្ឋានប្រពៃណី និងទំនៀមទម្លាប់ នៅតែដើរតួនាទីយ៉ាងសកម្មនៅក្នុងសង្គមកម្ពុជា។ នេះគឺជាភារៈកិច្ច របស់អ្នកតស៊ូមតិផ្នែកយេនឌ័រ ដើម្បីស្វែងរកវិធីសាស្ត្រល្អបំផុតក្នុងការដោះស្រាយបញ្ហាទាំងនេះ ប្រកបដោយភាពរហ័ស និងប្រយ័ត្នប្រយែង ដើម្បីកាត់បន្ថយភាពអាម៉ាស់ផ្អែកលើយេនឌ័រ ការមាក់ងាយ និងការវិនិច្ឆ័យ ទៅលើស្ត្រីដែលជ្រើសរើសប្រើប្រាស់សិទ្ធិស្វ័យភាពផ្លូវភេទរបស់ពួកគេ ខណៈពេលដែលកំពុងគិតគូរអំពីរបៀបដែលបទដ្ឋានជុំវិញបញ្ហាព្រហ្មចារី នៅតែត្រូវបានចាត់ទុកថាត្រឹមត្រូវនឹងមានតម្លៃដោយមនុស្សភាគច្រើននៅក្នុងសង្គមខ្មែរបច្ចុប្បន្ន។ សម្រង់សម្តីខាងក្រោមនេះប្រហែលជាការលើកឡើងដ៏ល្អបំផុតពីអ្នកឆ្លើយតបសំណួរមកពីអង្គការសង្គមស៊ីវិលមួយរូប ដែលបានសង្កត់ធ្ងន់លើ ការសម្រេចចិត្តដោយខ្លួនឯង និងការទទួលយកខ្លួនឯងដោយគ្មានលក្ខខណ្ឌ៖

"យើងមិនគួរប្រាប់គេថាគួររស់នៅដោយរបៀបណានោះទេ ប៉ុន្តែត្រូវឱ្យគេរៀនរស់ដោយខ្លួនគេ។ យើងមិនគួរដាក់សម្ពាធលើ បុរស ស្ត្រី ឬ អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រឲ្យផ្លាស់ប្តូរអ្វីមួយនោះទេ ប៉ុន្តែគួរតែផ្តល់ព័ត៌មានដល់ពួកគេ ដូចនេះពួកគេអាចរៀនធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានដោយខ្លួនឯងផ្ទាល់។ នេះគឺជាជីវិតរបស់ពួកគេ យើងមិនគួរគ្រប់គ្រងលើជីវិតរបស់ពួកគេនោះទេ។ យើងគួរតែផ្តោតលើខ្លួនយើង ហើយរៀនទទួលយកខ្លួនឯងដោយគ្មានលក្ខខណ្ឌ។"

អ្នកតបសម្ភាសជាអ្នកស្រឡាញ់ភេទដូចគ្នាមកពីអង្គការសង្គមស៊ីវិល (C7F)

# ឯកសារពិគ្រោះ

[១] Murdock, G.P., 2017. ទំនាក់ទំនងវប្បធម៌នៃបទប្បញ្ញត្តិនៃអាកប្បកិរិយាក្នុងការផ្លូវភេទមុនពេលរៀបការ។ ដំណើរការ និងលំនាំនៅក្នុងវប្បធម៌ (PP. 399-410). Routledge.

[២] UNFPA, របាយទិន្នន័យយុវជនកម្ពុជា ឆ្នាំ២០១៥, online: <https://bit.ly/3EasbEh>

[៣] វេទិកាអាស៊ីប៉ាស៊ីហ្វិកផ្តោតលើស្ត្រី ច្បាប់ និងការអភិវឌ្ឍ (APWLD), 'ការសិក្សាស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR)', online: <https://bit.ly/3rjMVGb>.

[៤] Nishigaya, K., 2010. ការរស់នៅឆ្ងាញពីផ្ទះ៖ ការរួមភេទមុនពេលរៀបការ និង covariates—ស្ត្រីធ្វើការរោងចក្រនៅក្នុងរាជធានីភ្នំពេញ, ប្រទេសកម្ពុជា. ការសិក្សាចំនួនប្រជាជនអាស៊ី, 6(2), pp.215-239.

[៥] Hoefinger, H., 2013. ការរួមភេទ ស្នេហា និងលុយនៅកម្ពុជា៖ មិត្តស្រីអាជីព និងទំនាក់ទំនងបែបដោះដូរ Routledge.

[៦] Farvid, P. and Saing, R., 2021. "ប្រសិនបើខ្ញុំមិនអនុញ្ញាតឱ្យគាត់រួមភេទជាមួយខ្ញុំ ទំនាក់ទំនងរបស់យើងនឹងបែកបាក់៖ ការចាប់រំលោភ ការបង្ខិតបង្ខំផ្លូវភេទ និងការអនុលោមតាមផ្លូវភេទក្នុងអាពាហ៍ពិពាហ៍នៅជនបទកម្ពុជា។ អំពើហិង្សាលើស្ត្រី, p.10778012211021130.

[៧] ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ (CDHS), 2014, online: <https://bit.ly/3I22h86>

[៨] Hoefinger, H., above [5]

[៩] Nishigaya, K., above [4]

[១០] OI, N., 2011. ស្ត្រីផ្សព្វផ្សាយស្រាបៀរ-ពិធីជប់លៀងបញ្ឈប់នៅទីនេះ៖ របៀបដែលប្រព័ន្ធច្បាប់ និងវប្បធម៌នៅកម្ពុជា និងឧស្សាហកម្មស្រាបៀរបានអនុញ្ញាតឱ្យមានការកេងប្រវ័ញ្ចលើស្ត្រី។ Wis. Int'l LJ

[១១] Farvid, P. and Saing, R., above [6]

[១២] Amnesty International et al, Joint Statement: អង្គការសង្គមស៊ីវិលអំពាវនាវឲ្យលុបចោលសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈជាបន្ទាន់, online: <https://bit.ly/3Ec9aBq>

[១៣] Jacobsen, T., 2012. ធ្វើជាមនុស្សប្រុស៖ បុរសល្អ អាក្រក់ និងបុរសជោគជ័យនៅកម្ពុជា Trude Jacobsen (pp. 100-116). Routledge.

[១៤] United States Department of State, Bureau of Democracy, Human Rights, and Labor, របាយការណ៍សេរីភាពសាសនាអន្តរជាតិនៅកម្ពុជា ឆ្នាំ២០១៨ (Report, 2018) 1, <https://bit.ly/37btHb8>.

[១៥] Kent, A., 2011. ជំរកដោយព្រះធម៌៖ ឆ្លុះបញ្ចាំងអំពីយេនឌ័រ សន្តិសុខ និងសាសនានៅកម្ពុជា Journal of Southeast Asian Studies, 42(2), pp.193-209.

[១៦] Nishigaya, K., above [4]

[១៧] Rigon, S., 2018. តើកូនស្រីរបស់ខ្ញុំនៅមានព្រហ្មចារីឬទេ? សូមលោកគ្រូពេទ្យ ពិនិត្យមើលផង? Journal of family medicine and primary care, 7(1), p.1.

សម្រាប់ព័ត៌មានបន្ថែម៖ info@klahaan.org
របាយការណ៍ទាំងស្រុងអាចទាយយកពីគេហទំព័រ៖ www.klahaan.org